


**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការចោទប្រកាន់របស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ  លោក **ទន់ ជាឆ្លូយ**

លោក **ឥន្ទ សម្ផស្ស**

ណែនាំដោយ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ជាដំបូង ខ្ញុំបាទ **ទង់ ដាឆ្ល័យ** និង ខ្ញុំបាទ **ឥន្ទ សម្ផស្ស** ដែលជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** សូមលំឱនកាយ គោរពសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោក ឪពុក **ហាស់ សេង** អ្នកម្តាយ **យស់ វណ្ណា:** និង លោកឪពុក **ឥន្ទ សុភា** អ្នកម្តាយ **ចាន់ អ៊ីម** ដែលជាទីគោរព ស្រលាញ់ដ៏ខ្ពង់ខ្ពស់បំផុតនៃកូន ដែល លោកអ្នកមានគុណបានផ្តល់កំណើត ក្តីស្រលាញ់ ភាពកក់ក្តៅ អប់រំទូន្មានប្រៀនប្រដៅដល់កូន និង ខិតខំប្រឹងប្រែង ចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីនៅក្នុងគភ៌ រហូតដល់ធំពេញវ័យ។ ហើយខិតខំធ្វើការ ទាំង យប់ទាំងថ្ងៃ គ្មានពេលសម្រាកបានស្រួលឡើយដើម្បីស្វែងរកប្រាក់ ផ្គត់ផ្គង់ ចិញ្ចឹមបីបាច់ និងឧបត្ថម្ភដល់កូន ក្នុងការសិក្សារៀនសូត្រ តាំងពីបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតបានបញ្ចប់ការសិក្សាថ្នាក់ មហាវិទ្យា ល័យបានដោយជោគជ័យ ។ គុណូបការៈ និងព្រហ្មវិហារធម៌របស់លោកអ្នកមានគុណ ចំពោះយើងខ្ញុំពិតជាមាន ទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ហើយគុណធម៌ និងព្រហ្មវិហារធម៌ទាំងនោះគឺស្ថិតក្នុងចិត្តកូនជានិច្ច ជាដរាប។ ហើយខ្ញុំបាទ ក៏សូមថ្លែងអំណរគុណដល់យាយតា អ៊ុំពូមីង បងប្រុស បងស្រី ដែលបានលើទឹកចិត្ត ផ្តល់ជាដំបូលន្មានប្រៀនប្រដៅល្អៗ និងតែងតែឧបត្ថម្ភជាថវិកាផ្ទាល់ខ្លួន ព្រមទាំងសម្ភារៈផ្សេងៗដើម្បីជួយ សម្រួលចំពោះការសិក្សា ដល់ខ្ញុំបាទកន្លងមក ។

យើងខ្ញុំសូមថ្លែងអំណរអរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាវិទ្យាធិការ រង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំអស់ពីសមត្ថភាពក្នុងការផ្តល់ និងផ្ទេរនូវ ចំណេះដឹង បទពិសោទធន៍ ឯកសារសិក្សាស្រាវជ្រាវ ដែលជាប្រទីបបំភ្លឺផ្លូវដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រ រហូតមក ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** ដែលលោកមិន ត្រឹមតែបានបង្រៀនផ្តល់នូវចំណេះដឹងនោះទេ លោកថែមទាំងជាសាស្ត្រាចារ្យ ណែនាំ និងចំណាយពេលវេលាដ៏ មានតម្លៃ ក្នុងការផ្តល់ការប្រឹក្សា និងផ្តល់អនុសាស៍ល្អៗ ដែលធ្វើឱ្យកិច្ចដំណើរការនៃការស្រាវជ្រាវ និងចងក្រងនូវ ឯកសារសារណានេះប្រកបដោយលទ្ធផលល្អ និងភាពរលូន។

យើងខ្ញុំទាំងពីរនាក់សូមគោរពជូនពរ និងលើកហត្ថប្រណម្យដល់គុណ ព្រះរតនត្រៃយ៍ គុណកែវទាំងបី អស់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សា លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យា ធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ឱ្យជួបតែពុទ្ធិពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

ឆ្លងកាត់ការសិក្សាអស់រយៈពេល៤ឆ្នាំមក ក្នុងជំនាញនីតិសាស្រ្តនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ខ្ញុំបាទទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្រៃលែង ដែលសាកលវិទ្យាល័យបានផ្តល់ឱកាស ដល់រូបខ្ញុំបាទទាំងពីរនាក់ ក្នុងការចែករំលែកបញ្ចេញនូវស្នាដៃក្នុងការចងក្រងសារណាបញ្ចប់ឆ្នាំសិក្សាមួយនេះឡើង។ យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្ត និងដោយមានការណែនាំពីលោកគ្រូ **សាស្រ្តាចារ្យ ហ៊ាង ឡេង** ក្នុងការជ្រើសរើសយកប្រធានបទ **ការចោទប្រកាន់របស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង**។ ព្រោះដោយយល់ឃើញថាប្រធានបទមួយនេះមានសារៈសំខាន់ខ្លាំង ដែលជាផ្នែកមួយជាជំនួយស្មារតី ដល់មិត្តអ្នកអានក្នុងការយល់ដឹងបន្ថែម ពីចំណុចសំខាន់ៗមួយចំនួន ដែលទាក់ទងនឹងផ្នែកនីតិវិធីព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលអយ្យការអមសាលាដំបូង។

យើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសយក ប្រធានបទនេះមកធ្វើការស្រាវជ្រាវនិងចងក្រងឡើង ក្នុងគោលបំណងគឺដើម្បី ចូលរួមជាវិភាគទានមួយ ក្នុងដំណើរការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នៅកម្ពុជាបច្ចុប្បន្ន ហើយក៏ទុកជាឯកសារសម្រាប់បំពេញតម្រូវការ របស់និស្សិតជំនាន់ក្រោយៗ និងជួយដល់លោកអ្នកទាំងអស់ដែលបានធ្វើការសិក្សាស្រាវជ្រាវជំនាញវិជ្ជាជីវៈ ជាពិសេសពួកយើងខ្ញុំផ្ទាល់ ឱ្យបានយល់ដឹង ស៊ីជម្រៅច្បាស់លាស់បន្ថែមទៀតអំពីខ្លឹមសារ និងអត្ថន័យនៃក្រមនីតិវិធីព្រហ្មទណ្ឌជាក់ស្តែងគឺនៅក្នុងដំណាក់កាលអយ្យការតែម្តង។

ម្យ៉ាងវិញទៀតនៅក្នុងការស្រាវជ្រាវ និងចងក្រងឯកសារមួយនេះឡើង ប្រាកដជាមាននូវចំណុចខ្វះខាតផ្នែកខ្លឹមសារ និងកំហុសឆ្គង ខាងអក្ខរាវិរុទ្ធ ជាក់ជាពុំខាន។ ដូចនេះយើងខ្ញុំទាំងពីរនាក់សង្ឃឹមថារាល់កំហុសឆ្គងទាំងឡាយដែលកើតមានឡើងក្នុងឯកសារមួយនេះ និងទទួលបាននូវការអធ្យាស្រ័យ និងការអភ័យទោសពីសំណាក់ លោក លោកស្រី សាស្រ្តាចារ្យ និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានជាក់ជាមិនខាន។ ដូច្នេះយើងខ្ញុំសូមទទួលរងចាំ នូវការរិះគន់និងកែតម្រូវក្នុងន័យស្ថាបនា ពីសំណាក់អស់លោក លោកស្រី សាស្រ្តាចារ្យ និងមិត្តអ្នកអានទាំងអស់គ្រប់ពេលវេលា ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សង្ឃឹមថាស្នាដៃមួយនេះ និងទទួលបានលទ្ធផលល្អ ហើយអាចក្លាយជាឯកសារជំនួយស្មារតី ដល់ការស្រាវជ្រាវបន្ថែមរបស់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវបន្តទៅទៀត។ ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមជូនពរដល់អស់លោក លោកស្រី សាស្រ្តាចារ្យ និងមិត្តអ្នកអានគ្រប់រូប ឱ្យជួបតែនិងភាពសុខដុម រុងរឿងថ្កុំថ្កើង និងមានសុភមង្គលជានិច្ចជានិរន្តរកុំបីឃ្លៀងឃ្លាតឡើយ សូមអរគុណ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១៖
## សញ្ញាណនៃបទល្មើស

**១. សញ្ញាណនៃជនល្មើស** ........ ៤
១.១ ជនល្មើសដែលចូលរួមដោយផ្ទាល់ ........ ៤
១.១.១ ចារី ........ ៤
១.១.២ សហចារី ........ ៥
១.២ ជនល្មើសចូលរួមដោយប្រយោល ........ ៥
១.២.១ អ្នកផ្តើមគំនិត ........ ៥
១.២.២ អ្នកសមគំនិត ........ ៥
**២. អត្ថន័យនៃបទល្មើស** ........ ៦
២.១ ធាតុផ្សំបទល្មើស ........ ៦
២.១.១ ធាតុនីត្យានុកូល ........ ៧
២.១.២ ធាតុសន្យានុម័ត ........ ៧
២.១.៣ ធាតុអត្តនោម័ត ........ ៨
**៣. ចំណាត់ថ្នាក់បទល្មើស** ........ ៩
៣.១ ផលប្រយោជន៍នៃការបែងចែកបទល្មើស ........ ១០
៣.១.១ ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ........ ១០
៣.១.២ ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ........ ១១
៣.១.៣ ផលប្រយោជន៍ទាក់ទិននឹងការកំណត់ពីបទល្មើសប៉ុនប៉ង ........ ១១
៣.១.៤ ការផ្តើមគំនិត និងការសមគំនិត ........ ១១
៣.១.៥ ការបែងចែករវាងបទល្មើសដោយចេតនា និងបទល្មើសដោយអចេតនា ........ ១១
**៤.លក្ខខណ្ឌនៃជនល្មើស** ........ ១៣
**៥.បទល្មើស និងអំពើល្មើសច្បាប់ផ្សេងៗ** ........ ១៣

៥.១ ភាពខុសគ្នានៃបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសរដ្ឋប្បវេណី ........ ១៣
៥.២ បទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកពិន័យ ........ ១៤

## ជំពូកទី២៖
## សញ្ញាណទូទៅនៃអង្គការអយ្យការ

**១. រចនាសម្ព័ន្ធនៃអយ្យការអមសាលាដំបូង** ........ ១៦
១.១ សមាសភាពនៃអយ្យការអមសាលាដំបូង ........ ១៦
១.១.១ ព្រះរាជអាជ្ញា ........ ១៧
១.១.២ ព្រះរាជអាជ្ញារង ........ ១៧
១.១.៣ ក្រឡាបញ្ជី ........ ១៨
**២. សមត្ថកិច្ច តួនាទី ភារកិច្ចនិងសិទ្ធអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង** ........ ១៨
២.១ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ........ ១៨
២.១ តួនាទីរបស់ព្រះរាជអាជ្ញា ........ ១៩
២.២ ភារកិច្ចរបស់ព្រះរាជអាជ្ញា ........ ១៩
២.៣ សិទ្ធអំណាចរបស់ព្រះរាជអាជ្ញា ........ ២០
**៣. គោលការណ៍សំខាន់ៗនៃអង្គការអយ្យការ** ........ ២០
៣.១ គោលការណ៍ឯករាជ្យ ........ ២០
៣.២ គោលការណ៍ឯកភាព (ឬឋានានុក្រម) ........ ២១
៣.៣ គោលការណ៍អវិភាគ( ឬមិនអាចបំបែកបាន) ........ ២២
៣.៤ គោលការណ៍មិនអាចប្តឹងជំទាស់ ........ ២២
៣.៥ គោលការណ៍មិនទទួលខុសត្រូវ ........ ២២
**៤. ទ្រឹស្តីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ** ........ ២៣
៤.១ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ........ ២៣
៤.២ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ........ ២៣

## ជំពូកទី៣៖
## ការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

**១. ការតម្កល់រឿងទុកឥតចាត់ការ** ........ ២៦
១.១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ ........ ២៦

១.១.១ អវត្តមាននៃអត្តសញ្ញាណរបស់ចារី ........ ២៦
១.១.២ អវត្តមាននៃបទល្មើសព្រហ្មទណ្ឌ ........ ២៧
១.១.៣ កង្វះធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ........ ២៧
១.១.៤ មូលហេតុគតិយុត្ត ........ ២៨
១.១.៤.១ ការរលត់បណ្តឹងអាជ្ញា ........ ២៨
ក. មរណៈភាពនៃជនល្មើស ........ ២៨
ខ. ការផុតអាជ្ញាយុកាល ........ ២៩
គ. ការលើកលែងទោសជាទូទៅ ........ ៣០
ឃ. និរាករណ៍ច្បាប់ព្រហ្មទណ្ឌ ........ ៣០
ង. អាជ្ញាអស់ជំនុំ ........ ៣១
ច. ការសម្របសម្រួលជាមួយរដ្ឋ ........ ៣១
ឆ. ការដកពាក្យប្តឹង ........ ៣១
១.១.៥ មូលហេតុគតិយុត្តផ្សេងទៀត ........ ៣២
១.១.៥.១ បុគ្គលមានអភ័យឯកសិទ្ធ ........ ៣២
១.១.៥.២ មោឃៈភាពនៃនីតិវិធី ........ ៣៣
១.១.៥.៣ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ៣៣
១.១.៦ ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញាចំពោះការតម្កល់រឿងទុកឥតចាត់ការ ........ ៣៥
១.២ ការប្តឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ ........ ៣៧
១.២.១ ដីកាតម្កល់រឿងទុកឥតចាត់ការ ........ ៣៧
១.២.២ នីតិវិធីនៃការប្តឹងតវ៉ា ........ ៣៧
១.២.២.១ ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ........ ៣៧
១.២.២.២ ការប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ ៣៨
១.៣ អធិបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ........ ៤១
១.៣.១ លក្ខខណ្ឌនៃការធ្វើអធិបញ្ជា ........ ៤១
១.៣.២ នីតិវិធីនៃការធ្វើអធិបញ្ជា ........ ៤២
**២. ការសម្រេចចោទប្រកាន់** ........ ៤២

២.១ ការបើកការស៊ើបសួរ ............ ៤២
២.១.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ............ ៤៣
២.១.២ លក្ខខណ្ឌនៃការបើកកិច្ចស៊ើបសួរ ............ ៤៤
២.១.៣ នីតិវិធីនៃការបើកការស៊ើបសួរ ............ ៤៤
២.១.៣.១ ការទទួលបានពាក្យប្តឹងដោយផ្ទាល់ ឬពាក្យចចាមរាម ............ ៤៥
២.១.៣.២ ការទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ ............ ៤៥
២.១.៤ អានុភាពនៃកិច្ចស៊ើបសួរ ............ ៤៦
២.១.៥ ការបិទបញ្ចប់កិច្ចស៊ើបសួរ ............ ៤៧
២.២ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ............ ៤៨
២.២.១ លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម ............ ៤៨
២.២.២ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ............ ៤៩
២.២.២.១ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា ............ ៤៩
២.២.២.២ នីតិវិធីក្នុងដំណាក់កាលយុត្តាធិកាជំនុំជម្រះ ............ ៥០
ក. ការបង្វិលសំណុំរឿងទៅព្រះរាជអាជ្ញា ............ ៥០
ខ. ការឃុំខ្លួនជនជាប់ចោទ ............ ៥០
គ. ការប្រកាសសាលក្រមលើអង្គសេចក្តី ............ ៥១
២.២.៣ អានុភាពនៃការចូលបង្ហាញខ្លួនភ្លាម ............ ៥១
២.៣ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៥២
២.៣.១ លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៥២
២.៣.២ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៥៣
២.៣.២.១ លក្ខខណ្ឌទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៥៣
២.៣.២.២ ការប្រគល់ដីកាកោះហៅបញ្ជូនទៅជនុំជម្រះផ្ទាល់ ............ ៥៣
២.៣.៣ អានុភាពនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ............ ៥៤
**សេចក្តីសន្និដ្ឋាន** ............ ៥៧
**អនុសាសន៍** ............ ៦០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

ជាការពិតណាស់នៅក្នុងសង្គមមួយ ដើម្បីឱ្យទទួលបាននូវ ស្ថេរភាព សណ្ដាប់ធ្នាប់របៀបរយ សន្តិសុខសង្គម សុវត្ថិភាព យុត្តិធម៌ តម្លាភាព ភាពកក់ក្ដៅចំពោះប្រជាពលរដ្ឋគ្រប់រូប និងការអភិវឌ្ឍរីកចម្រើន លើគ្រប់វិស័យផ្សេងៗ លុះត្រាតែប្រទេសនោះ ឬសង្គមនោះមាននូវវិធានច្បាប់ និងបទដ្ឋានគតិយុត្តនានា ព្រមទាំងមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាពផងដែរ។ ពិសេសជាងនេះទៅទៀត ដើម្បីបម្រើនិងការពារផលប្រយោជន៍សាធារណៈ វិធានច្បាប់ទាំងនោះត្រូវតែ អនុវត្តដោយត្រឹមត្រូវ មិនលំអៀង និងឈរលើគោលការណ៍គោរព សិទ្ធិមនុស្សជៀសវាងការមិនទទួលបាននូវភាពយុត្តិធម៌ ដូចជាប្រជាពលរដ្ឋក្រីក្រស្លូតត្រង់ជាដើម។ ដូច្នេះត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ ដើម្បីពង្រឹងការអនុវត្តច្បាប់ ដោយមិនលំអៀង និងមិនពុករលួយ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧ មុននិងត្រូវបានរំលេចឡើងជារូបរាង ត្រូវចំណាយពេលអស់ជាង ១០ឆ្នាំ ហើយក្រមនេះត្រូវបានក្លាយជាអត្ថបទច្បាប់ ដ៏ចម្បងនិងជាមធ្យោបាយដ៏សំខាន់របស់តុលាការព្រហ្មទណ្ឌ ក្នុងការអនុវត្តស្របទៅតាមនីតិវិធីជាក់លាក់។ នៅក្នុងក្រមនេះត្រូវបានធ្វើការបែងចែកជា ៤ ដំណាក់កាលសំខាន់ៗដូចជា ៖ ដំណាក់កាលស៊ើបអង្កេត ឬដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលចោទប្រកាន់ ឬដំណាក់កាលអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ នៅក្នុងដំណាក់កាលទី ២ គឺដំណាក់កាលចោទប្រកាន់ ឬហៅម្យ៉ាងទៀតថាដំណាក់កាលអយ្យការ គឺជាដំណាក់កាលមួយដ៏សំខាន់បំផុតនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ មុននិងឈានដល់មាន ដំណាក់កាលស៊ើបសួរនិង ដំណាក់កាលជំនុំជម្រះ ដែលត្រូវបានអនុវត្តដោយស្ថាប័នអយ្យការ ។

អង្គការអយ្យការ ត្រូវបានបង្កើតឡើងដំបូងបង្អស់នៅក្នុងឆ្នាំ ១៩៣៧ ដែលមានចែងនៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ កាលពីសម័យនោះអង្គការអយ្យការអមសាលាដំបូងមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង និងនៅអយ្យការអមសាលាជម្រះក្ដីជាន់ខ្ពស់ មានព្រះរាជបម្រើ និងភូឈួយព្រះរាជបម្រើ។ អង្គការអយ្យការ គឺជាស្ថាប័នដែលនៅអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ ដែលមានតួនាទីចោទប្រកាន់ពីបុគ្គលណាម្នាក់ ហើយបញ្ជូនជនដែលត្រូវបានចោទប្រកាន់នោះ ទៅស្ថាប័នយុត្តាធិការដើម្បីកាត់ក្ដី និងសន្និដ្ឋានដើម្បីឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ អង្គការអយ្យការដែលនៅអមសាលាជម្រះក្ដីជាន់ទាបហៅថា អយ្យការ និងអង្គការអយ្យការដែលនៅអមសាលាជម្រះក្ដីជាន់ខ្ពស់ហៅថា មហាអយ្យការ។ អង្គការអយ្យការ គឺជាស្ថាប័នតំណាងឱ្យអំណាចនីតិប្រតិបត្តិ ក្នុងការការពារផលប្រយោជន៍សាធារណៈ និងសុវត្ថិភាព សណ្ដាប់ធ្នាប់សង្គម តំណាងអយ្យការត្រូវមានវត្តមាននូវគ្រប់សវនាការក្នុងរឿងក្ដីព្រហ្មទណ្ឌ ។

នៅក្នុងប្រធានបទមួយនេះយើងខ្ញុំបានធ្វើការបែងចែកជា៣ជំពូករួមមាន ៖ **ជំពូកទី១ សញ្ញាណនៃបទល្មើស ជំពូកទី២ សញ្ញាណទូទៅនៃអង្គការអយ្យការ** និង**ជំពូកទី៣ ការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**។ នៅក្នុងជំពូកនីមួយៗគឺបានបញ្ជាក់អំពីអត្ថន័យ ខ្លឹមសារនៃប្រធានបទទាំងស្រុង ។

# ជំពូកទី១៖

# សញ្ញាណនៃបទល្មើស

# ជំពូកទី១៖
# សញ្ញាណនៃបទល្មើស

## ១. សញ្ញាណនៃជនល្មើស

ជនល្មើសគឺជាជនដៃដល់នៅក្នុងការប្រព្រឹត្តបទល្មើស មានន័យថា គ្រប់អំពើទាំងអស់ដែលបានចែង ហើយត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ដោយឡែកផ្សេងទៀត និងអាចក្លាយជាកម្មវត្ថុនៃការចោទប្រកាន់ចំពោះអំពើល្មើសនោះបាន ឬគេអាចនិយាយបានម្យ៉ាងទៀតថា ជនល្មើសគឺជាជនទាំងឡាយណា ដែលបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយចេតនា ដោយមានឆន្ទៈត្រូវរូវគ្នា។ អនុលោមតាមមាត្រា២៤ នៃ ក្រមព្រហ្មទណ្ឌបានបញ្ញត្តិថា បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនបណ្ណោះ។[1] មានន័យថាគឺមិនអាចមានបុគ្គលផ្សេង ក្រៅពីបុគ្គលដែលប្រព្រឹត្តអំពើនោះមកទទួលខុសត្រូវជំនួសបានឡើយ ។

ជាក់ស្តែងនៅពេលដែលមានបទល្មើសមួយកើតឡើង គឺអាចមានជនល្មើសប្រព្រឹត្តិម្នាក់ឯង ឬច្រើននាក់ដោយមានការព្រមព្រៀងគ្នាក្នុងការប្រព្រឹត្តបទល្មើស។ បទល្មើសដែលបានប្រព្រឹត្តដោយបុគ្គលច្រើននាក់អាចក្រោមរូបភាពជាក្រុមមានការចាត់តាំង ដែលប្រមូលផ្តុំឡើងដើម្បីត្រៀមរៀបចំប្រព្រឹត្តបទល្មើសមួយ ឬច្រើន។ ជនល្មើសដែលបានចូលរួមប្រព្រឹត្តបទល្មើសអាចចូលរួមដោយផ្ទាល់ ឬដោយប្រយោល។

### ១.១ ជនល្មើសដែលចូលរួមដោយផ្ទាល់

#### ១.១.១ ចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។[2] ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម។ ចារី នៃបទល្មើស គឺជាជនដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬ ជនដែលបាន ប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬអាចហៅម្យ៉ាងទៀតថាជាជនដៃដល់។ ចារី ត្រូវបានច្បាប់ចាត់ទុកថាជា អ្នកដែលមានតួនាទីសំខាន់នៅក្នុងបទល្មើស។ ព្រោះប្រសិនបើគ្មានអំពីល្មើសរបស់ចារីទេ នោះក៏គ្មានបទល្មើសកើតឡើងដែរ។ ឧទាហរណ៍៖ លោក ក បានវ៉ៃលោក ខ មួយដំបង បណ្តាយឱ្យបែកក្បាល ។ ដូចនេះលោក ក គឺជាចារី។

[1] មាត្រា២៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[2] មាត្រា២៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

#### ១.១.២ សហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។[3] ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀង ប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។ សហចារីនៃបទល្មើស គឺជាជនដែលបានចូលរួម និងមានសកម្មភាពប្រព្រឹត្តអំពើល្មើសដោយផ្ទាល់ជាមួយចារី ហើយស្ថិតក្នុងកាលៈទេសៈ និងទីកន្លែងតែមួយជាមួយចារី។ ឧទារហណ៍៖ លោក ក,ខ,គ បានព្រមព្រៀងគ្នាក្នុងការធ្វើសម្មភាពដោយផ្ទាល់ទៅលួចម៉ូតូមួយគ្រឿង នៅក្នុងហាងមួយកន្លែង ។ ដូចនេះលោក ក,ខ,គ ត្រូវបានសន្មត់ថាជាសហចារី ក្នុងបទលួច ។

### ១.២ ជនល្មើសចូលរួមដោយប្រយោល

#### ១.២.១ អ្នកផ្ដើមគំនិត

ជាជនត្រូវចាត់ទុកថាជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល៖

- ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា ។
- បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។[4] ក្នុងន័យនេះ អ្នកផ្ដើមគំនិត ឬចារីបញ្ញា គឺជាអ្នកដែលចាប់ផ្ដើមគំនិត ការគិតទុច្ចរិតណែនាំ បញ្ជា ញុះញង់ និងគំរាមកំហែង ឬជាការលួងលោមអោយប្រព្រឹត្តបទល្មើសជាដើម។ អំពើទាំងនេះ អាចត្រូវបានធ្វើឡើងដោយផ្ទាល់ក្ដី ឬតាមសម្ភារៈអេឡិចត្រូនិចក្ដី ក៏ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិត ហើយនឹងត្រូវទទួលទោសដូចគ្នា ទៅនឹងចារីផងដែរ។ ឧទាហរណ៍៖ លោក ក មានគំនុំជាមួយលោក ខ ដោយសារការរកស៊ីហេតុនេះ លោកកបានបញ្ជាលោកគ ដែលជាកូនចៅរបស់ខ្លួនទៅសម្លាប់លោកខ ហើយពេលសម្លាប់រួចបានសន្យាថានិងឱ្យលុយមួយចំនួន ។ ហេតុនេះលោក ក គឺជាអ្នកផ្ដើមគំនិត ។

#### ១.២.២ អ្នកសមគំនិត

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួល ដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចនូវបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។[5] អ្នកសមគំនិត គឺជាអ្នកដែលជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសអោយកើតមានឡើង តាមរយៈនៃការ ផ្ដល់ជាជំនួយ ការឧបត្ថម្ភជាសម្ភារៈ ឬមធ្យោបាយផ្សេងៗ។ បានន័យថាអ្នកសមគំនិត គឺមិនបានចូលរួមប្រព្រឹត្ត បទ

---

[3] មាត្រា២៦ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[4] មាត្រា២៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[5] មាត្រា២៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ល្មើសដោយផ្ទាល់ទេ តែជាអ្នកដែលបានដឹងលឺនិងជាចំណែកមួយដើម្បីសម្រួលឱ្យមានភាពងាយស្រួលដល់ការប្រព្រឹត្តនូវបទល្មើស។ ទោះបីអ្នកសមគំនិតមិនបានចូលរួមប្រព្រឹត្តបទល្មើសដោយផ្ទាល់ ក៏ច្បាប់បានកំណត់ផ្តន្ទាទោសដូចគ្នានឹងចារីដែរ។ ឧទាហរណ៍៖ លោក ក បានឱ្យលោក ខ ខ្ចីកាំបិទ ទាំងដែលដឹងក្នុងចិត្តច្បាស់ថាលោក ខ គឺមានគោលបំណងយកកាំបិតនោះទៅសម្លាប់មនុស្ស ។

អ្នកផ្តើមគំនិត និងអ្នកសមគំនិតត្រូវផ្តល់ទ្នាទោសដូចនិងចារីផងដែរ កាលបើបទល្មើសជាបទមជ្ឈឹម ឬបទឧក្រិដ្ឋ បានសម្រេច ឬប៉ុនប៉ង។

## ២. អត្ថន័យនៃបទល្មើស

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ត្រង់មាត្រា២បានចែងថា ច្បាប់បញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កចលាចលដល់សង្គមជាបទល្មើស។ មានន័យថាបទល្មើសព្រហ្មទណ្ឌ គឺជាអំពើប្រព្រឹត្តដោយចេតនា ឬអចេតនាដែលបង្កគ្រោះថ្នាក់ដល់សង្គម ហើយត្រូវបានផ្តន្ទាទោសតាមកាលកំណត់ទុកជាមុននៃច្បាប់ព្រហ្មទណ្ឌ។ ហើយគេអាចនិយាយម្យ៉ាងទៀតថា អំពើបំពានច្បាប់ព្រហ្មទណ្ឌ។ ដោយឡែកបទល្មើសអាចត្រូវបានគេចាត់ទុកថា ជាបាតុភូតអសកម្មនៅក្នុងជីវភាពរស់នៅផងដែរ ពីព្រោះបទល្មើសបានជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់សង្គម និងសេរីភាពរបស់ ប្រជាពលរដ្ឋ។ ម្យ៉ាងទៀត គេអាចចាត់ទុកអំពើមួយជាបទល្មើសបាន លុះត្រាតែអំពើនោះធ្វើឱ្យប៉ះពាល់ដល់សង្គមដែលច្បាប់បានការពារ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបង្កឱ្យមានព្យសនកម្មសម្រាប់សង្គម ហើយមានចែងយ៉ាងជាក់លាក់ក្នុងច្បាប់ថាជាបទល្មើស។ យ៉ាងណាមិញមិនមែនមានតែបទល្មើសព្រហ្មទណ្ឌទេដែលបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម គឺមានបទល្មើសមួយចំនួនទៀតដែលបង្កឱ្យមានគ្រោះថ្នាក់ដែរ គឺគេហៅថា កំហុសរដ្ឋប្បវេណី (បទល្មើសរដ្ឋប្បវេណី) ដែលតម្រូវឱ្យចារីត្រូវដាក់ទណ្ឌកម្មឱ្យបង់ជាសំណង និងជម្ងឺចិត្តតែប៉ុណ្ណោះដោយមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌនោះឡើយ។ ហេតុនេះហើយទើបតម្រូវឱ្យ មានការចាំបាច់ត្រូវតែពិនិត្យមើល ពីភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងបទល្មើសដទៃទៀត។

### ២.១ ធាតុផ្សំបទល្មើស

យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងនៅត្រង់មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។ មានន័យថាអ្នកណាប្រព្រឹត្តអ្នកនោះទទួល គឺមិនអាចតម្រូវឱ្យមានបុគ្គលផ្សេងក្រៅពីបុគ្គលដែលប្រព្រឹត្តអំពើនោះ មកទទួល

ខុសត្រូវព្រហ្មទណ្ឌជំនួសខ្លួនបានឡើយ ដែលខុសពីទណ្ឌកម្មរដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យបុគ្គលផ្សេងទៀតទទួលខុសត្រូវជំនួសខ្លួនបាន [6]។

ដើម្បីសន្និដ្ឋានថាអំពើណាមួយជាបទល្មើសបាន តម្រូវឱ្យបំពេញនូវធាតុផ្សំទាំងបីដូចជា ៖ ធាតុនីត្យានុកូល ធាតុសន្យានុម័ត និងធាតុអត្តនោម័ត ។

### ២.១.១ ធាតុនីត្យានុកូល

ធាតុនីត្យានុកូល ឬធាតុច្បាប់ មានន័យថាត្រូវមានច្បាប់ណាមួយចែងយ៉ាងជាក់លាក់ថាអំពើនោះគឺជាបទល្មើសដែលត្រូវផ្តន្ទាទោស។ ធាតុនីត្យានុកូលនេះត្រូវបានបែងចែកជាពីររួមមាន នីត្យានុកូលភាពនៃបទល្មើស និងនីត្យានុកូលភាពនៃទោស។

**នីត្យានុកូលភាពនៃបទល្មើស៖** អនុលោមតាមមាត្រា៣ នៃក្រមព្រហ្មទណ្ឌត្រង់កថាខណ្ឌទី១ បានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌ ជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន [7]។ មានន័យថា រាល់អំពើដែលជាបទល្មើសត្រូវបានច្បាប់ព្រហ្មទណ្ឌចែងទុកជាមុន ហើយអំពើដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់គឺ ត្រូវចាត់ទុកថាមានទោស។ ឧទាហរណ៍ ៖ បទឃាតកម្មគិតទុកជាមុន គឺមានចែងក្នុងមាត្រា២០០ នៃក្រមព្រហ្មទណ្ឌត្រូវចាត់ទុកថា ជាបទល្មើសហើយត្រូវផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត ។

**នីត្យានុកូលភាពនៃទោស៖** យោងតាមមាត្រា៣ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌដែលបានចែងថា មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន។ មានន័យថាដើម្បីអាច ប្រកាសអំពីទោសដែលមានចែងនៅក្នុង ក្រមព្រហ្មទណ្ឌ គឺទាមទារឱ្យមានការប្រព្រឹត្តអំពើដែលជាបទល្មើសជាមុនសិន ទើបទោសនោះអាចត្រូវ ប្រកាសបាន ។ ឧទាហរណ៍៖ បទហិង្សាដោយចេតនា ដែលមានកំណត់ក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា ២១៧ ក្នុងករណីនេះប្រសិនបើបុគ្គលណាម្នាក់បានប្រព្រឹត្តអំពើហិង្សា ដោយចេតនាលើអ្នកដ៏ទៃ នោះនិងត្រូវតុលាការប្រកាសអំពីទោសជាមិនខាន ។

### ២.១.២ ធាតុសន្យានុម័ត

ធាតុសន្យានុម័ត ឬធាតុសម្ភារៈ សំដៅទៅលើអំពើដែលជនល្មើសបានប្រព្រឹត្តបទល្មើសស្តែងចេញមកខាងក្រៅ តាមរយៈអំពើបង្កគ្រោះថ្នាក់ដល់សង្គម ឬបច្ច័យគ្រោះថ្នាក់ដល់សង្គម (ការអន្តរាយ) ដោយមានទំនាក់ទំនងហេតុផលរវាងអំពើ និងបច្ច័យដែលកើតមានឡើងដោយសារតែអំពើនោះ។ នៅក្នុងចំណុចធាតុ

[6] មេរៀននីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ លោកសាស្ត្រចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

[7] មាត្រា៣ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

សន្យានុម័តនេះគឺរួមមានចំណុចមួយចំនួនដែលត្រូវលើកយកមកបកស្រាយមានដូចជា៖ អំពើ ព្យាសនៈកម្ម និង ទំនាក់ទំនងហេតុ និងផល ។

**អំពើ៖** គឺជាកាយវិការសម្តែងចេញមកខាងក្រៅ ដែលអាចមើលឃើញក្រោមរូបភាពជាក់ស្តែង ដើម្បីសម្រេចនៅបំណងដែលមានគោលដៅនឹងសេចក្តីប៉ងប្រាថ្នាចង់បាន ដែលអាចជាការរំលោភបំពានទៅលើបុគ្គល ទ្រព្យសម្បត្តិ ឬសង្គមជាតិ។ អំពើត្រូវបានបែងចែកជាពីរគឺ អំពើសកម្ម និងអំពើអកម្ម ។

**អំពើសកម្ម ៖** គឺជាអំពើដែលស្តែងចេញពីសកម្មភាពនៃកាយវិការរបស់ចារី មានន័យថា ចារីបានប្រព្រឹត្តអំពើស្តែងចេញជាក់ស្តែង ដែលអ្នកណាក៏អាចមើលឃើញថាបុគ្គលនោះបានប្រព្រឹត្តបទល្មើសដែរ។ ឧទាហរណ៍ ៖ ករណីបទឃាតកម្ម មានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ គឺនៅពេលដែលជនណាម្នាក់ទៅផ្តាច់ជីវិតរបស់ជនម្នាក់ទៀត នេះគឺបានបង្ហាញនៅសកម្មភាពជាសត្យានុម័តមកខាងក្រៅ ដែលបញ្ជាក់ថាជននោះបានប្រព្រឹត្តអំពើ។

**អំពើអកម្ម៖** ជាអំពើដែលជនណាម្នាក់មិនព្រមធ្វើតាមការកំណត់ជាកាតួកិច្ចដែលច្បាប់តម្រូវឱ្យធ្វើ។ អំពើនោះគឺទាល់តែ ច្បាប់ចែងយ៉ាងជាក់លាក់ថាជា កាតព្វកិច្ចណាខ្លះដែលបុគ្គលគ្រប់រូបក្នុងសង្គម ឬក៏បុគ្គលណាខ្លះត្រូវបំពេញ ហើយនៅពេលដែលមិនបំពេញតាមការកំណត់ទេ បុគ្គលនោះនឹង ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌមិនខាន។ ឧទាហរណ៍៖ បទមិនប្តឹងបរិហារការធ្វើបាបអនីតិជន ដែលមានចែងក្នុងមាត្រា ៥៣០ នៃក្រមព្រហ្មទណ្ឌ ។

### ២.១.៣ ធាតុអត្តនោម័ត

ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ គឺចង់សំដៅលើផ្នែកខាងក្នុងរបស់ជនល្មើស ឬសភាពផ្លូវចិត្ត។ ក្រមព្រហ្មទណ្ឌបានសម្រេចអនុម័តយក សភាពផ្លូវចិត្តរបស់ជនល្មើសជាមូលដ្ឋានក្នុងការកំណត់ទណ្ឌកម្ម មានន័យថា ច្បាប់ធ្វើការផ្តន្ទាទោសទៅតាមចេតនាប្រព្រឹត្តបទល្មើស។

គោលការណ៍បទល្មើសកើតចេញពីឆន្ទៈ ឬចេតនាប្រព្រឹត្តបទល្មើស ប៉ុន្តែក្នុងករណីមួយចំនួនបទល្មើសក៏អាចកើតឡើងដោយអចេតនាផងដែរ។ ហេតុដូច្នេះទើបច្បាប់បែងចែកកំហុសជាពីរគឺ កំហុសចេតនា និង កំហុសអចេតនា ។

**កំហុសចេតនា៖** ជាកំហុសរបស់បុគ្គលដែលមានបំណង ឬឆន្ទៈក្នុងការប្រព្រឹត្តបទល្មើសណាមួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌមាត្រា ៤ ថាពុំមានបទល្មើសទេ បើគ្មានចេតនាប្រព្រឹត្ត ។ ចេតនាប្រព្រឹត្តបទល្មើសសំដៅទៅលើឆន្ទៈក្នុងការប្រព្រឹត្តបទល្មើសរបស់ចារី ដែលមានបំណងចង់ឱ្យមានបទល្មើសកើតមានឡើង ។

**កំហុសអចេតនា៖** គឺជាកំហុសដែលកើតមានឡើងអំពីការដែលមិនអាចគ្រប់គ្រងនូវឆន្ទៈរបស់ខ្លួនបាន មានន័យថា ចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួនក៏ប៉ុន្តែចារីគឺពិតជាពុំមានឆន្ទៈ ឬ ពុំបានដឹងអំពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ ។ យោងតាមក្រមព្រហ្មទណ្ឌមាត្រា ៤ ចែងថាពុំមានបទល្មើសទេបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់ចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ [8]។

មានន័យថាចារី អាចព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផល តាមរយៈការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចណាមួយ ។

## ៣. ចំណាត់ថ្នាក់បទល្មើស

ជាទូទៅនៅក្នុងសង្គមគេសង្កេតឃើញថាមានបទល្មើសច្រើនប្រភេទដែលរាប់មិនអស់ ហើយច្បាប់ដែលកំណត់ពីបទល្មើស ក៏មានច្រើនដែលមិនអនុញ្ញាតឱ្យរៀបរាប់អស់បានដែរ ។ ដូច្នេះដើម្បីស្គាល់បាននូវបទល្មើសនីមួយៗ គម្បីត្រូវតែធ្វើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ក្នុងគោលដៅសម្រួលដល់ការកំណត់ និងស្គាល់នូវរបបគតិយុត្ត ជាបណ្ដាលវិធានច្បាប់ពាក់ព័ន្ធ នឹងវិស័យណាមួយដែលត្រូវយកមកអនុវត្ត សម្រាប់អនុវត្តចំពោះបទល្មើសណាមួយ ។

នេះគឺជាចំណាត់ថ្នាក់នៃបទល្មើសតែមួយគត់ ដែលមានចែងយ៉ាងជាក់លាក់នៅក្នុង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាគឺមាត្រា២ វាក្យខណ្ឌទី២ ដែលចែងថាបទល្មើស ត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់បទល្មើស។ [9] ការបែងចែកបទល្មើសជាបីប្រភេទ តាមលក្ខណៈធ្ងន់ធ្ងរនៃបទល្មើសមានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថាការបែងចែកនាំមកនូវផលប្រយោជន៍ទាក់ទងនឹងរបបគតិយុត្តដែលច្បាប់មែងភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើស។ [10]

ដើម្បីអាចដឹងពីប្រភេទនៃបទល្មើស គេត្រូវពិនិត្យទៅលើអតិបរមានៃទោសដែលច្បាប់ បានចែងទៅលើបទល្មើសនីមួយៗ។

**បទល្មើសជាបទឧក្រិដ្ឋ៖** នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវវងជា ៖

- ទោសដាក់ពន្ធនាគារអស់មួយជីវិត ។

[8] មាត្រា៤ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

[9] មាត្រា២ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩។

[10] មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយ ឯ.ឧ ហ៊ី សោភា ឯ.ឧ ប៊ុន ហ៊ុន ឯ.ឧ កើត រិទ្ធ ឯ.ឧ ផូវ សំភី និង លោកស្រី ចាំង ស៊ីណាត។

- ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និង ក្រោម ឬស្មើ ៣០ឆ្នាំ (មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ)។ ឧទាហរណ៍៖ ឃាតកម្មគិតទុកជាមុន រំលោភសេពសន្ថវៈ អំពើលួចដោយស្ថានទម្ងន់ទោស ។

**បទល្មើសជាបទមជ្ឈិម៖** នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬស្មើនិង ៥ ឆ្នាំ ។ ( មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ) ឧទាហរណ៍ ៖ ហិង្សាដោយចេតនា ធ្វើឱ្យខូចខាតដោយចេតនា ប្រើប្រាស់អាវុធដោយខុសច្បាប់ជាអាទិ៍ ។

**បទល្មើសជាបទលហុ៖** នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមាន រយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ ឬក៏បទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ (មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ)។ ឧទាហរណ៍ ៖ បើកបរដោយមិនពាក់ខ្សែក្រវាត់ការពារ ឬពាក់មួកការពារសុវត្ថិភាព បើកបរហួសល្បឿនកំណត់ (មាត្រា ៨៨ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក)។

## ៣.១ ផលប្រយោជន៍នៃការបែងចែកបទល្មើស

ការបែងចែកជាបទល្មើសទាំងបីប្រភេទខាងលើមានផលប្រយោជន៍ជាច្រើន ដែលច្បាប់បានកំណត់ ហើយផលប្រយោជន៍សំខាន់ៗមានដូចជា ៖

### ៣.១.១ ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល

អាជ្ញាយុកាលជារយៈពេលមួយកំណត់ដោយច្បាប់ ដែលផុតរយៈពេលនេះបុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយ ជាប្រយោជន៍ដល់ខ្លួនឯង ។ ក្នុងច្បាប់ព្រហ្មទណ្ឌ អាជ្ញាយុកាលមាន ពីរប្រភេទគឺ អាជ្ញាយុកាលនៃបទល្មើស (អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា) និងអាជ្ញាយុកាលនៃទោស។

- **អាជ្ញាយុកាលនៃបទល្មើស ៖** ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថាព្រះរាជអាជ្ញាពុំអាចធ្វើបណ្តឹងអាជ្ញាបានឡើយ។ អាជ្ញាយុកាលប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស [11]។ មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៩ ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម នៃក្រមនេះ ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅគឺៈ
    - ១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ
    - ៥ឆ្នាំ ចំពោះបទមជ្ឈិម និង

[11] មាត្រា១០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

- ១ឆ្នាំ ចំពោះបទលហុ។ ជាគោលការណ៍អាជ្ញាយុកាលនៃបទល្មើសចាប់ផ្តើមរាប់ពីពេលប្រព្រឹត្តបទល្មើសទៅ។

- **អាជ្ញាយុកាលនៃទោស៖** ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសលែងអាចអនុវត្តបានទៀតហើយ។ ក្រមព្រហ្មទណ្ឌកំណត់រយៈពេលអាជ្ញាយុកាលនៃទោសដូចតទៅ (មាត្រា ១៤៤ នៃក្រមព្រហ្មទណ្ឌ) អាជ្ញាយុកាលនៃទោសរួមមាន[12]៖
  - ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ឆ្នាំ ។
  - ទោសដែលប្រកាសពីបទមជ្ឈឹមមានអាជ្ញាយុកាល ៥ឆ្នាំ ។
  - ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ឆ្នាំ ។

### ៣.១.២ ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី

នៅក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិប្បញ្ញត្តិខ្មែរកំណត់នូវគោលការណ៍មួយចំនួនដោយផ្អែកលើប្រភេទនៃបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈឹម។ ឧទាហរណ៍៖ ក្នុងករណីជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរតាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប្រសិនបើជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះ ដោយផ្ទាល់តាមមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣.១.៣ ផលប្រយោជន៍ទាក់ទិននឹងការកំណត់ពីបទល្មើសប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវមានទោស។ ការប៉ុនប៉ងប្រព្រឹត្តបទល្មើសមជ្ឈិមមានទោសតែក្នុងករណីដែលច្បាប់ទុកថាការប៉ុនប៉ងមានទោស។ រីឯការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ (មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ)។

### ៣.១.៤ ការផ្តើមគំនិត និងការសមគំនិត

ការផ្តើមគំនិត ឬការសមគំនិតដែលបំពេញលក្ខខណ្ឌច្បាប់កំណត់ក្នុងការប្រព្រឹត្តបទល្មើសឧក្រិដ្ឋឬមជ្ឈិមសុទ្ធសឹងតែមានទោស។ ប៉ុន្តែការសមគំនិតក្នុងបទលហុពុំអាចមានទោសទេ លើកលែងតែច្បាប់ ចែងយ៉ាងច្បាស់លាស់ថាយ៉ាងដូច្នេះ (មាត្រា២៨.២៩ នៃក្រមព្រហ្មទណ្ឌ)។

### ៣.១.៥ ការបែងចែករវាងបទល្មើសដោយចេតនា និងបទល្មើសដោយអចេតនា

ជាគោលការណ៍ ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត មាត្រា ៤ នៃ ក្រមព្រហ្មទណ្ឌ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើត ចេញពីការមិនប្រុងប្រយ័ត្នការខ្ជីខ្ជា ការធ្វេស

[12] មាត្រា១៤៤ សក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ។ ក្នុងករណីនេះ គោរប់បញ្ចូលថាជាបទល្មើសដោយអចេតនា។

**បទល្មើសដោយចេតនា៖** ជាបទល្មើសដែលចារីមានបំណងប្រព្រឹត្ត។ ឧទាហរណ៍ ៖ ចោរមានចេតនាយកអាវុធអ្នកដទៃ មានន័យថាបំណងយកទ្រព្យរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។ ឃាតករ រមែងមានបំណងធ្វើឲ្យជនរងគ្រោះស្លាប់បាត់បង់ជីវិត។

**បទល្មើសដោយអចេតនា៖** ជាបទល្មើសដែលកើតឡើងទោះជាចារី ពុំមានបំណងប្រព្រឹត្តក៏ដោយ ។ ចំពោះបទល្មើសដោយអចេតនា ភាពសុចរិតរបស់ចារីពុំមែនជាធាតុផ្សំបទល្មើសទេ បានសេចក្តីថា ទោះបីជាចារីពុំមានបំណងទុច្ចរិតក៏ដោយ ក៏នៅតែមានបទល្មើសកើតឡើងបានដដែល។

ឧទាហរណ៍ ៖ មនុស្សឃាតដោយអចតនា បើកបរដោយបង្កឲ្យស្លាប់ដល់អ្នកដទៃដោយអចេតនា បើកបរបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនាជាដើម ។

ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌមិនត្រឹមតែដាក់ទោសការប្រព្រឹត្តបទល្មើសបានសម្រេចផលនោះទេ ថែមទាំងដាក់ទោសលើការប៉ុនប៉ងប្រព្រឹត្តបទល្មើសផងដែរ កាលបើលក្ខខណ្ឌនៃការប៉ុនប៉ងត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។

## ៤. លក្ខខណ្ឌនៃជនល្មើស

លក្ខខណ្ឌនៃជនល្មើស គឺសំដៅទៅលើលក្ខខណ្ឌដែលច្បាប់បានកំណត់ ចំពោះជនល្មើសដើម្បីអាចប្រកាសទណ្ឌកម្មទៅលើបុគ្គលនោះបាន។ ការប្រកាសទណ្ឌកម្មគឺមានលក្ខណៈ និងលក្ខខណ្ឌខុសគ្នាទៅតាមប្រភេទបុគ្គល និងប្រភេទគតិយុត្តជនល្មើសដែលបានចូលរួមប្រព្រឹត្តបទល្មើស។

**មនុស្ស៖** គឺជារូបវន្តបុគ្គល មានរូបរាង មានសាច់ឈាម មានជីវិតហើយដែលផ្ទុយពីនីតិបុគ្គល ។ មនុស្សម្នាក់ដែលបានប្រព្រឹត្តអំពើបង្កការអន្តរាយដល់សង្គម ហើយដែលច្បាប់ព្រហ្មទណ្ឌដែលបានបញ្ញត្តថាជាបទល្មើស នោះគេនិងក្លាយទៅជាប្រធាននៃបទល្មើស ប្រសិនបើជននោះមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ហើយឈានដល់កម្រិតអាយុទទួលខុសត្រូវព្រហ្មទណ្ឌតាមច្បាប់កំណត់។

**កំពុងមានជីវិត៖** ចង់មានន័យថា គឺជាមនុស្សដែលកំពុងមានជីវិតរស់នៅ ចំពោះមនុសដែលស្លាប់ ឬសត្វពុំអាចក្លាយជាប្រធាននៃបទល្មើសបានឡើយ។ រដ្ឋពុំអាចធ្វើការចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌចំពោះមនុស្សដែលបានស្លាប់ទៅហើយ ទោះបីជាក្នុងករណីនៅមុនពេលដែលស្លាប់នោះ ជននោះបានប្រព្រឹត្តនូវអំពើបង្កឱ្យមានការអន្តរាយធំធេងយ៉ាងណាដល់សង្គម និងសមាជិកសង្គមក៏ដោយ។

**សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ៖** គឺជាលទ្ធភាពរបស់មនុស្ស នៅពេលដែលប្រព្រឹត្តអំពើបង្ករគ្រោះថ្នាក់ដល់សង្គម ជននោះយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួនហើយអាចបញ្ជាបាននូវអំពើនោះ។

មនុស្សម្នាក់ត្រូវចាត់ទុកថាមានសម្ថភាពក្នុងកាទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនពេលប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គមនោះបានឈានដល់កំរិតអាយុទទួលខុសត្រូវព្រហ្មទណ្ឌ តាមបញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ ហើយជននោះពុំស្ថិតនៅក្នុងករណី គ្មានសម្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ ។ ក្នុងរណីនេះបើទោះបីជាមានអំពើផ្ទុយច្បាប់ព្រហ្មទណ្ឌដែលប្រព្រឹត្តឡើងដោយបុគ្គលអសម្ថភាពក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏ពុំមែនជាបទល្មើសនោះដែរ ។

**អាយុតាមការកំណត់របស់ច្បាប់៖** អនុលោមតាមមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានបញ្ញត្តថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ។ ហេតុនេះបុគ្គលដែលមានអាយុចាប់ពី១៨ឡើងទៅគឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងពេញលេញ ទៅលើអំពើដែលខ្លួនបានប្រព្រឹត្តដែលមិនអាចមានបុគ្គលណាផ្សេងមកទទួលជំនួសខ្លួនបានឡើយ ។ បន្តែចំពោះអនីតិជនដែលមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ តុលាការក៏អាចប្រកាសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ កាលណាបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិតលក្ខណៈតម្រូវ ។

## ៥.បទល្មើស និងអំពើល្មើសច្បាប់ផ្សេងៗ

បទល្មើសគឺជាប្រភេទមួយក្នុងចំណោមបណ្តាអំពើល្មើសច្បាប់ដូចនេះយើងអាចមានការ ភាន់ច្រឡំខ្លះ ក្នុងការកំណត់ព្រំដែននៃបទល្មើសផ្សេងទៀត ជាពិសេសក្នុងដំណាក់ដែលការកំណត់របស់ច្បាប់ ពុំទាន់ច្បាស់លាស់នូវវិធាននៃទណ្ឌកម្ម និងព្រំដែននៃទណ្ឌកម្ម នៃអំពើល្មើសផ្សេងទៀតជាមួយទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ។

### ៥.១ ភាពខុសគ្នានៃបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសរដ្ឋប្បវេណី

បទល្មើសព្រហ្មទណ្ឌវិញ ត្រូវតែជាអំពើដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ថា ជាបទល្មើសព្រហ្មទណ្ឌ។ សម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណីវិញ ព្យសនកម្មជាកត្តាចាំបាច់ដើម្បីអាចឲ្យចៅក្រមដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តបាន។ ផ្ទុយទៅវិញការបង្កើតជាបទល្មើសព្រហ្មទណ្ឌ ពុំសុទ្ធតែទាមទារឲ្យមានព្យសនកម្មដូចជា ៖ បទល្មើសជួញដូរគ្រឿងញៀន ការបើកបរលឿនខុសច្បាប់ជាដើម ។

ការបង់សំណងជំងឺចិត្តជាទណ្ឌកម្មសម្រាប់អំពើល្មើសរដ្ឋប្បវេណី និងជាទណ្ឌកម្មដែលផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ។ ប៉ុន្តែទោសដែលជាទណ្ឌកម្មព្រហ្មទណ្ឌ និងមានគោលដៅការពារសង្គម មិនត្រូវបានជាប្រយោជន៍ដល់ជនរងគ្រោះទេ។ ប្រាក់ពិន័យគឺជាចំណូលថវិការបស់រដ្ឋ រីឯប្រាក់សំណងជំងឺចិត្តត្រូវបានទៅជនរងគ្រោះ។

អំពើមួយអាចជាបទល្មើសព្រហ្មទណ្ឌ តែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេ ដូចជា ការល្មើសដោយពុំព្រមឈប់ពេលភ្លើងក្រហម ការរត់ពន្ធគ្រឿងញៀនជាដើម។ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គង ប៉ុន្តែពុំមែនជាបទល្មើសទេ ។ ឧទាហរណ៍ ៖ ការធ្វើឲ្យខូចខាតទ្រព្យរបស់អ្នកដទៃដោយអចេតនា។

ផ្ទុយទៅវិញ អំពើមួយអាចត្រូវបានទុកថាជាបទល្មើសព្រហ្មទណ្ឌផង អំពើល្មើសផ្នែករដ្ឋប្បវេណីផងដែរ ដូចជាអំពើឃាតកម្ម ឬអំពើហឹង្សាដោយចេតនាដល់តតិយជនជាដើម។ ក្នុងករណីបែបនេះ អំពើល្មើសនាំឲ្យមានបណ្តឹងពីរប្រភេទគឺ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី។[13]

## ៥.២ បទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកពិន័យ

អំពើល្មើស ផ្នែកវិន័យជាអំពើធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍សមូហភាពនៃក្រុមសង្គមណាមួយ ដូចជា ពេទ្យ មេធាវី និស្សិតជាដើម ដោយអំពើនោះមិនត្រូវបានកំណត់ឲ្យច្បាស់លាស់ជាទូទៅទេ ។ ឧទាហរណ៍ ៖ មាត្រា៥៩ នៃច្បាប់ស្តីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី២២ខែសីហាឆ្នាំ១៩៩៥ ចែងថា ត្រូវទទួលទណ្ឌកម្មជាបទវិន័យចំពោះមេធាវីណាដែលប្រព្រឹត្តល្មើស នឹងវិធានវិជ្ជជីវៈ ប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ។ ការកំណត់យ៉ាងដូច្នេះបង្ហាញឲ្យឃើញថា អំពើល្មើសផ្នែកវិន័យសម្រាប់វិជ្ជាជីវៈមេធាវី ពុំត្រូវបានបញ្ជាក់ឱ្យច្បាស់ជាមុនដូចក្នុងបទល្មើសព្រហ្មទណ្ឌទេ ព្រោះថាអំពើប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ជាសញ្ញាមួយទូលំទូលាយណាស់។

ផ្ទុយទៅវិញបទល្មើសព្រហ្មទណ្ឌទោះបីជាមានច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធសឹងជាអំពើដែលច្បាប់បានកំណត់យ៉ាងច្បាស់លាស់ជាមុនរួចស្រេចអស់ ហើយអំពើណាដែលច្បាប់ពុំបានចែងថាជាបទល្មើសព្រហ្មទណ្ឌទេ ពុំអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយ ផ្អែកតាមគោលការណ៍ នីត្យានុកូលភាពនៃបទល្មើស។ អំពើល្មើសផ្នែកវិន័យធ្វើឲ្យប៉ះពាល់តែផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ ។ ប៉ុន្តែបទល្មើសព្រហ្មទណ្ឌវិញជាអំពើដែល ប៉ះពាល់ដល់សង្គម ជាទូទៅ ។

ការដាក់ទណ្ឌកម្មលើអំពើល្មើសខាង វិន័យត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ ដូចជាក្រុមប្រឹក្សាមេធាវីសម្រាប់ការដាក់វិន័យលើមេធាវី ឬឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់ ការដាក់វិន័យចៅក្រមជាដើម ។ ចំណែកឯការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌវិញ សមត្ថកិច្ចរបស់សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានលក្ខណៈធ្ងន់ធ្ងរ រហូតដល់ការដាក់ពន្ធនាគារ អស់មួយជីវិតទៀតផង។

ប៉ុន្តែអំពើមួយចំនួនត្រូវចាត់ចូលជាអំពើល្មើសផ្នែកវិន័យផងនិងជាបទល្មើសព្រហ្មទណ្ឌផង ដូចជាឃាតកម្មប្រព្រឹត្តដោយវេជ្ជបណ្ឌិតម្នាក់ទៅលើអតិថិជនរបស់ខ្លួន ឬការរំលូតកូនដោយល្មើសនិងច្បាប់ស្តីពីការរំលូតកូន។ល។

[13] មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយ ឯ.ឧ ហ៊ី សោភា ឯ.ឧ ប៊ុន ហ៊ុន ឯ.ឧ កើត រិទ្ធ ឯ.ឧ ផូវ សំភី និង លោកស្រី ចាំង ស៊ីណាត។

# ជំពូកទី២៖

# សញ្ញាណទូទៅនៃអង្គការអយ្យការ

# ជំពូកទី២៖

# សញ្ញាណទូទៅនៃអង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយដែលនៅដាច់ដោយឡែកពីតុលាការ ថ្វីត្បិតតែស្ថាប័ននេះ នៅក្នុងបរិវេណតុលាការក៏ពិតមែនតែ ស្ថាប័នអយ្យការនេះមានអ្នកដឹកនាំដោយឡែកផ្សេង ពីតុលាការ។ អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តខាងសេចក្តីសម្រេច ខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់ លើការផ្សព្វផ្សាយដីការបង្គាប់ឱ្យចាប់ខ្លួន។ បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមប្រយោជន៍ទូទៅ ដោយអយ្យការ ក្នុងនោះបណ្តឹងរបស់ជនរងគ្រោះ ឬ បុគ្គលផ្សេងទៀត មានតម្លៃគ្រាន់តែជាបណ្តឹងសាមញ្ញ គ្មានអនុភាព នាំអោយមានការចោទប្រកាន់ជាបទព្រហ្មទណ្ឌនោះទេ។ ក្រមនីតិវិធីព្រហ្មទណ្ឌបើកសិទ្ធិឱ្យជនរងគ្រោះធ្វើបណ្តឹងអាជ្ញា។ អយ្យការអមសាលាដំបូង គឺស្ថាបន័អយ្យការដែលនៅអមសាលាដំបូងរាជធានី-ខេត្ត ។ ហើយចំពោះមុខងាររបស់អយ្យការអមសាលាដំបូង ត្រូវបានប្រគល់ទៅអោយព្រះរាជអាជ្ញាអមសាលាដំបូង ។

## ១. រចនាសម្ព័ន្ធនៃអយ្យការអមសាលាដំបូង

អនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ សាលាជម្រះក្តី នៅព្រះរាជាណាចក្រកម្ពុជារួមមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល។ សាលាដំបូងជាសាលាជម្រះក្តីជាន់ទាប ចំណែកឯសាលាឧទ្ធរណ៍ និងតុលាការកំពូលជាសាលាជម្រះក្តីជាន់ខ្ពស់ ។ ហើយនៅអមសាលាដំបូងត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង ចំពោះនៅអមសាលាឧទ្ធរណ៍វិញ ត្រូវមានអង្គការអយ្យការមួយ ហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ និងនៅអមតុលាការកំពូល ត្រូវមានអង្គការអយ្យការមួយហៅថា មហាអយ្យការអមតុលាការកំពូល [14]។ តំណាងអយ្យការ ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់ នៃរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងៗទៀតដែលច្បាប់កំណត់ ។

### ១.១ សមាសភាពនៃអយ្យការអមសាលាដំបូង

អនុលោមតាមមាត្រា២៩ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤ សមាសភាពអយ្យការអមសាលាដំបូង រួមមាន ៖

ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។

---

[14] មាត្រា៨ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ឆ្នាំ ២០១៤ ។

### ១.១.១ ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអមសាលាដំបូង ជាតំណាងអង្គការអយ្យការអមតុលាការនេះ[15] ព្រះរាជអាជ្ញាដឹកនាំ សម្របសម្រួល សកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ ក្នុងដែនដីរបស់ខ្លួន ព្រមទាំងចុះទៅទីកន្លែងស៊ើបអង្កេត និងការចង្អុលបង្ហាញណែនាំ ដែលមានប្រយោជន៍ដល់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ។ ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន [16]។

ចៅក្រមអយ្យការទាំងអស់ នៃអយ្យការអមសាលាដំបូង ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាអមសាលាដំបូង។ ព្រះរាជអាជ្ញាអមតុលាការមានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការ។ ព្រះរាជអាជ្ញាអមសាលាដំបូងចាត់ចែង និងបែងចែកដល់ចៅក្រមអយ្យការ នៃអយ្យការអមសាលាដំបូងនៅក្នុងការងារផ្សេងៗ នៃអយ្យការនិងក្នុងអង្គជំនុំជម្រះ។

### ១.១.២ ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារងជា តំណាងអង្គការអមតុលាការនេះ ព្រះរាជអាជ្ញារងអាចមានចំនួនច្រើន តាមការចាំបាច់ជាក់ស្តែង ព្រះរាជអាជ្ញារងស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីបានផ្តល់ឱ្យ ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស[17]។ រាល់សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ជាគោលការដាច់ខាតត្រូវតែបញ្ជូនដល់នាយឋានានុក្រមរបស់ខ្លួន ពោលគឺព្រះរាជអាជ្ញា ដើម្បីធ្វើការពិនិត្យមុនពេលដល់ដំណាក់កាលក្នុងសវនាការ ។ ហើយប្រសិនបើ ព្រះរាជអាជ្ញាមិនយល់ព្រម ទៅលើសេចក្តីសន្និដ្ឋាននោះ គឺព្រះរាជអាជ្ញារងត្រូវធ្វើការកែតម្រូវ លើសេចក្តីសន្និដ្ឋាននោះ បើព្រះរាជអាជ្ញារងមិនធ្វើការកែតម្រូវលើសេចក្តីសន្និដ្ឋាននោះទេ ដូច្នេះព្រះរាជអាជ្ញាអាចចាត់តាំង ដល់ព្រះរាជអាជ្ញារងផ្សេងទៀត ឬមួយចាត់តាំងខ្លួនឯងក្នុងការបំពេញការងារនេះ ។

[15] មាត្រា៣៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។
[16] មាត្រា៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។
[17] មាត្រា៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

### ១.១.៣ ក្រឡាបញ្ជី

ក្រឡាបញ្ជីជាអ្នកបច្ចេកទេស ផ្នែកនីតិវិធីដែលជួយសម្រួលដល់ចៅក្រម និងព្រះរាជអាជ្ញា នៅក្នុងសកម្មភាពសាលាជម្រះក្ដី ទៅតាមលក្ខខណ្ឌដែលមានកំណត់ក្នុងអត្ថបទច្បាប់ ឬ បទបញ្ញាជាធរមាន ។

នៅតាមអង្គការអយ្យការអមសាលាជម្រះក្ដីនីមួយៗ មានក្រឡាបញ្ជីអង្គការអយ្យការ ជាជំនួយនៅគ្រប់ដំណាក់កាលនៃនីតិវិធីអយ្យការ។ ក្រឡាបញ្ជីនៃអង្គការអយ្យការអមសាលាជម្រះក្ដីមួយ ដឹកនាំដោយនាយកក្រឡាបញ្ជីមួយរូបដែលត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នាយកក្រឡាបញ្ជី និងក្រឡាបញ្ជីអង្គការអយ្យការអមសាលាជម្រះក្ដីមួយ ត្រូវស្ថិតក្នុងអង្គភាពតែមួយ ហៅថាអង្គភាពក្រឡាបញ្ជីអង្គការអយ្យការអមសាលាជម្រះក្ដីនោះ[18] ។

## ២. សមត្ថកិច្ច តួនាទី ភារកិច្ចនិងសិទ្ធអំណាចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង

ដើម្បីទទួលបាននូវភាពច្បាស់លាស់ធានាសកម្មភាពនៃការប្រព្រឹត្តទៅ របស់អង្គការអយ្យការប្រកបទៅដោយប្រសិទ្ធិភាព ភាពរលូន តម្លាភាព និងភាពយុត្តិធម៌ពេញលេញ ព្រមទាំងរក្សាជំនឿទុកចិត្តពីសំណាក់ប្រជាពលរដ្ឋ ជាពិសេសជៀសវាងនៅការកើតមានឡើងនូវវិវាទសមត្ថកិច្ចនៃអយ្យការអមសាលាដំបូងនីមួយៗ ដែលមានប្រភេទដូចគ្នាហើយមានច្រើនកន្លែង ដែលតម្រូវឱ្យច្បាប់កំណត់អំពីដែនវង្វង់សមត្ថកិច្ចរបស់ព្រះរាជអាជ្ញានីមួយៗ ។

### ២.១ សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ជាក់ស្ដែងយើងឃើញថា នៅពេលដែលមានបទល្មើសមួយកើតឡើង គឺអាចមានការទាក់ទង និងបុគ្គលច្រើននាក់ ឬមួយទីតាំងច្រើនកន្លែង តាមការកំណត់ពាក់ព័ន្ធនឹងបទល្មើសនោះជាអាទិ៍ ដើម្បីមានភាពច្បាស់លាស់ និងភាពងាយស្រួលក្នុងការប្រមូលស្វែងរកភ័ស្ដុតាងផ្សេងៗជៀសវាងនូវការកើតមាននូវវិវាទសមត្ថកិច្ចដែលមានប្រភេទដូចគ្នា ប៉ុន្តែទីតាំងខុសគ្នា ច្បាប់បានកំណត់អំពីសមត្ថកិច្ច របស់ព្រះរាជអាជ្ញាដូចជា ៖ ទីតាំងប្រព្រឹត្តបទល្មើស ទីតាំងជនសង្ស័យរស់នៅ និងទីតាំងចាប់ខ្លួនជនសង្ស័យ។ ដូច្នេះហើយដើម្បីងាយស្រួលកំណត់ថា តើព្រះរាជអាជ្ញាណាមួយដែលមានសមត្ថកិច្ច ក្នុងការដំណើរនីតិវិធីលើបទល្មើសនោះ។ ដូចនេះព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចគឺ ៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃលំនៅដ្ឋានរបស់ជនសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស[19] ។

[18] មាត្រា៨ សេចក្ដីព្រាងច្បាប់ ស្ដីពីលក្ខន្តិកៈនៃក្រឡាបញ្ជី។

[19] មាត្រា៣៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

## ២.១ តួនាទីរបស់ព្រះរាជអាជ្ញា

តួនាទីអយ្យការត្រូវតែបែងចែកឱ្យដាច់ពីមុខងារតុលាការ។ ព្រះរាជអាជ្ញាត្រូវដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងស្ថាប័នអយ្យការ ដែលច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តន៍ក្នុងស្រុកក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលការអនុវត្តន៍សាលក្រម និងការបំពេញតួនាទីផ្សេងៗទៀតដោយតំណាងឱ្យផលប្រយោជន៍សាធារណៈ។

ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវច្បាស់លាស់ និងឱ្យបានឆាប់រហ័សស្របតាមច្បាប់កំណត់ហើយត្រូវគោរពនិងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្សហេតុដូច្នេះត្រូវរួមជាវិភាគទានក្នុងការធានាដល់កិច្ចដំណើរការ នៃប្រព័ន្ធយុត្តិធម៌ឱ្យបានត្រឹមត្រូវនិងមានភាពរលូន [20]។

## ២.២ ភារកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ព្រះរាជអាជ្ញាត្រូវ[21]៖

- អនុវត្តមុខនាទីរបស់ខ្លួនដោយមិនលំអៀង និងជៀសវាងរាល់ការរើសអើងភេទ វប្បធម៌ ជាតិសាសន៍ សាសនា ឋានៈសង្គម នយោបាយ ឬការរើសអើងណាមួយផ្សេងទៀត ។
- ការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលំអៀង និងត្រូវប្រុងប្រយ័ត្នគ្រប់ស្ថានភាពដែលពាក់ព័ន្ធទាំងអស់ ទោះជាស្ថានភាពនោះមានប្រយោជន៍ ឬឥតមានប្រយោជន៍ដល់ ជនសង្ស័យក៏ដោយ ។
- រក្សារឿងក្តីជាការសម្ងាត់ លើកលែងតែត្រូវបំពេញភារកិច្ច បើពុំដូច្នោះទេគឺជាតំរូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។
- ព្រះរាជអាជ្ញាមិនត្រូវផ្តើមគំនិតចោទប្រកាន់ ឬបន្តចោទប្រកាន់ ឬមិនត្រូវខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីតំកល់រឿងទុកឥតចាត់ការ នៅពេលដែលការស៊ើបអង្កេតដោយលំអៀងមួយ បង្ហាញឱ្យឃើញថាការចោទប្រកាន់នេះពុំមានមូលដ្ឋានត្រឹមត្រូវ ។
- ព្រះរាជអាជ្ញាត្រូវផ្តល់ការយកចិត្តទុកដាក់ លើការធ្វើបណ្តឹងអាជ្ញា ចំពោះមន្ត្រីសាធារណៈដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋដទៃៗទៀត ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិហើយ និងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះ នៅទីណាដែលមានការអនុញ្ញាត្តិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់ ។

[20] គោលការណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយអង្គការសហប្រជាជាតិ ឆ្នាំ១៩៩០ ប្រទេសគុយបា ទីក្រុងហាវ៉ាណា

[21] គោលការណែនាំស្តីពី តួនាទីរបស់ព្រះរាជអាជ្ញា អនុម័តដោយអង្គការសហប្រជាជាតិ ឆ្នាំ១៩៩០ ប្រទេសគុយបា ទីក្រុងហាវ៉ាណា

### ២.៣ សិទ្ធអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអមតុលាការមានអំណាច គ្រប់គ្រងលើព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការ។ ព្រះរាជអាជ្ញាអមសាលាដំបូងចាត់ចែង និងបែងចែកដល់ចៅក្រមអយ្យការ នៃអយ្យការអមសាលាដំបូងនៅក្នុងការងារផ្សេងៗនៃអយ្យការ និងក្នុងអង្គជំនុំជម្រះនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ព្រះរាជអាជ្ញាអាចធ្វើអធិបញ្ញា ឱ្យចៅក្រមអយ្យការធ្វើការចោទប្រកាន់ ឬក៏ចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ[22]។ អំណាចអធិបញ្ញា គឺជាបញ្ជាដែលប្រើចំពោះការចោទប្រកាន់ ប៉ុន្តែមិនមែនជាការបញ្ជាឱ្យមានការតម្កល់រឿងទុកឥតចាត់ការនោះទេ។ ព្រះរាជអាជ្ញាដឹកនាំសម្របសម្រួល ដល់សកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងដែនដី សមត្ថកិច្ចរបស់ខ្លួន។ ព្រះរាជអាជ្ញាចុះទៅទីកន្លែងស៊ើបអង្កេត និងចង្អុលបង្ហាញណែនាំ ដែលមានប្រយោជន៍ដល់មន្ត្រីនគរបាលយុត្តិធម៌។ ក្នុងករណីចាំបាច់ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេត ពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រី និងភ្នាក់ងារនេះ[23]។

មុននឹងធ្វើការចោទប្រកាន់ចំពោះបទល្មើសណាមួយបាន ព្រះរាជអាជ្ញាត្រូវមានការបើកការស៊ើបអង្កេតជាមុនសិន ដើម្បីពិនិត្យទៅលើអង្គច្បាប់ និងអង្គហេតុដែលបានកើតឡើង និងកំណត់ឱ្យបានច្បាស់លាស់អំពីប្រភេទបទល្មើស និងធាតុផ្សំបទល្មើស សម្រាប់ធ្វើការចោទប្រកាន់ ចំពោះបុគ្គលដែលបានប្រព្រឹត្តនៅបទល្មើសនោះ។ ពិសេសជាងនេះ នៅក្នុងដំណាក់កាលនៃការចោទប្រកាន់ព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការជ្រើសរើសយកវិធានណាមួយ ពោលគឺការចោទប្រកាន់ ឬមួយតម្កល់រឿងទុកឥតចាត់ការ ដែលឱ្យឈ្មោះថា **គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**។ ដែលយើងខ្ញុំ នឹងធ្វើការបកស្រាយឱ្យបានពិស្តានៅក្នុងជំពូកទី៣ ។

## ៣. គោលការណ៍សំខាន់ៗនៃអង្គការអយ្យការ

នៅក្នុងទំនាក់ទំនងការងារនៃការរៀបចំអង្គការអយ្យការ ចៅក្រមអយ្យការ ត្រូវគោរពនៅគោលការណ៍មួយចំនួនដូចតទៅ ៖

### ៣.១ គោលការណ៍ឯករាជ្យ

អង្គការអយ្យការគឺឯករាជ្យពីសាលាជម្រះក្តីមានន័យថា អយ្យការមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលមានន័យថា សាលាជម្រះក្តីមិនអាចត្រួតពិនិត្យកិច្ចការ ឬជ្រៀតជ្រែត កិច្ចការរបស់ចៅក្រមអយ្យការបានឡើយ។ ទោះបីជាក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសខុសឆ្គងក្នុងការបំពេញមុខងារ ក៏ដោយ

[22] មាត្រា២៩ កថាខណ្ឌ៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

[23] មាត្រា៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

ក៏សាលាជម្រះក្តីមិនត្រូវ ឬមិនអាចចុះសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសចំពោះព្រះរាជអាជ្ញាបានឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងក្តីព្រហ្មទណ្ឌ និងក្នុងរឿងក្តីផ្សេងទៀត។ ប៉ុន្តែសាលាជម្រះក្តីអាចលើកសំណើទៅនាយឋានានុក្រមព្រះរាជអាជ្ញា អំពីកំហុសឆ្គងនោះបាន[24]។ ឧទាហរណ៍៖ នៅពេលដែលព្រះរាជអាជ្ញារងមានកំហុសធ្ងន់ធ្ងរនៅពេលបំពេញមុខងាររបស់ខ្លួន ចៅក្រមអាសនៈអាចជូនដំណឹងទៅថ្នាក់លើរបស់ព្រះរាជអាជ្ញារង នោះគឺព្រះរាជអាជ្ញាអមសាលាដំបូង ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ៣.២ គោលការណ៍ឯកភាព ( ឬឋានានុក្រម )

អង្គការអយ្យការ គឺជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់នាយឋានានុក្រម(ការស្តាប់បញ្ជា)។នាយឋានានុក្រមនៃអង្គការអយ្យការជាអ្នកដឹកនាំ និងជាអ្នកទទួលខុសត្រូវរួមនៅក្នុងអង្គភាពរបស់ខ្លួន ។ នៅក្នុងការបំពេញមុខងាចៅក្រមអយ្យការត្រូវតែស្តាប់បង្គាប់ ឬការណែនាំនាយឋានានុក្រមរបស់ខ្លួនតាមរយៈការធ្វើអធិបញ្ញា។ ចៅក្រមអយ្យការ ដែលនៅក្រោមឋានានុក្រមមិនអាចប្រឆាំង មិនធ្វើតាមអធិបញ្ញា ឬការណែនាំរបស់នាយឋានុក្រមរបស់ខ្លួនបានឡើយ ពោលគឺដាច់ខាតត្រូវតែធ្វើតាម។ នាយឋានានុក្រមអាចធ្វើអធិបញ្ញាឱ្យចៅក្រមអយ្យការធ្វើតាមខ្លួន បានគ្រប់យ៉ាងដូចជា៖ អធិបញ្ញាឱ្យចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ឬការធ្វើសេចក្តីសន្និដ្ឋានតាមការ យល់ឃើញរបស់ខ្លួនជាអាទិ៍។ លើកលែងតែការធ្វើអធិបញ្ញា ឱ្យតម្កល់រឿងទុកឥតចាត់ការ ។

នៅពេលសវនាការចៅក្រមអយ្យការអាចធ្វើសេចក្តីសន្និដ្ឋាន តាមអ្វីដែលខ្លួនយល់ឃើញជាការគួរដោយសម្បជញ្ញៈរបស់ខ្លួន ទោះបីជាការគិតខុសពីសេចក្តីសន្និដ្ឋាននៅក្នុងសំណុំរឿងដែលនាយឋានានុក្រមបានណែនាំក៏ដោយ ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខអក្សរទៅអង្គការគ្រប់ជាន់ថ្នាក់ ។

**អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖** គឺជានាយឋានុក្រមនៃមហាអយ្យការអមតុលាការកំពូល ។

**អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** គឺជានាយឋានានុក្រម នៃមហាអយ្យការអមសាលាដំបូងទាំងអស់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

[24] មាត្រា ៧៥ កថាខណ្ឌ៣ នៃច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ។

**ព្រះរាជអាជ្ញាអមសាលាដំបូង៖** គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង ។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវ ធ្វើការក្រោមការដឹកនាំនិងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន[25]។

### ៣.៣ គោលការណ៍អវិភាគ( ឬមិនអាចបំបែកបាន)

អង្គការអយ្យការជាអង្គអវិភាគ គឺក្នុងការបំពេញមុខងារសមាជិកនៃអង្គការអយ្យការម្នាក់ៗ ជាតំណាងឱ្យអង្គការអយ្យការទាំងមូល និងជាប្រយោជន៍សមូហភាព ។ យោងតាមគោលការណ៍នេះនៅចំពោះមុខស្ថាប័នយុត្តាធិការទាំងអស់ ចៅក្រមអយ្យការតែងតែប្រើពាក្យថា យើងជាដំណាងអយ្យការ នៅពេលធ្វើសេចក្តីសន្និដ្ឋានផ្សេងៗ ដូចជាការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំជាអាទិ៍ ដែលជាការសន្និដ្ឋានតាំងនាមឱ្យអង្គការអយ្យការទាំងមូល ។

ក្នុងការបំពេញមុខងាររបស់ខ្លួនចៅក្រមអយ្យការអាចជំនួសគ្នាទៅវិញទៅមកបាន នៅក្នុងសំណុំរឿងតែមួយ ដែលតាមរយៈការចាត់ចែងរបស់នាយឋានានុក្រម[26]។

### ៣.៤ គោលការណ៍មិនអាចប្តឹងជំទាស់

ចៅក្រមអយ្យការមិនអាចត្រូវប្តឹងជំទាស់ដូចទៅនិងចៅក្រមអសនះទេ។ ចៅក្រមអយ្យការមានឋានៈជាភាគីមួយនៃបណ្តឹងព្រហ្មទណ្ឌ ដែលប្តឹងសុំឱ្យតុលាការអនុវត្តច្បាប់តែប៉ុណ្ណោះ ពោលគឺគ្មានអំណាចសម្រេចសេចក្តីនោះទេ។ ចៅក្រមអយ្យការមានអំណាចតំណាងឱ្យគ្នាទៅវិញទៅមកបានគ្រប់កិច្ចនីតិវិធីដូចសេចក្តីសម្រេច របស់ចៅក្រមអយ្យការ គឺដំណាងឱ្យស្ថាប័នទាំងមូល ។

### ៣.៥ គោលការណ៍មិនទទួលខុសត្រូវ

ចៅក្រមអយ្យការបំពេញមុខងារជាសមូហភាព និងសម្រេចសេចក្តីដំណាងឱ្យ ស្ថាប័នអយ្យការទាំងមូល។ និងមិនមែនក្នុងនាមបុគ្គលនោះឡើយទើបចៅក្រមអយ្យការមិនទទួលខុសត្រូវចំពោះការសម្រេចចិត្តរបស់ខ្លួននោះទេ។ ចៅក្រមអយ្យការជាតំណាងឱ្យអំណាចនីតិប្រតិបត្តិ ដើម្បីការពារផលប្រយោជន៍សាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម និងតាំងខ្លួនជាគូក្តីនៅក្នុងបណ្តឹងព្រហ្មទណ្ឌ ប្រឆាំងនិងជនល្មើសជានិច្ច។ ហេតុដូចនេះនៅពេលដែល ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ចំពោះបុគ្គលណាម្នាក់ ដើម្បីឱ្យស្ថាប័នយុត្តាធិការជំនុំជម្រះ ហើយបុគ្គលនោះត្រូវបានតុលាការប្រកាសថាគ្មានពិរុទ្ធភាព ឬសម្រេចឱ្យ រួចផុតពីបទចោទព្រះរាជអាជ្ញាមិនត្រូវដាក់ឱ្យទទួលខុសត្រូវ ឬទណ្ឌកម្មវិន័យណាមួយឡើយ។

[25] មាត្រា ៧៥ កថាខណ្ឌ១ នៃច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ ។

[26] មាត្រា ៧៥ កថាខណ្ឌ២ នៃច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

## ៤. ទ្រឹស្តីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ

ការចោទប្រកាន់ សំដៅដល់ការកំណត់អំពីអត្ថិភាពនៃបទល្មើស ដោយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋ ដែលកំណត់ដោយច្បាប់។ នៅក្នុងដំណាក់កាលចោទប្រកាន់ត្រូវអនុវត្តដោយអង្គការអយ្យការ ដែលមានសិទ្ធិ ធ្វើបណ្តឹងអាជ្ញា ។ ដោយក្នុងដំណាក់កាលចោទប្រកាន់របស់អយ្យការ ធ្វើការចោទប្រកាន់បុគ្គលទាំងឡាយណា ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនិងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះតាមនីតិវិធីច្បាប់។

ទ្រឹស្តីនៃការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌជាវិធាន ឬបទដ្ឋានគតិយុត្តិដែលបានបញ្ញត្តិ ដោយច្បាប់ជាធរមាន ដើម្បីឱ្យស្ថាប័នអយ្យការអនុវត្ត ឬប្រតិបត្តិតាម។ ទ្រឹស្តីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ ដែលយើងខ្ញុំលើកយកមកធ្វើការបកស្រាយរួមមាន៖ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និង គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។

### ៤.១ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

នៅមុនពេលអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ការចោទប្រកាន់របស់អង្គការអយ្យការត្រូវ បានគេជ្រើសរើសតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់។ មានន័យថាកាលណារឿងព្រហ្មទណ្ឌ មួយត្រូវបានប្តឹងមកមន្ទីអយ្យការ ព្រះរាជអាជ្ញា ត្រូវតែសម្រេចចាត់ការបណ្តឹងនោះ ពោលគឺត្រូវតែធ្វើការ ចោទប្រកាន់ឲ្យតែបទល្មើស ដែលត្រូវបានប្តឹងនោះមានធាតុផ្សំ ខាងអង្គហេតុ និងអង្គច្បាប់គ្រប់គ្រាន់[27] ដោយព្រះរាជអាជ្ញា មិនត្រូវគិតដល់កាលៈទេសៈអ្វីផ្សេងទៀតទេ។ ដោយតាមរយៈគោលការណ៍នេះ ស្ថាប័នទទួលបន្ទុកចោទប្រកាន់ នូវរឿងក្តីព្រហ្មទណ្ឌ ត្រូវបានចាប់បង្ខំដោយច្បាប់ឲ្យធ្វើការចោទប្រកាន់គ្រប់រឿងក្តី ទាំងឡាយដែលមានចរិតលក្ខណៈបទល្មើសព្រហ្មទណ្ឌ ដោយមិនគិតអំពីស្ថានភាពនៃបទល្មើស ឬបរិបទសង្គម ឬ តាមរបៀបមនុស្សធម៌ នោះទេ ។

### ៤.២ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

ក្រោយពីក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវបានអនុវត្ត គោលការណ៍នីត្យានុកូលភាពនៃការ ចោទប្រកាន់មិនត្រូវបានគេលើកយកមកអនុវត្តទៀតនោះទេដោយហេតុថា ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បាន លើកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ មកអនុវត្តជំនួសវិញ ។

តាមរយៈគោលការណ៍ថ្មីនេះ ច្បាប់បានផ្តល់ឆន្ទានុសិទ្ធិឲ្យស្ថាប័នអយ្យការ មានជម្រើសក្នុងការ ចោទប្រកាន់ ឬ មិនចោទប្រកាន់ ទោះបីជាអង្គហេតុទាំងនោះមានចរិតលក្ខណៈ ជាបទល្មើសព្រហ្មទណ្ឌ

[27] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកស្រី ឌី លីណា និងលោក ខាន់ សុខា ។

ក៏ដោយ។ ប៉ុន្តែអំណាចដែលច្បាប់បានផ្តល់ឲ្យគឺពុំមានស្ថានភាពទូលំទូលាយ ហួសហេតុដែលអាចធ្វើបានតាមទំនើងចិត្តនោះទេ វាត្រូវបានកម្រិតដោយលក្ខខណ្ឌគតិយុត្តមួយចំនួន ។

តាមរយៈគោលការណ៍នេះ ត្រូវបានវិស័យនីតិនិពន្ធតាក់តែងឡើង ដើម្បីបង្កើតនូវវិធានកណ្តាលនៃការចោទប្រកាន់ដោយប្រគល់ឲ្យ ស្ថាប័នចោទប្រកាន់ពោលគឺស្ថាប័នអយ្យការមាននូវជម្រើសដ៏សំខាន់ក្នុងការធ្វើចំណាត់ការលើសំណុំរឿងក្តីព្រហ្មទណ្ឌ តាមរយៈគោលការណ៍នេះអនុញ្ញាតឲ្យស្ថាប័នអយ្យការ មានជម្រើសមិនធ្វើការចោទប្រកាន់ ទោះបីអំពើដែលបរិហារនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ [28] ។ ជម្រើសមិនចោទប្រកាន់នេះសម្តែងចេញតាមការរយៈសេចក្តីសម្រេចតម្កល់រឿងទុកមិនចាត់ការ ដែលផ្អែក ទៅលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ដូចគ្នាដែរក្នុងករណីដែលមានអំពើច្រើនដែលត្រូវ បានប្តឹងមកនោះមានការពាក់ព័ន្ធក្នុងអង្គហេតុតែមួយ ព្រះរាជអាជ្ញាមានជម្រើសធ្វើការចោទប្រកាន់ នូវអំពើណាមួយ ហើយមិនចោទប្រកាន់នូវអំពើផ្សេងទៀត ។ ឧទាហរណ៍ ៖ មានករណីមួយដែលជនល្មើសជាជនដែលមានជីវភាពក្រីក្រលំបាក គាត់បានលួចបេះផ្លែស្វាយរបស់អ្នកភូមិចំនួន ៣ផ្លែ ដើម្បីចម្អែតក្រពះ ។ តាមរយៈសកម្មភាពរបស់ជនល្មើសបានឆ្លើយតប ទៅនិងនិយមន័យនៃអំពើលួច តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីខាងលើនេះបើយើងអនុវត្តតាមគោលការណ៍ នីត្យានុកូលនៃការចោទប្រកាន់ ជនល្មើសនឹងត្រូវចោទប្រកាន់ពីបទលួចដោយស្ថាប័នអយ្យការ ក៏ប៉ុន្តែ បើយើងអនុវត្តតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ ដោយផ្អែកតាមស្ថានភាព របស់ជនល្មើស ព្យសនកម្ម អំពើល្មើសវិញនោះ ជនល្មើសនេះអាចត្រូវបានស្ថាប័នអយ្យការតម្កល់រឿងទុកឥតចាត់ការបាន។

[28] សៀវភៅនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកស្រី ឌី លីណា និងលោក ខាន់ សុខា ។

# ជំពូកទី៣៖
# ការអនុវត្តគោលការណ៍កាលានុវត្តភាពនៃ
# ការចោទប្រកាន់

# ជំពូកទី៣៖

# ការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់បានផ្តល់ឲ្យព្រះរាជអាជ្ញានូវសេរីភាព នៃការពិចារណា និងការថ្លឹងថ្លែង ពីការសម្រេចអំពីបណ្តឹងអាជ្ញា។ ម៉្យាងវិញទៀតគោលការណ៍នេះក៏បានអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ទោះបីជាអំពើដែលបានប្តឹង ឬបរិហានោះ ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។ វិធាននៃគោលការណ៍នេះគឺផ្ទុយគ្នាពីគោលការណ៍នីត្យានុកូលភាពនៃបណ្តឹង ដែលត្រូវបានអនុវត្តនៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ដែលតម្រូវឲ្យព្រះរាជអាជ្ញាត្រូវចោទប្រកាន់ នូវរាល់បទល្មើសព្រហ្មទណ្ឌដែលខ្លួនបានដឹង[29]។ ចំណែកឯគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ គឺបានផ្តល់ជាជម្រើសដ៏សំខាន់ដល់ព្រះរាជអាជ្ញា នៅក្នុងការធ្វើចំណាត់ការសំណុំរឿង ដោយផ្អែកទៅលើទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្ត ព្យសនកម្មដែលបង្កភាពវឹកវរដល់សង្គម និងព័ត៌មានផ្សេងទៀតដែល ប្រមូលបានពីការស៊ើបអង្កេត។ ការសម្រេចអំពីបណ្តឹងអាជ្ញាអាចស្តែងឡើងតាមរូបភាពពីរយ៉ាងគឺ ការតម្កល់រឿងទុកឥតចាត់ការ និងការសម្រេចចោទប្រកាន់។

## ១. ការតម្កល់រឿងទុកឥតចាត់ការ

### ១.១ មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការមានច្រើន ដោយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ច្បាស់លាស់ទេ។ ប៉ុន្តែតាមរយៈការធ្វើចំណាត់ការលើសំណុំរឿង ព្រះរាជអាជ្ញាអាចនឹងតម្កល់រឿងទុកឥតចាត់ការចំពោះស្ថានភាពមួយចំនួនដូចតទៅ៖

#### ១.១.១ អវត្តមាននៃអត្តសញ្ញាណរបស់ចារី

ការមិនអាចកំណត់បាននូវអត្តសញ្ញាណនៃជនល្មើស អាចជាមូលហេតុដែលនាំឲ្យព្រះរាជអាជ្ញាមិនធ្វើការចោទប្រកាន់ ព្រោះអត្តសញ្ញាណនៃជនល្មើស ជាបន្ទុកសំខាន់ដើម្បីបង្ហាញអំពីពិរុទ្ធភាព និងជាមូលដ្ឋានសម្រាប់ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ផងដែរ។ ទន្ទឹមនឹងនេះបើទោះបីជាការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមត្រូវបានធ្វើឡើងក៏ដោយ តែបើមិនអាចកំណត់នូវអត្តសញ្ញាណនៃជនល្មើសបានទេ នោះលទ្ធផលនៃការស្រាវជ្រាវ និងស៊ើបអង្កេតនោះហាក់ដូចជាគ្មានប្រយោជន៍ និងគ្មានប្រសិទ្ធភាព។ ទោះជាយ៉ាងណាព្រះរាជអាជ្ញានូវតែអាចចោទប្រកាន់បុគ្គលដែលជាអញ្ញាតជនបានដដែល ប្រសិនបើយល់ឃើញថាចាំបាច់[30] ប៉ុន្តែជាការអនុវត្តគេពុំសូវឃើញការចោទប្រកាន់ចំពោះអញ្ញាតជននោះទេ។

[29] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យ ហ៊ី សោភា

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៤

### ១.១.២ អវត្តមាននៃបទល្មើសព្រហ្មទណ្ឌ

នៅពេលដែលព្រះរាជអាជ្ញា ទទួលបានព័ត៌មានព្រហ្មទណ្ឌដូចជា ពាក្យប្ដឹងដែលទទួលបានផ្ទាល់ ឬពាក្យប្ដឹងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌។ ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ប៉ុន្តែមុននឹងសម្រេចព្រះរាជអាជ្ញា ត្រូវថ្លឹងថ្លែងចំណាត់ការដោយបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមជាមុនសិន [31] ។ ជាដំបូងព្រះរាជអាជ្ញាត្រូវធ្វើការថ្លឹងថ្លែង និងពិចារណាទៅលើលទ្ធផលនៃការស្រាវជ្រាវ ឬការស៊ើបអង្កេតនោះ ប្រសិនបើក្នុងករណីដែលពិនិត្យឃើញថាអង្គហេតុនៃរឿងមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌទេ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានឡើយ។ ក្នុងករណីមួយចំនួនអង្គហេតុខ្លះ មិនមែនជាបទល្មើសព្រហ្មទណ្ឌទេ តែអាចជាវិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម វិវាទការងារឬជាវិវាទរដ្ឋបាលជាដើម។ ដូច្នេះព្រះរាជអាជ្ញានឹងមិនចាត់ការទៅលើសំណុំរឿងនោះទេ ព្រោះព្រះរាជអាជ្ញាមានសមត្ថកិច្ចចាត់ការតែលើបណ្ដឹងអាជ្ញាប៉ុណ្ណោះ[32]។

### ១.១.៣ កង្វះធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

បន្ទាប់ពីប្រមូលបានព័ត៌មាន អំពីសំណុំរឿង តាមរយៈពាក្យប្ដឹងរបស់ជនរងគ្រោះ ឬតតិយជន ឬពាក្យប្ដឹងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌រួមមក ព្រះរាជអាជ្ញាត្រូវចាត់ឲ្យមានការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែម ដើម្បីពិនិត្យស្វែងរកនូវធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។ តាមទ្រឹស្ដីនីតិព្រហ្មទណ្ឌជាទូទៅគេចែកធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌជា៣គឺ៖

- **ធាតុផ្សំនីត្យានុកូល៖** សំដៅដល់ធាតុច្បាប់។ មានន័យថាដើម្បីអាចចាត់ទុកថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែអំពើនោះមានចែងថាជាបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន។
- **ធាតុផ្សំសត្យានុម័ត៖** ជាធាតុផ្សំសម្ភារៈ។ សំដៅដល់អង្គហេតុនៃរឿង ឬព្រឹត្តការណ៍ទាំងឡាយដែលបង្កើតឡើងទៅជាសកម្មភាពណាមួយ ដែលច្បាប់ព្រហ្មទណ្ឌចែងថាជាបទល្មើស។ សកម្មភាពទាំងនោះអាចជាអំពើសកម្ម ឬអកម្ម អំពើកើតឡើងភ្លាមៗ ឬមានលក្ខណៈអូសបន្លាយ ឬអំពើដែលកើតឡើងម្ដងម្កាល ឬកើតឡើងជាទម្លាប់ជាអាទិ៍។
- **ធាតុផ្សំអត្តនោម័ត៖** ជាធាតុផ្សំចិត្តសាស្ត្រ។ គឺជាចរិកគ្រោះថ្នាក់ដែលចេញពីឆន្ទៈ ឬចេតនា តាមកិរិយាផ្លូវចិត្តរបស់ជនល្មើស។ ជាទូទៅធាតុអត្តនោម័ត ស្ដែងចេញតាមរយៈធាតុសត្យានុម័តតែម្ដង ជាពិសេសលទ្ធផលនៃអំពីល្មើសដែលជាព្យសនកម្ម អាចបង្ហាញពីចេតនានៃការប្រព្រឹត្តរបស់ជនល្មើស។

[31] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤០

[32] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៣១ថ្មី

ធាតុផ្សំនៃបទល្មើសទាំងនេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ប្រសិនបើកង្វះនៃធាតុផ្សំណាមួយ ព្រះរាជអាជ្ញា នឹងមិនអាចបង្ហាញពិរុទ្ធភាពនៃជនល្មើសឲ្យហួសពីវិមតិសង្ស័យបានឡើយ ដែលនាំឲ្យការអនុវត្តបណ្តឹងអាជ្ញាមិនអាចធ្វើទៅបាន។

### ១.១.៤ មូលហេតុគតិយុត្ត

ដូចដែលបានលើកឡើងរួមមកហើយថា ព្រះរាជអាជ្ញាអាចអនុវត្តគោលការណ៍កាលានុវត្តភាព ដើម្បីសម្រេចអំពីបណ្តឹងអាជ្ញា។ ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌពុំបានបញ្ញត្តិអំពីមូលហេតុគិតយុត្តិណាមួយ ដែលនាំឲ្យព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការនោះទេ តែក្រមនេះបានបញ្ញត្តិអំពីមូលហេតុមួយចំនួនដែលនាំឲ្យរលត់បណ្តឹងអាជ្ញា។

#### ១.១.៤.១ ការរលត់បណ្តឹងអាជ្ញា

ការធ្វើបណ្តឹងអាជ្ញាគឺ ជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ក្នុងគោលបំណងដើម្បីធានានូវ សណ្តាប់ធ្នាប់សង្គម។ ប៉ុន្តែបណ្តឹងនេះអាចនឹងត្រូវរលត់ដោយមូលហេតុមួយចំនួន ដែលនាំឲ្យការធ្វើបណ្តឹងមិនអាចបន្តទៅទៀតបាន។ មូលហេតុដែលនាំឲ្យរលត់បណ្តឹងអាជ្ញាត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងនោះរួមមានដូចជា៖ មរណៈភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍ច្បាប់ព្រហ្មទណ្ឌ និងអាជ្ញាអស់ជំនុំ[33]។

ក្រៅពីមូលហេតុខាងលើ ក៏មានមូលហេតុផ្សេងៗទៀត ដែលនាំឲ្យរលត់បណ្តឹងអាជ្ញាផងដែរ កាលណាមូលហេតុទាំងនោះត្រូវបានចែងជាក់លាក់ដោយច្បាប់ដោយឡែក។ មូលហេតុទាំងនោះរួមមាន៖ ការសម្របសម្រួលជាមួយរដ្ឋ ការដកពាក្យប្តឹងជាដើម[34]។

**ក. មរណៈភាពនៃជនល្មើស**

ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ បណ្តឹងអាជ្ញានឹងត្រូវរលត់ក្នុងករណីដែលជនល្មើសបានទទួលមរណៈភាព[35]។ ជាការពិតណាស់ក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ជនល្មើសជាប្រធាននៃបទល្មើស និងជាកម្មវត្ថុនៃបណ្តឹងអាជ្ញាផងដែរ[36]។ បើជនល្មើសបានទទួលមរណៈភាពហើយ ជននោះនឹងបាត់បង់នូវបុគ្គលភាពគតិយុត្ត ដែលពេលនោះគឺលែងជារូបវន្តបុគ្គលទៀតហើយ ផ្ទុយទៅវិញគឺជាសាកសព។ សាកសពមិនមែនជារូបវន្តបុគ្គលទេ ដូច្នេះជននេះលែងក្លាយជាកម្មវត្ថុនៃបណ្តឹងអាជ្ញាតទៅទៀតហើយ។ ទន្ទឹមនឹងនេះបណ្តឹងអាជ្ញាធ្វើឡើងក្នុង

---

33 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៧

34 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៨

35 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៧

36 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៣

គោលបំណង ដើម្បីផ្តន្ទាទោសជនល្មើសតាមកំណត់ច្បាប់[37] ក្នុងគោលដៅធានារក្សាសណ្តាប់ធ្នាប់សាធារណៈ តែប្រសិនបើជនល្មើសទទួលមរណៈភាព នោះគោលបំណងនៃបណ្តឹងអាជ្ញាក៏មិនអាចបំពេញបានដែរ មានន័យថាទោះបីជាធ្វើការចោទប្រកាន់ក៏ហាក់ដូចជាគ្មានប្រយោជន៍អ្វីដែរ។ ម៉្យាងវិញទៀតផ្អែកតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ[38] បានសេចក្តីថាពុំមានបុគ្គលណាផ្សេងមក ទទួលទោសជំនួសជនល្មើសបានឡើយ ដូច្នេះបើជនល្មើសទទួលមរណៈភាព បណ្តឹងអាជ្ញានឹងលែងអាចធ្វើបានតទៅទៀតហើយ។

ដូចនេះការតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលជនល្មើសទទួលមរណៈភាព គឺជាហេតុផលដ៏ត្រឹមត្រូវ។ ប៉ុន្តែទោះជាយ៉ាងណា ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំឲ្យមានការជួសជុលព្យសនកម្ម ពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជននេះទទួលមរណៈភាពក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។ ទោះបីជាបណ្តឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះបាន[39]។

**ខ. ការផុតអាជ្ញាយុកាល**

អាជ្ញាយុកាលនៅក្នុងរឿងព្រហ្មទណ្ឌមានពីរគឺៈ អាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។ តែនៅត្រង់ចំណុចនេះគឺចង់សំដៅដល់ អាជ្ញាយុកាលនៃបទល្មើស ឬហៅម៉្យាងទៀតថាអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា។ អាជ្ញាយុកាលនេះគឺជាការកំណត់ដោយច្បាប់នូវថេរវេលាមួយសមស្រប សម្រាប់ព្រះរាជអាជ្ញាក្នុងការធ្វើបណ្តឹង។ ថេរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចជាៈ

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ[40]។

អាជ្ញាយុកាលនៃបទល្មើសត្រូវ មានភាពខុសគ្នាទៅតាមប្រភេទបទល្មើសនីមួយៗ។ តួយ៉ាងដូចជាបទឧក្រិដ្ឋ ដែលមានអាជ្ញាយុកាល១៥ឆ្នាំ ជាដើមដែលបទឧក្រិដ្ឋភាគច្រើនគឺជាបទល្មើសដែលបង្កគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរ។ ប៉ុន្តែទន្ទឹមនឹងនេះក៏មានឧក្រិដ្ឋកម្មមួយចំនួនដែលគ្មានអាជ្ញាយុកាលកំណត់ផងដែរ ដែលក្នុងនោះមានដូចជា បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[41]។

---

[37] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២

[38] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា២៤

[39] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៤

[40] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១០

[41] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៩

ដោយសារបទឧក្រិដ្ឋទាំងបីនេះ មានចរឹកគ្រោះថ្នាក់ធ្ងន់ធ្ងរខ្លាំង ដែលអាចបង្កជាមហន្តរាយដល់អាយុជីវិតសង្គមទាំងមូល ដូច្នេះការចោទប្រកាន់របស់ព្រះរាជអាជ្ញាអាចធ្វើឡើងបានគ្រប់ពេល ដើម្បីបង្ការ និងទប់ស្កាត់ឲ្យបានទាន់ពេលវេលានូវបទល្មើសទាំងនេះ។ ថេរវេលានៃអាជ្ញាយុកាល នឹងត្រូវរាប់ចាប់ពីពេលប្រព្រឹត្តិបទល្មើស។ ហើយអាជ្ញាយុកាលនឹងត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ មានន័យថាបើអាជ្ញាយុកាលកំពុងតែចាប់ផ្តើមរាប់ ឬបន្តរាប់នូវថេរវេលា ប៉ុន្តែកំឡុងពេលនោះស្រាប់តែ ព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬបើកកិច្ចស៊ើបសួរនោះ ថេរវេលានឹងត្រូវឈប់រាប់តែម្តង។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឲ្យចាប់ផ្តើមគតិថិរវេលាថ្មីនៃអាជ្ញាយុកាល [42] ដែលនេះមានន័យថាអាយុកាលនឹងត្រូវរាប់សារជាថ្មីនៅពេលដែលកិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរត្រូវបានបញ្ចប់។

ដូច្នេះតាមការបកស្រាយខាងលើយើងឃើញទោះបីជាការផុតអាជ្ញាយុកាលនៃបទល្មើសជាមូលហេតុដែល នាំឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ក៏ដោយ តែអាយុកាលនេះ មិនងាយនឹងរលត់ទេ ជាពិសេសតាមរយៈការផ្តាច់រយៈពេលនៃអាជ្ញាយុកាលតែម្តង ដែលនាំឲ្យមានការរាប់សារជាថ្មីនូវថេរវេលា។

**គ. ការលើកលែងទោសជាទូទៅ**

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឲ្យមានមតិភាគច្រើនដាច់ខាតនៃសមាជិកសភាទាំងមូល[43]។ ការលើកលែងទោសជាទូទៅ ជាវិធានការនីតិកម្មដែលមានគោលដៅលុបចោលនូវលក្ខណៈជាបទល្មើសរបស់អំពើមួយចំនួន។ ការលើកលែងទោសជាទូទៅនេះ ស្ថិតនៅក្នុងអំណាចរបស់អង្គការនីតិបញ្ញត្តិ។ ច្បាប់នេះអាចអនុម័តបានដោយមានមូលហេតុច្រើនយ៉ាងដូចជា កុំឲ្យមានទណ្ឌិតក្នុងពន្ធនាគារច្រើនពេកក្នុងឱកាសហេតុការណ៍សំខាន់ណាមួយជាដើម។[44] កាលណាមានការលើកលែងទោសជាទូទៅ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានទៀតឡើយ មានន័យថាបណ្តឹងអាជ្ញាត្រូវបានរលត់។

**ឃ. និរាករណ៍ច្បាប់ព្រហ្មទណ្ឌ**

នៅក្នុងករណីដែលច្បាប់ព្រហ្មទណ្ឌចាស់កំណត់បទល្មើសណាមួយ ត្រូវបានលុបចោលដោយច្បាប់ថ្មីនោះបណ្តឹងអាជ្ញាដែលទាក់ទង នឹងបទល្មើស ដែលបានប្រព្រឹត្ត ក្នុងពេលដែលច្បាប់ចាស់នៅជាធរមាន នឹងត្រូវរលត់[45] បានសេចក្តីថាព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ នូវបទល្មើសចាស់នោះ ហើយបើស្ថិតនៅក្នុងនីតិវិធីណាមួយក៏ត្រូវតែបញ្ឈប់ដែរ។

---

[42] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១១

[43] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៩០ថ្មី

[44] សៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយៈ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ២០១៤

[45] សៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយៈ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ២០១៤

**ខ. អាជ្ញាអស់ជំនុំ**

អាជ្ញាអស់ជំនុំ គឺសំដៅដល់គោលការណ៍មិនអាចជំនុំជម្រះពីរដងលើរឿងតែមួយ មានន័យថាបើជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវបានព្រះរាជអាជ្ញាចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់បទល្មើសថ្មីផ្សេងក៏ដោយ[46]។ គោលការណ៍នៃអាជ្ញាអស់ជំនុំនេះគឺជាការការពារសិទ្ធសេរីភាព របស់ជនជាប់ចោទ ព្រោះថាបើតុលាសម្រេចជាស្ថាពររួចហើយ តែបែរជាអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចចោទប្រកាន់ ចំពោះរឿងដែលជំនុំជម្រះជាស្ថាពររួច វាហាក់បីដូចជាមិនសមហេតុផល។ ម្យ៉ាងវិញទៀតបើមានការអនុវត្តបែបនេះ នោះនឹងនាំឲ្យមានការបាត់បង់នូវជំនឿទុកចិត្តរបស់សាធារណៈជនមកលើវិស័យយុត្តិធម៌ ជាពិសេសនោះគឺស្ថាប័នអយ្យការផ្ទាល់តែម្តង។ ប៉ុន្តែទន្ទឹមនេះគោលការណ៍អាជ្ញាអស់ជំនុំក៏នឹងនាំឲ្យមានផលវិបាកមួយចំនួនដូចតទៅ៖ ព្រះរាជអាជ្ញានឹងមិនអាចធ្វើបណ្តឹងអាជ្ញាបានទៀតទេ ប្រសិនបើមានសាលក្រមតុលាការសម្រេចដោះលែងជនជាប់ចោទចំពោះអំពើដដែលនេះ ទោះបីក្រោយពេលមានសាលក្រមស្ថាពរហើយ គេរកឃើញភស្តុតាងដាក់បន្ទុកថ្មីក៏ដោយ[47]។

ដូច្នេះព្រះរាជអាជ្ញាត្រូវ តែធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ ពីតម្រុយពិរុទ្ធភាពរបស់ជនល្មើស ជាមុនសិនមុននឹងសម្រេចធ្វើការចោទប្រកាន់ ព្រោះបើគ្មានមូលដ្ឋានច្បាស់លាស់ទេ វិមតិសង្ស័យនិងបានជាប្រយោជន៍ដល់ជនជាប់ចោទ ហើយតុលាការនឹងអាចសម្រេចដោះលែងជននោះដោយមូលហេតុ គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់។

**ច. ការសម្របសម្រួលជាមួយរដ្ឋ**

ក្នុងករណីដែល ច្បាប់ដោយឡែកបានចែងដាក់លាក់បណ្តឹងអាជ្ញានឹងរលត់ដោយការសម្របសម្រួលជាមួយរដ្ឋ[48]។ ការសម្របសម្រួលនេះអាចធ្វើទៅបានលុះត្រាតែ បុគ្គលដែលប្រព្រឹត្តល្មើស បានទទួលស្គាល់និងសន្យាកែប្រែកំហុស ហើយព្យសនកម្មដែលបង្កឡើងនោះត្រូវតែមិនប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់របស់សង្គម។

**ឆ. ការដកពាក្យបណ្តឹង**

ជាទូទៅការដកពាក្យប្តឹងរបស់ជនរងគ្រោះ មិនអាចដកការចោទប្រកាន់ពីបទអាជ្ញាបានទេ។ ការសម្រេចអំពីបណ្តឹងអាជ្ញាគឺជា សមត្ថកិច្ចផ្តាច់មុខរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែការដកពាក្យប្តឹងរបស់ជនរងគ្រោះអាចធ្វើទៅបានក្នុងករណីមួយចំនួន ដែលមានច្បាប់ដោយឡែកបានកំណត់ជាក់លាក់ ហើយពាក្យប្តឹងរបស់ជន

[46] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១២
[47] សៀវភៅ មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ២០១៤
[48] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៨

រងគ្រោះនោះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់[49]។ ជាឧទាហរណ៍ បទផិត ដែលមានចែងនៅក្នុងមាត្រា៧ នៃច្បាប់ស្តីពីឯកពន្ធភាពជាដើម ដែលសហព័ទ្ធជាជនរងគ្រោះ អាចស្នើសុំកុំឲ្យចោទប្រកាន់បាន[50]។ តែចំពោះស្ថានភាពជាក់ស្តែងវិញយើងសង្កេតឃើញថា ព្រះរាជអាជ្ញា មិនសូវចោទប្រកាន់ទៅលើបទល្មើសផិតដោយផ្ទាល់ទេ ភាគច្រើនគឺជាការដាក់ពាក្យប្តឹងពីសំណាក់សហព័ន្ធដែលជាជនរងគ្រោះទៅវិញ។

**១.១.៥ មូលហេតុគតិយុត្តផ្សេងទៀត**

ក្រៅមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏នៅមានមូលហេតុគតិយុត្តិផ្សេងទៀត ដែលច្បាប់កម្ពុជាបានបញ្ញត្តិ ហើយក៏ជាហេតុផលមួយចំនួនផងដែរ ដែលនាំឲ្យព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ មូលហេតុទាំងនោះរួមមាន៖ បុគ្គលមានអភ័យឯកសិទ្ធ មោឃៈភាពនៃនីតិវិធី និងការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

**១.១.៥.១ បុគ្គលមានអភ័យឯកសិទ្ធ**

អភ័យឯកសិទ្ធសំដៅដល់ លក្ខខណ្ឌពិសេសដែលច្បាប់បញ្ញត្តិសម្រាប់បុគ្គលមួយចំនួន ទាក់ទងនឹងនីតិវិធី ការទទួលខុសត្រូវព្រហ្មទណ្ឌ ការសម្រាលទោស ឬការលើកលែងទោសចំពោះបទល្មើសព្រហ្មទណ្ឌមួយចំនួនជាដើម។ ត្រង់ចំណុចនេះយើងនឹងលើកយកតែ អភ័យឯកសិទ្ធសភា និងអភ័យឯកសិទ្ធគ្រួសារមកបកស្រាយតែប៉ុណ្ណោះ។

- **អភ័យឯកសិទ្ធសភា៖** បុគ្គលដែលទទួលបានអភ័យឯកសិទ្ធសភា មានដូចជា តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។ ផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់ ចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រ នឹងអាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាក្នុងចន្លោះសម័យប្រជុំរបស់រដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង[51]។ ដូចនេះមានន័យថា ចំពោះតំណាងរាស្ត្រ ព្រះរាជអាជ្ញាមិនអាចសម្រេចធ្វើការចោទប្រកាន់បានភ្លាមនោះទេ ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែ រដ្ឋសភាអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល។ ផ្ទុយទៅវិញប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឲ្យផ្អាកតាមមតិភាគច្រើន បីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូលនោះព្រះរាជអាជ្ញាត្រូវតម្កល់រឿងទុកឥតចាត់ការសិន។ ប៉ុន្តែបើជាបទល្មើសជាក់ស្តែង ព្រះរាជអាជ្ញាអាចចោទប្រកាន់បាន។ ទោះជាត្រូវតម្កល់រឿងទុកឥតការក្នុងករណីខ្លះក៏ដោយ ក៏ព្រះរាជអាជ្ញា នៅ

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៨

[50] ច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦ មាត្រា៨

[51] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៨០

តែអាចសើរើសំណុំរឿងនោះមកចាត់ការនៅពេលក្រោយបានដដែលព្រោះថា ការតម្កល់រឿងទុករបស់ព្រះរាជអាជ្ញាគ្មានអាជ្ញាអស់ជំនុំទេ[52]។ ចំពោះសមាជិកព្រឹទ្ធសភាវិញ ក៏មានការអនុវត្តស្រដៀងគ្នានឹងតំណាងរាស្ត្រដែរ តែត្រូវសម្រេចដោយមតិភាគច្រើននៃសមាជិកព្រឹទ្ធសភា[53]។

- **អភ័យឯកសិទ្ធគ្រួសារ៖** ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬសហព័ទ្ធខ្លួន បុគ្គលនោះមិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌទេ[54]។ ដូចនេះព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានឡើយ ប៉ុន្តែករណីនេះអនុវត្តបានតែចំពោះបទល្មើសលួចតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌតែប៉ុណ្ណោះ តែបើជាការលួចដោយមានស្ថានទម្ងន់ទោស ឧទាហរណ៍មាត្រា ៣៥៧នៃក្រមព្រហ្មទណ្ឌជាដើម នោះព្រះរាជអាជ្ញានៅតែអាចធ្វើបណ្តឹងអាជ្ញាបានដដែល។

### ១.១.៥.២ មោឃៈភាពនៃនីតិវិធី

មោឃៈភាពនៃនីតិវិធីនៅក្នុងរឿងព្រហ្មទណ្ឌគឺ ជាភាពមិនស្របច្បាប់ដែលកើតឡើងដោយសារតែការមិនគោរពនូវវិធានដែលបានបញ្ញត្តិដោយក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីដែលព្រះរាជអាជ្ញាពិនិត្យឃើញថានៅក្នុងដំណើរការនៃការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែមរបស់មន្ត្រីនគរបាលយុត្តិធម៌ ធ្វើឡើងដោយមិនគោរពនូវទម្រង់ការដែលកំណត់ដោយច្បាប់ ហើយនាំឲ្យមានមោឃភាពនីតិវិធី នោះព្រះរាជអាជ្ញាអាចសម្រេចមិនចាត់ការលើបណ្តឹងអាជ្ញាបាន។

### ១.១.៥.៣ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់នូវមូលហេតុមួយចំនួននៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនល្មើស ដូចជា មូលហេតុវិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬការបង្ខំ និងករណីជនល្មើសជាអនីតិជនអាយុក្រោម១៤ឆ្នាំ។

- **វិបល្លាស្មារតី៖** កាលណាបើជនណាម្នាក់ប្រព្រឹត្តបទល្មើសនៅ ពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[55]។ បើក្នុងករណីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវដដែល តែតុលាការអាចពិចារណាពីស្ថានសម្រាល។ ប៉ុន្តែបើជននោះប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ ជននោះក៏មិនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ ការកំណត់អំពីវិបល្លាសស្មារតីនេះអាចត្រូវបានធ្វើដោយគ្រូពេទ្យជំនាញ។

---

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១

[53] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១០៤ ថ្មី

[54] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៥៥

[55] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣១

- **ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ៖** ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទេ។ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ហើយបុគ្គលនោះនៅតែប្រព្រឹត្តិ។ ប៉ុន្តែ ចំពោះចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចឲ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ ទោះក្នុងមូលហេតុណាក៏ដោយ[56]។
- **ការការពារស្របច្បាប់៖** បុគ្គលដែលប្រព្រឹត្តបទល្មើសក្នុងសភាពនៃការការពារស្របច្បាប់ នឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែត្រូវភ្ជាប់ជាមួយលក្ខខណ្ឌមួយចំនួនដូចជា៖ បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ ដើម្បីការពារខ្លួន អ្នកដ៏ទៃ ឬការពារទ្រព្យសម្បត្តិប្រឈមនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ ហើយបទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន[57]។
- **សច្ចធារណ៍នៃការការពារស្របច្បាប់៖** ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចជា៖ បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សរស់នៅ ហើយបទល្មើសបានប្រព្រឹត្តិ ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬប្លន់ដែលអនុវត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ[58]។
- **ស្ថានភាពចាំបាច់៖** ចំពោះបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពចាំបាច់ ដោយត្រូវតែប្រព្រឹត្តិបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ប៉ុន្តែស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចជា៖ បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវ ដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដ៏ទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់[59]។

[56] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣២

[57] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៣

[58] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៤

[59] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៥

- **អានុភាពនៃកម្លាំង ឬការបង្ខំ៖** បុគ្គលដែលប្រព្រឹត្តិបទល្មើសក្រោមអានុភាពនៃកម្លាំងបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ហើយត្រូវតែមិនអាចមើលឃើញមុនបាន និងមិនអាចជៀសវាងបាន[60]។
- **ករណីជនល្មើសជាអនីតិជនអាយុក្រោម១៨ឆ្នាំ៖** ក្នុងករណីអនីតិជនមានអាយុក្រោម១៨ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម[61]។

សរុបមកវិញ ប្រសិនបើមានករណី នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដូចដែលបានរៀបរាប់ខាងលើនេះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រោះមូលហេតុទាំងនេះ គឺជាអំពីយុត្តិកម្មមានន័យថាច្បាប់ចាត់ទុកអំពើទាំងនេះជាសកម្មភាពស្របច្បាប់ និងជាអំពើដែលមិនអាចទម្លាក់កំហុសបាន។

### ១.១.៦ ការថ្លឹងថ្លែងរបស់ព្រះរាជអាជ្ញាចំពោះការតម្កល់រឿងទុកឥតចាត់ការ

តាមរយៈគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ព្រះរាជអាជ្ញានឹងប្រើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចមិនចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយបាន ទោះបីជាអំពើនោះមានចែងក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ដោយឡែកផ្សេងទៀតក៏ដោយ។ ជាគោលការណ៍មុននឹងតម្កល់រឿងទុកព្រះរាជអាជ្ញាអាចពិចារណាទៅលើស្ថានភាពមួយចំនួនដូចជា៖

- **តុល្យភាពនៃការផ្តន្ទាទោស និងទំហំនៃព្យសនកម្ម៖** ព្រះរាជអាជ្ញាត្រូវពិនិត្យអំពីតុល្យភាពនៃការផ្តន្ទាទោស និងទំហំព្យសនកម្ម របស់ជនរងគ្រោះ និងសង្គមជាតិទាំងមូលដែរទទួលរង។ ឧទាហរណ៍៖ ករណីលួច ផ្លែស្វាយ២ ទៅ ៣ផ្លែ ដើម្បីទទួលទាន បើយើងពិនិត្យទៅឃើញថាមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ដែល អាចឲ្យព្រះរាជអាជ្ញាយកធ្វើជាមូលដ្ឋានដើម្បីធ្វើការចោទប្រកាន់បាន ប៉ុន្តែក្នុងស្ថានភាពនេះ ព្រះរាជអាជ្ញាអាចពិចារណាថ្លឹងថ្លែងបានថា តើជនរងគ្រោះ និងសង្គមជាតិទាំងមូល បានទទួលរងព្យសនកម្មធ្ងន់ធ្ងរកម្រិតណា ដោយគ្រាន់តែលួចស្វាយ ២ ឬ៣ផ្លែ? តើការផ្តន្ទាទោសទៅលើជនល្មើស អាចផ្តល់ផលចំណេញដល់សង្គមជាតិដែរឬទេ? បើមានការចោទប្រកាន់ និងផ្តន្ទាទោសមែន តើរដ្ឋនឹងត្រូវចំណាយថវិកាប៉ុន្មានដើម្បីចិញ្ចឹមទណ្ឌិត? ដែលទាំងនេះគឺមូលហេតុមួយចំនួនដែលព្រះរាជអាជ្ញាគួរធ្វើការពិចារណា។

---

[60] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៣៦

[61] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ មាត្រា២៧ កថាខណ្ឌទី១

- **ស្ថានភាពរបស់ជនរងគ្រោះ៖** ភ្ជាប់ទៅនឹងករណីលួចស្វាយខាងលើ ព្រះរាជអាជ្ញាក៏ត្រូវពិចារណាពីស្ថានភាពរបស់ជនរងគ្រោះផងដែរ តើជនរងគ្រោះមានការទាមទារអ្វីដែរឬទេ? បើជនរងគ្រោះមិនអើពើទៅនឹងការលួចស្វាយរបស់ខ្លួនផង តើព្រះរាជអាជ្ញាគួរចូលធ្វើអន្តរាគមន៍ដើម្បីផ្តន្ទាទោសជនល្មើសដែរឬទេ?
- **ស្ថានភាពរបស់ជនល្មើស៖** ក្នុងករណីដដែលនេះ ព្រះរាជអាជ្ញាក៏ត្រូវពិចារណាអំពីស្ថានភាពរបស់ជនល្មើសផងដែរថា តើជនល្មើស បានប្រព្រឹត្តិអំពើនេះប៉ុន្មានលើកហើយ? ជនល្មើសជានីតិជន ឬអនីតិជន? តើជនល្មើសមានអាកប្បរិយាទទួលស្គាល់នូវកំហុសរបស់ខ្លួនដែរឬទេ? ព្រះរាជអាជ្ញាគួរតែធ្វើការណែនាំនិងព្រមាន កុំឲ្យជនល្មើសប្រព្រឹត្តអំពើបែបនេះតទៅទៀត។
- **ការជួសជុលព្យសនកម្ម៖** ប្រសិនបើព្រះរាជអាជ្ញាពិនិត្យឃើញថា ព្យសនកម្មដែលបង្កឡើងពីអំពីល្មើសមានលក្ខណៈតិចតួច ដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់ជនរងគ្រោះ និងសង្គមទាំងមូល ហើយជនរងគ្រោះនិងជនល្មើល ព្រមព្រៀងគ្នាលើសំណង់រដ្ឋប្បវេណី នោះព្រះរាជអាជ្ញាអាចយកមូលហេតុនេះដើម្បីជាមូលដ្ឋាន ក្នុងការតម្កល់រឿងទុកឥតចាត់ការបាន។
- **ការជះឥទ្ធិពលពីសង្គម៖** ព្រះរាជអាជ្ញាក៏ត្រូវប៉ាន់ប្រមាណមើលផងដែរនូវ ការជះឥទ្ធិពលពីសង្គមមកលើការធ្វើបណ្តឹងអាជ្ញា។ ជាការពិតណាស់ការសម្រេចអំពីបណ្តឹងអាជ្ញា គឺជាឆន្ទានុសិទ្ធរបស់ព្រះរាជអាជ្ញា ប៉ុន្តែករណីមួយចំនួនដែលបង្កជាបទល្មើស តែសង្គមទាំងមូលបែរជាយល់ថាជារឿងដែលមិនគួរចោទប្រកាន់ទៅវិញ ឧទាហរណ៍៖ ក្នុងករណីដែលមានការរួមភេទរវាង ក្មេងប្រុសអាយុ១៨ឆ្នាំ និងក្មេងស្រីអាយុ១៥ឆ្នាំជាដើម បើពិនិត្យមើលទៅឃើញថាករណីនេះជាបទល្មើសរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ដែលក្មេងស្រីអាយុ១៥ឆ្នាំអាចប្រឈមនឹងការផ្តន្ទាទោស[62]។ ត្រង់ចំណុចនេះព្រះរាជអាជ្ញាអាចថ្លឹងថ្លែងពិចារណាថា តើគួរចោទប្រកាន់ក្មេងស្រីនោះឬទេ? តើការចោទប្រកាន់ផ្តល់ផលប្រយោជន៍ដល់សង្គមឬទេ? ហើយប្រសិនបើចោទប្រកាន់តើនឹងមានការទទួលរងឥទ្ធិពលពីសង្គមយ៉ាងដូចម្តេចខ្លះ? ដូច្នេះការជះឥទ្ធិពលពីសង្គមក៏ ជាមូលហេតុជំរុញឲ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការផងដែរ។

សរុបមកការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ទៅលើបទល្មើសព្រហ្មទណ្ឌ គឺត្រូវពិចារណាទៅលើស្ថានភាពមួយចំនួនដូចបានបកស្រាយខាងលើ ទន្ទឹមនឹងនេះការតម្កល់រឿងទុករបស់ព្រះរាជអាជ្ញាផ្អែកតាមគោលការណ៍កាលានុវត្តភាពនេះគឺ ជាវិធានដែលមានលក្ខណៈបត់បែន។

[62] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា៤២

## ១.២ ការប្ដឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកមិនចាត់ការត្រូវធ្វើឡើង ដោយសេចក្ដីសម្រេចដែលមានសំអាងច្បាប់ និងសំអាងហេតុ ហើយព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្ដឹង អំពីការសម្រេចតម្កល់រឿងទុកនេះ នៅក្នុងរយៈពេលខ្លីបំផុត ហើយយូរបំផុតរយៈពេល២ខែ គិតចាប់ពីថ្ងៃចុះពាក្យប្ដឹងក្នុងបញ្ជីនៃពាក្យប្ដឹង [63] ។ បើទោះបីជាការតម្កល់រឿងទុកជា សិទ្ធិសម្រេចរបស់ព្រះរាជអាជ្ញាក៏ដោយ ក៏សេចក្ដីសម្រេចនេះពុំមានលក្ខណៈដាច់ខាតទេ ពោលគឺអាចប្ដឹងតវ៉ាបាន។

### ១.២.១ ដីកាតម្កល់រឿងទុកឥតចាត់ការ

ក្នុងការសម្រេចតម្កល់រឿងទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវចេញលិខិតនៃកិច្ចនីតិវិធីមួយ គឺដីកាតម្កល់រឿងទុកឥតចាត់ការ ដែលមានខ្លឹមសារដូចជា៖

- អត្តសញ្ញាណរបស់អ្នកប្ដឹង
- កាលបរិច្ឆេទដែលព្រះរាជអាជ្ញាទទួលពាក្យប្ដឹង
- ប្រភពនៃពាក្យប្ដឹងផ្ទាល់មាត់ ឬមកពីមន្ត្រីនគរបាលយុត្តិធម៌
- ប្រភេទនៃរឿងហេតុដែលអ្នកប្ដឹងបានរាយការណ៍។

បន្ថែមពីនោះដីកានេះព្រះរាជអាជ្ញាត្រូវភ្ជាប់មក ជាមួយមូលហេតុដែលតម្កល់រឿងទុក នឹងត្រូវមានសំអាងហេតុ និងសំអាងច្បាប់។ ដីកាតម្កល់រឿងទុកឥតចាត់ការ គ្មានអាជ្ញាអស់ជំនុំទេ ព្រះរាជអាជ្ញាអាចសើរើកែប្រែនូវសេចក្ដីសម្រេចនេះឡើងវិញបាន ប្រសិនបើបណ្ដឹងអាជ្ញាមិនទាន់ផុតរលត់[64]។ ម្យ៉ាងវិញទៀតដីកាតម្កល់រឿងទុកឥតចាត់ការនឹង ត្រូវបញ្ជូនទៅអ្នកប្ដឹង ក្នុងរយៈពេលកំណត់ដូចបានរៀបរាប់ខាងលើ។

### ១.២.២ នីតិវិធីនៃការប្ដឹងតវ៉ា

បន្ទាប់ពីទទួលបាននូវសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញា អ្នកប្ដឹងឬជនរងគ្រោះដែលមិនពេញចិត្តនឹងការតម្កល់រឿងទុកនេះ អាចការប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ដែលបែបបទនិងនីតិវិធីនៃការប្ដឹងមានដូចខាងក្រោម៖

#### ១.២.២.១ ការប្ដឹងតវ៉ានៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ដូចដែលបានបកស្រាយខាងលើ អ្នកប្ដឹងឬជនរងគ្រោះអាចដាក់ពាក្យប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បានបើខ្លួនមិនពេញនឹងសេចក្ដីសម្រេចតម្កល់រឿងទុករបស់ព្រះរាជអាជ្ញាទេ។ ប៉ុន្តែការតវ៉ានេះត្រូវធ្វើក្នុងរយៈពេល២ខែ ដោយគិតពីថ្ងៃដែលទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការពី

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី១

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី៣

ព្រះរាជអាជ្ញា។ ជាដំបូងអ្នកប្ដឹងឬជនរងគ្រោះត្រូវដាក់ពាក្យប្ដឹង ដែលជាបណ្ដឹងសាមញ្ញទៅកាន់អយ្យការអមសាលាដំបូងដែលតម្កល់រឿងទុកឥតចាត់ការនោះ។ បន្ទាប់មកពាក្យប្ដឹងនោះនឹងត្រូវបានបញ្ជូនភ្លាមដោយតំណាងអយ្យការអមសាលាដំបូង ទៅកាន់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា[65]។ ហើយក្រោយពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទទួលបាននូវពាក្យប្ដឹងតវ៉ា នោះអគ្គព្រះរាជអាជ្ញានឹងធ្វើការសម្រេចអំពីរឿងនេះ ដែលការសម្រេចនេះអាចស្ដែងចេញក្រោមរូបភាពពីយ៉ាង៖

- ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថា ការប្ដឹងតវ៉ានេះមានមូលហេតុត្រឹមត្រូវដែលគួរធ្វើការចោទប្រកាន់ នោះអគ្គព្រះរាជអាជ្ញានឹងធ្វើអធិបញ្ញាជាលាយ លក្ខណ៍អក្សរ ដោយបញ្ជាមកព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការសើរើសំណុំរឿងនោះមកធ្វើការចោទប្រកាន់វិញបាន។
- ប៉ុន្តែក្នុងករណីដែលអគ្គព្រះរាជអាជ្ញា យល់ស្របចំពោះការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាដោយទុកជាបានការ នោះអគ្គព្រះរាជអាជ្ញាត្រូវឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់ខ្លួនដល់អ្នកប្ដឹង[66]។

ដូចនេះកាលណាអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ បញ្ជាឱ្យព្រះរាជអាជ្ញាចោទប្រកាន់ នោះព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ បើទោះបីជាព្រះរាជអាជ្ញាយល់ឃើញផ្សេងពីនេះក៏ដោយព្រោះនេះជាគោលការណ៍ឋានានុក្រម ប៉ុន្តែនៅពេលសវនាការព្រះរាជអាជ្ញាអាចធ្វើការកត់សម្គាល់ផ្ទាល់មាត់ដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន។ ហើយគ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលត្រូវធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាចាររបស់ខ្លួន ដែលបានបញ្ចេញនូវពេលសវនាការសោះឡើយ[67]។ ដោយឡែកក្នុងករណីដែលអគ្គព្រះរាជអាជ្ញា យល់ស្របតាមសេចក្ដីសម្រេចតម្កល់រឿងទុករបស់ព្រះរាជអាជ្ញា នោះអ្នកប្ដឹងឬជនរងគ្រោះអាចដាក់ពាក្យប្ដឹងដោយតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទៅកាន់ចៅក្រមស៊ើបសួរបាន ប្រសិនបើខ្លួននៅតែមិនពេញចិត្តទៅនឹងការសម្រេចរបស់អគ្គព្រះរាជអាជ្ញា។

### ១.២.២.២ ការប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ចំពោះករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ យល់ស្របចំពោះសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញា ហើយបដិសេធពាក្យប្ដឹងតវ៉ារបស់ អ្នកប្ដឹង នោះអ្នកប្ដឹងអាចអនុវត្តនីតិវិធីមួយផ្សេងទៀត ដែលផ្ដល់ឱ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌ គឺការដាក់ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ សម្រាប់នីតិវិធីជាដំបូងត្រូវដាក់ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទៅចៅក្រមស៊ើបសួរ ដោយពាក្យប្ដឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវីបាន។

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី៥

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤១ កថាខណ្ឌទី៦

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៩

ក្រោយពីទទួលបានពាក្យប្ដឹង ចៅក្រមស៊ើបសួរត្រូវកត់សម្គាល់នូវពាក្យប្ដឹងនោះតាមដីកា ហើយបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា។ ចំណែកឯព្រះរាជអាជ្ញាក្រោយពីទទួលបានពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវពិនិត្យទៅលើបណ្ដឹងនេះរួចធ្វើសេចក្ដីសម្រេច។ ការសម្រេចរបស់ព្រះរាជអាជ្ញាអាចស្ដែងចេញតាមរូបភាពពីរយ៉ាង៖

- ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា រឿងហេតុនៅក្នុងបណ្ដឹងនេះគួរតែធ្វើការចោទប្រកាន់ នោះព្រះរាជអាជ្ញាអាចបើកធ្វើការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលស្ថានភាពនេះបានចូលជាការបើកការស៊ើបសួរតាមផ្លូវធម្មតាវិញ។
- បើក្នុងករណីដែលព្រះរាជអាជ្ញាមិនឯកភាព ចំពោះបណ្ដឹងនេះ នោះព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរបាន។

កាលណាព្រះរាជអាជ្ញាស្នើសុំចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ នោះចៅក្រមស៊ើបសួរមានជម្រើសពីរយ៉ាងដើម្បីសម្រេចលើរឿងនេះ៖

- បើចៅក្រមស៊ើបសួរ ឯកភាពតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ដោយសម្រេចមិនធ្វើការស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។
- ប្រសិនបើចៅក្រមស៊ើបសួរ នៅតែសម្រេចស៊ើបសួរ នោះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ និងជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា[68]។

នៅពេលដែលចៅក្រមស៊ើបសួរនៅតែសម្រេចបើកការស៊ើបសួរតាមបណ្ដឹងនោះ ចៅក្រមស៊ើបសួរត្រូវអនុវត្តនីតិវិធីដូចតទៅ៖

- **ការបង់ប្រាក់តម្កល់ទុក៖** ដោយផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុនចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេច នូវចំនួនទឹកប្រាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវប្រាក់នេះផង[69]។ ការបង់ប្រាក់តម្កល់ទុកនេះធ្វើឡើងក្នុងគោលបំណងដើម្បីការពារនូវស្ថានភាពដែលអាចកើតមានឡើង ដូចជាក្នុងករណីដែលមានការធ្វើបណ្ដឹងដោយបំពានជាដើម[70]។ ប៉ុន្តែបើពិនិត្យឃើញថាដើមបណ្ដឹងរដ្ឋប្បវេណីពុំមានលទ្ធភាពបង់ប្រាក់តម្កល់ទុកទេ នោះចៅក្រមស៊ើបសួរអាចពិចារណាលើកលែងមិនឱ្យបង់ប្រាក់នេះបាន។ ដីកានេះ

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៣៨

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៤០ កថាខណ្ឌទី១

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៤១

ត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយឡែកក្នុងករណីដែលមានដីកាតម្រូវឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុក តែដើមបណ្តឹងមិនបានបង់ប្រាក់នៅក្នុងរយៈពេលដែលកំណត់ដោយដីកា នោះពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ មានន័យថាចៅក្រមស៊ើបសួរបដិសេធនូវបណ្តឹងនោះ។ ប៉ុន្តែចៅក្រមស៊ើបសួរត្រូវ ជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងតាមរយៈដីកាសម្រេច។ ម្យ៉ាងវិញទៀតប្រាក់តម្កល់ទុកនេះនឹងត្រូវប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណីវិញនៅពេលបញ្ចប់នីតិវិធី លើកលែងតែប្រាក់តម្កល់នេះត្រូវកាត់យកក្នុងករណីដែលមានបណ្តឹងដោយបំពាន ឬបណ្តឹងដោយអូសបន្លាយពេលវេលា។

- **ករណីមានបណ្តឹងដោយបំពាន ឬបណ្តឹងអូសបន្លាយពេលវេលា៖** ក្នុងករណីដែលការស៊ើបសួរត្រូវបានបិទបញ្ចប់ទៅវិញ ហើយពិនិត្យឃើញថាគ្មានបទល្មើសព្រហ្មទណ្ឌ នោះការធ្វើបណ្តឹងត្រូវចាត់ទុកជាបណ្តឹងដែលធ្វើឡើងដោយបំពាន ឬមានលក្ខណៈអូសបន្លាយ[71]។ ការធ្វើបណ្តឹងដោយបំពានឬអូសបន្លាយ អាចនាំឱ្យមានការប៉ះពាល់ដល់ជនទាំងឡាយ ដែលពាក់ព័ន្ធក្នុងសំណុំរឿង ហើយបើករណីនេះកើតឡើងនោះវិធានការ២ យ៉ាងអាចនឹងត្រូវបានអនុវត្ត៖
    - ប្រាក់តម្កល់ទុកដែលចៅក្រមស៊ើបសួរ សម្រេចឱ្យតម្កល់ទុកនោះ នឹងត្រូវបានកាត់យកក្នុងន័យជាទណ្ឌកម្មរដ្ឋប្បវេណី (ពិន័យរដ្ឋប្បវេណី) ដោយចៅក្រមស៊ើបសួរអាចសម្រេចឱ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យ តាមរយៈការរឹបអូសយកប្រាក់តម្កល់ទុក។ ប៉ុន្តែចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះ ត្រូវឱ្យដល់សាមីខ្លួនជាបន្ទាន់[72]។
    - បណ្តឹងនេះអាច ធ្វើឱ្យប៉ះពាល់ទៅដល់បុគ្គលមួយចំនួនដែលត្រូវបានបញ្ជាក់ឈ្មោះនៅក្នុងសំណុំរឿង នៃពាក្យប្តឹងនោះ។ ក្នុងករណីដែលមានការបិទបញ្ចប់កិច្ចស៊ើបសួរដោយការលើកលែងចោទប្រកាន់ក្នុងករណីប្រភេទនេះចូលជាស្ថាពរ ជនទាំងឡាយដែលមានឈ្មោះនៅក្នុងពាក្យប្តឹង អាចប្តឹងសុំការជួសជុលសំណងពីអ្នកដែលប្តឹងខ្លួនបាន[73]។

តាមរយៈដំណើរការនៃនីតិវិធីបានបង្ហាញឱ្យយើងឃើញថា វិធីដែលច្បាស់លាស់ចំពោះការបើកការស៊ើបសួរ គឺជាវិធីនៃ ការបើកធ្វើការស៊ើបសួរដោយអយ្យការតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ប៉ុន្តែក្នុងករណីលើកលែងបំផុត ជនរងគ្រោះត្រូវថ្លឹងថ្លែងឱ្យបានច្បាស់លាស់អំពីបញ្ហាដែលត្រូវ

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៤១

[72] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៤១

[73] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៤២ កថាខណ្ឌទី១

ប្រឈម ក្នុងករណីដែលបណ្តឹងនោះត្រូវបានលើកលែងចោទប្រកាន់វិញដោយចៅក្រមស៊ើបសួរ ក្នុងក្របខណ្ឌនេះជនរងគ្រោះអាចធ្វើបណ្តឹងនេះបានតែក្នុងករណីដែលខ្លួនជឿជាក់ច្បាស់លាស់ថាមានបទល្មើសព្រហ្មទណ្ឌ។

## ១.៣ អធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គការអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់[74]។ ចំណែកលក្ខខណ្ឌ និងនីតិវិធីមានដូចតទៅ៖

### ១.៣.១ លក្ខខណ្ឌនៃការធ្វើអធិបញ្ញា

ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើការប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានដឹង ដោយធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។ ចំពោះប្រភពនៃ បទល្មើសដែលរដ្ឋមន្ត្រីបានដឹង ក្រមនេះមិនបានបញ្ជាក់ច្បាស់លាស់ទេ ប៉ុន្តែព័ត៌មានអំពីបទល្មើសអាចត្រូវបានដឹងតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយ ឬក៏តាមរយៈការប្តឹងរបស់ជនរងគ្រោះជនដើម។ ថ្វីត្បិតតែក្រមនេះមិនបានបញ្ជាក់ថាជនរងគ្រោះអាចដាក់ពាក្យប្តឹងទៅរដ្ឋមន្ត្រី ក៏ពិតមែន ប៉ុន្តែករណីនេះអាចនឹងកើតឡើងប្រសិនបើមានភាពអសកម្មរបស់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ក្នុងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ហើយបើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរត្រូវបានច្រានចោលទៀតនោះ ផ្លូវចុងក្រោយរបស់ជនរងគ្រោះប្រាកដជាការប្តឹងទៅរដ្ឋមន្ត្រីក្រសួងយុត្តធម៌។ យើងអាចពិចារណាបានថា ហេតុអ្វីបានជាច្បាប់កំណត់ឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជានាយឋានានុក្រមរបស់អង្គការអយ្យការ? ជាការពិតណាស់ហេតុផលដែលយើងអាចពិចារណាបាននោះ គឺដើម្បីធានា និងរក្សា នូវការប្រព្រឹត្តិទៅល្អនៃវិស័យយុត្តិធម៌ ជាពិសេសជៀសវាង និងទប់ស្កាត់នូវភាពអសកម្មដែលនឹងអាចបង្កឡើង។ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល និងជាអ្នកសម្របសម្រួល និងអន្តរាគមន៍ ការពារនូវសណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាផលប្រយោជន៍សង្គម ពិសេសការស្វែងរកយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋ គឺជាមុខការរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប៉ុន្តែនេះគ្រាន់តែជាការបកស្រាយមួយជ្រុងនៃទ្រឹស្តីតែប៉ុណ្ណោះ តែបើតាមស្ថានភាពជាក់ស្តែង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ធ្វើអធិបញ្ញាតែក្នុងករណីដែលបទល្មើស មានចរិកគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរប៉ុណ្ណោះ។

[74] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា៧៥

### ១.៣.២ នីតិវិធីនៃការធ្វើអធិបញ្ញា

ចំពោះអធិបញ្ញាជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងដើម្បីឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ[75]។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើការធ្វើអធិបញ្ញានេះ[76]។

## ២. ការសម្រេចចោទប្រកាន់

ព្រះរាជអាជ្ញា មានមធ្យោបាយច្រើនដើម្បីធ្វើបណ្តឹងអាជ្ញា។ ការជ្រើសរើសទាំងនេះអាស្រ័យលើស្ថានភាពនៃសំណុំរឿងនីតិវិធី។ ហើយភាពចាំបាច់នេះអាចជាកាតព្វកិច្ចដោយអាស្រ័យលើប្រភេទបទល្មើសដែលពាក់ព័ន្ធ។ បន្ថែមពីនោះ ទោះជាព្រះរាជអាជ្ញា ប្តឹងទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិកាជំនុំជំរះក៏ដោយ ក៏ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានចេញលិខិតនៃកិច្ចនីតិវិធី ដែលមានចុះនិទ្ទេសផ្សេងៗ ដូចជា អំពើដែលចោទប្រកាន់ទៅបុគ្គលមានអត្តសញ្ញាណ ឬអញ្ញាតជន ឈ្មោះបទល្មើស អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសជាដើម។ ទន្ទឹមនឹងនេះនៅពេលបុគ្គលម្នាក់ ត្រូវបានចោទប្រកាន់ និងទទួលឋានៈជាជនជាប់ចោទ ជននេះត្រូវតែទទួលបានដំណឹងអំពីការបង្ក្រាបនេះ មានន័យថា ទទួលដំណឹងពីការចោទប្រកាន់ដែលប្រឆាំងនឹងខ្លួន[77]។ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចធ្វើការចោទកាន់តាមវិធី៣យ៉ាងគឺៈ

- ការបើកការស៊ើបសួរ
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ឬ
- តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[78]។

### ២.១ ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរគឺជាវិធីមួយនៃការធ្វើបណ្តឹងរបស់ព្រះរាជអាជ្ញា តាមរយៈកិច្ចនីតិវិធីមួយគឺដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលជាភាសាកាត់ហៅថា (RI)។ ការបើកការស៊ើបសួររបស់ព្រះរាជអាជ្ញា គឺជាការចាប់ផ្តើមនៃតួនាទី និងអំណាចរបស់ចៅក្រមស៊ើបសួរ ក្នុងដំណើរការស៊ើបសួរស្វែងរកនូវការពិតនៅក្នុងសំណុំរឿង។ ខុសពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរមិនរណបអោយស្ថាប័នណាឡើយ ការសម្រេចរបស់ចៅក្រមធ្វើឡើងដោយឯករាជ្យ ក្នុងគោលបំណងស្វែងរក ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ពោលគឺស្វែង

---

[75] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៩ កថាខណ្ឌទី១

[76] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤ មាត្រា៧៥

[77] សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យ ហ៊ី សោភា

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៣

រកឱ្យឃើញនូវការពិតនៃរឿង។ ប៉ុន្តែទន្ទឹមនឹងនេះការស៊ើបសួរ ក៏តម្រូវឱ្យព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រូវតែគោរពនូវ លក្ខណ្ឌមួយចំនួនដែលច្បាប់បានបញ្ញត្តផងដែរ។

### ២.១.១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ជាទូទៅការស៊ើបសួរនឹងត្រូវបើក ដោយដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងន័យនេះចៅក្រមស៊ើបសួរមិនអាចបំពេញ កិច្ចស៊ើបសួរណាមួយបានឡើយបើគ្មានដីកានេះ លើកលែងតែក្នុងករណីដែលមានពាក្យប្តឹងដោយមាន ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវមានទម្រង់ដូចតទៅ៖

- **សេចក្តីសង្ខេបអង្គហេតុ៖** គឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់ចៅក្រមស៊ើបសួរ ក្នុងការកំណត់ថា អង្គហេតុណាដែលត្រូវស៊ើបសួរ ព្រោះចៅក្រមស៊ើបសួរអាចស៊ើបសួរបានតែទៅលើអង្គហេតុដែលមាន នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះ។
- **ការកំណត់ឈ្មោះបទល្មើស៖** ឈ្មោះបទល្មើសគឺជា ផ្នែកមួយដ៏សំខាន់ផងដែរ សម្រាប់ការស៊ើបសួរ ព្រោះ បើគ្មានការកំណត់ឈ្មោះបទល្មើសណាមួយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេ នោះមានន័យថា ព្រះរាជអាជ្ញាមិនបានធ្វើការចោទប្រកាន់ទេ ។ ម៉្យាងទៀតចៅក្រមស៊ើបសួរក៏មិនដឹងថាត្រូវ ស៊ើបសួរចំពោះបទល្មើសអ្វីដែរ។
- **ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស៖** ជាទូទៅដើម្បីកំណត់ថាអំពើមួយជាបទល្មើសព្រហ្មទណ្ឌ លុះត្រាតែអំពីនោះមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌជាធរមាន ហើយក្នុងករណីដែលព្រះរាជអាជ្ញាមិនមានសរសេរនូវអត្ថបទច្បាប់ដែលកំណត់អំពីបទល្មើសទេ នោះបានសេចក្តីថាការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺគ្មានមូលដ្ឋានគ្រប់គ្រាន់នោះទេ។
- **ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ៖** ចំណុចនេះពុំមានលក្ខណៈដាច់ខាតទេ ឈ្មោះជនត្រូវចោទអាចនឹងត្រូវបានសរសេរប្រសិនបើមានការកំណត់នូវអត្តសញ្ញាណរបស់ជននោះបាន។ ប៉ុន្តែក្នុងករណីដែលមិនអាចកំណត់អត្តសញ្ញាណរបស់ជនល្មើសបាន នោះព្រះរាជអាជ្ញានូវតែអាចបើកការស៊ើបសួរចំពោះអញ្ញាតជនបានដដែល។

ដីកានេះត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខារបស់តំណាងអយ្យការ។ ទម្រង់ការទាំងនេះមានលក្ខណៈ

ដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ[79] ឧទាហរណ៍៖ ក្នុងករណីដែលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មិនមានហត្ថលេខារបស់តំណាងអយ្យការ នោះដីកាត្រូវទុកជាមោឃៈតែម្តង។

**២.១.២ លក្ខខណ្ឌនៃការបើកកិច្ចស៊ើបសួរ**

ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់លក្ខខណ្ឌដោយតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ចំពោះបទឧក្រិដ្ឋ[80]។ ប៉ុន្តែទន្ទឹមនឹងនេះព្រះរាជអាជ្ញាក៏ អាចបើកការស៊ើបសួរចំពោះបទមជ្ឈិមផងដែរ ដែលលក្ខខណ្ឌទាំងនេះមានដូចតទៅ៖

- **បទឧក្រិដ្ឋ៖** ជាកាតព្វកិច្ចតែម្តង ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ ព្រោះបើយើងពិចារណាទៅ បទឧក្រិដ្ឋជាបទល្មើសដែលមានការផ្តន្ទាទោសធ្ងន់ធ្ងរ ដែលអតិបរមានៃទោសដាក់ពន្ធនាគារ អាចមានរយៈពេលលើសពី៥ឆ្នាំ និងក្រោមឬស្មើនឹង៣០ឆ្នាំ ឬអាចត្រូវជាប់ពន្ធនាគារអស់មួយជីវិតតែម្តង[81]។ ដូចនេះដើម្បីជៀសវាងនូវ ការកាត់ក្តីដោយភ័ន្តច្រឡំ និងដើម្បីការពារសិទ្ធសេរីភាពរបស់ជនត្រូវចោទ ក្រមនេះបានកំណត់ឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរដែលជាចៅក្រមឯករាជ្យ មានសិទ្ធអំណាចស៊ើបសួរស្វែងរកនូវការពិតនៃសំណុំរឿង ពោលគឺស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក។ ការស៊ើបសួរនេះនឹងធានាបន្ថែមនូវភាពច្បាស់លាស់ នៃសំណុំរឿង មុនបញ្ជូនទៅជំនុំជម្រះ ម៉្យាងវិញទៀតដើម្បីធានាឱ្យមានការជម្រះក្តីមួយប្រកបនូវភាពត្រឹមត្រូវ និងយុត្តិធម៌ ចៅក្រមស៊ើបសួរ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការជំនុំជម្រះចំពោះរឿងក្តីដែលខ្លួនបានស៊ើបសួរឡើយ បើពុំដូច្នេះទេ ការជំនុំជម្រះនឹងត្រូវចាត់ទុកជាមោឃៈ[82]។
- **បទមជ្ឈិម៖** ចំពោះបទមជ្ឈិមព្រះរាជអាជ្ញាអាចធ្វើការស៊ើបសួរក៏បាន ឬមិនស៊ើបសួរក៏បាន ប៉ុន្តែព្រះរាជអាជ្ញាត្រូវពិនិត្យឱ្យបានច្បាស់លាស់ពី ស្ថានភាពនៃសំណុំរឿង។ តួយ៉ាងដូចជាក្នុងករណីដែលសំណុំរឿងលក្ខណៈស្មុគស្មាញ ឬសំណុំរឿងមិនទាន់មូលសព្វគ្រប់ ឬជនល្មើសជាអញ្ញាតជន នោះព្រះរាជអាជ្ញាអាចសម្រេចបើកការស៊ើបសួរវិញ។

**២.១.៣ នីតិវិធីនៃការបើកការស៊ើបសួរ**

ដូចដែលយើងដឹងហើយថា ស្ថាប័នអយ្យការប្រៀបដូចជាស្ថាប័នកណ្តាល ក្នុងការទទួលនូវរាល់ព័ត៌មានទាំងអស់ទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញាអាចទទួលបាននូវរាល់ព័ត៌មានព្រហ្មទណ្ឌ

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៥

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៤

[81] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា៤៦

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៥៥

តាមរយៈសំណុំរឿងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ ការទទួលពាក្យប្តឹងដោយផ្ទាល់ ឬព័ត៌មានដែលជាពាក្យចាមអារាមក៏ព្រះរាជអាជ្ញាអាចទទួលបានដែរ។ ត្រង់ចំណុចនេះព្រះរាជអាជ្ញានឹងធ្វើការថ្លឹងថ្លែងចំណាត់ការទៅលើ ព័ត៌មាននៃសំណុំរឿងនីមួយៗដែលទទួលបាន។

### ២.១.៣.១ ការទទួលបានពាក្យប្តឹងដោយផ្ទាល់ ឬពាក្យចចាមអារាម

នៅពេលដែលព្រះរាជអាជ្ញាទទួលបាននូវពាក្យប្តឹងដោយផ្ទាល់ពីជនរងគ្រោះ ឬតតិយជន ឬបានដឹងនូវព័ត៌មានជាពាក្យចចាមអារាមជាដើម ព្រះរាជអាជ្ញាអាចបញ្ជាឱ្យមន្ត្រីនគរបាលយុត្តិធម៌បើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យមានការស្រាវជ្រាវបន្ថែម [83] ដើម្បីអាចឱ្យព្រះរាជអាជ្ញាមានមូលដ្ឋានគ្រប់គ្រាន់នៅក្នុងការសម្រេចអំពីបណ្តឹងអាជ្ញា។ បន្ថែមពីនោះព្រះរាជអាជ្ញាក៏អាចកោះហៅ ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ដើម្បីសួរ និងស្តាប់ចម្លើយដោយផ្ទាល់បានផងដែរប្រសិនបើយល់ថាចាំបាច់។ បន្ទាប់ពីថ្លឹងថ្លែងនូវ លទ្ធផលនៃការស៊ើបអង្កេត ឬស្រាវជ្រាវបន្ថែម បូករួមនិងលទ្ធផលដែលទទួលបានផ្សេងៗទៀត បើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងមានមូលដ្ឋាន និងមានលក្ខខណ្ឌគ្រាន់ដើម្បីធ្វើបណ្តឹង នោះព្រះរាជអាជ្ញាអាចជ្រើសរើសវិធីនៃការចោទប្រកាន់តាមការបើកការស៊ើបសួរបាន តែក៏ត្រូវពិនិត្យមើលនូវលក្ខខណ្ឌដែរ គួយ៉ាងដូចជា ប្រភេទបទល្មើសជាបទឧក្រិដ្ឋ ឬបទល្មើសមានលក្ខណៈស្មុគស្មាញជាដើម។

### ២.១.៣.២ ការទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌

ចំពោះសំណុំរឿងដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ ភាគច្រើនអាចជាពាក្យប្តឹងបរិហារ និងប្តឹងទាមទារក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ បន្ថែមពីនេះក្នុងករណីមានបទល្មើសព្រហ្មទណ្ឌជាក់ស្តែង មន្ត្រីនគរបានយុត្តិធម៌ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាផងដែរ[84]។ ក្នុងករណីដែលមានពាក្យប្តឹង ព្រះរាជអាជ្ញាអាចចាត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ស៊ើបអង្កេតបឋម ឬស្រាវជ្រាវបន្ថែមទៅលើ ពាក្យប្តឹងទាំងនោះបាន រូបភាពត្រង់នេះអាចស្តែងចេញតាមរយៈ ការសុំចំណាត់ការទៅព្រះអាជ្ញាទៅលើពាក្យប្តឹង មានន័យថា នគរបាលយុត្តិធម៌ សុំការសម្រេចពីព្រះរាជអាជ្ញាទៅលើពាក្យបណ្តឹង តើគួរបើកការស៊ើបអង្កេតបឋម ឬយ៉ាងណា? ក្នុងករណីនេះព្រះរាជអាជ្ញាអាចសម្រេចឱ្យធ្វើការស៊ើបអង្កេតបានបើយល់ឃើញថាចាំបាច់។ ប៉ុន្តែក្នុងករណីមួយចំនួនទៀតនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមដោយខ្លួនឯងបានដោយ មិនចាំបាច់មានការអនុញ្ញាតពីព្រះរាជអាជ្ញាឡើយ[85]។ នៅពេលបញ្ចប់ការស៊ើបអង្កេត នគរបាលយុត្តិធម៌ នឹងបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ហើយជនល្មើសក៏ត្រូវបញ្ជូនទៅក្នុងពេលជាមួយគ្នានោះដែរ។ ព្រះរាជអាជ្ញាបន្ទាប់ពីទទួលបាននូវ

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤០

[84] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៨៩

[85] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១១១

លទ្ធផលនៃការ ស៊ើបអង្កេត ព្រះរាជអាជ្ញាអាច សួរ និងស្តាប់ចម្លើយជនល្មើស ឬជនពាក់ព័ន្ធបាន។ ផ្អែកតាមមូលដ្ឋានដែលបានមកពីការស៊ើបអង្កេត និងភាពស៊ីសង្វាក់គ្នានៃអង្គហេតុ និងចម្លើយរបស់ជនពាក់ព័ន្ធ បើពិនិត្យឃើញថា មានភស្តុតាង និងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីធ្វើបណ្តឹង នោះព្រះរាជអាជ្ញានឹងអាចសម្រេចបើកការស៊ើបសួរ។ ប៉ុន្តែដូចដែលការបកស្រាយខាងលើដែរ ព្រះរាជអាជ្ញាក៏ត្រូវពិនិត្យទៅលើស្ថានភាពនៃសំណុំរឿងផងដែរតើគ្រប់លក្ខខណ្ឌដើម្បីបើកការស៊ើបសួរឬទេ។

**២.១.៤ អានុភាពនៃកិច្ចស៊ើបសួរ**

នៅពេលដែលព្រះរាជអាជ្ញាបើកកិច្ចស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អានុភាពមួយចំនួននឹងកើតមានឡើងដូចជា៖ ការផ្តាច់រយៈពេលនៃអាជ្ញាយុកាល ការផ្ទេរនូវសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរ និងការកំណត់ដែនសមត្ថកិច្ចនៃកិច្ចស៊ើបសួរ។

- **ការផ្តាច់រយៈពេលនៃអាយុកាល៖** ដូចដែលបានរៀបរាប់រួចមកហើយ ការចាប់ផ្តើមនៃកិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរ នឹងនាំឱ្យមានការផ្តាច់នូវអាជ្ញាយុកាលនៃបទល្មើស។ ជាទូទៅអាជ្ញាយុកាលនៃបទល្មើស នឹងត្រូវរាប់ចាប់គិតពីពេលប្រព្រឹត្តបទល្មើស ។ ទន្ទឹមនឹងនេះមិនថាកិច្ចស៊ើបសួរនោះត្រូវបានបើកដោយព្រះរាជអាជ្ញា ឬត្រូវបានបើកដោយសារការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ អាជ្ញាយុកាលនឹងត្រូវផ្តាច់។ ហើយថេរវេលាថ្មីនិងត្រូវរាប់ឡើងវិញនៅពេលដែលកិច្ចចោទប្រកាន់ឬ កិច្ចស៊ើបសួរត្រូវបានបញ្ចប់[86]។
- **ការផ្ទេរនូវសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរ៖** ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។ ព្រោះបើគ្មានដីកានេះសមត្ថកិច្ចក្នុងការស៊ើបសួររបស់ចៅក្រមស៊ើបសួរក៏មិនទាន់មានដែរ លុះត្រាតែព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសិន។ ហើយទន្ទឹមជាមួយគ្នានោះអំណាចរបស់ចៅក្រមស៊ើបសួរក៏ត្រូវចាប់ផ្តើមក្នុងពេលជាមួយគ្នានោះដែរ។
- **ការកំណត់ដែនសមត្ថកិច្ចនៃកិច្ចស៊ើបសួរ៖** ដែនសមត្ថកិច្ចនៃកិច្ចស៊ើបសួរ នឹងត្រូវបានកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរផ្ទាល់តែម្តង ព្រោះនៅពេលដែលចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា នោះចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុដែលមានសរសេរនៅក្នុងដីកានេះប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើក្នុងករណីដែលលេចឡើងនូវអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេល

[86] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១១

ស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ហើយព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក្នុងករណីនេះបើមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាទេ នោះចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ឧទាហរណ៍៖ ក្នុងករណីដែលចៅក្រមស៊ើបសួររកឃើញថា អង្គហេតុដែលបញ្ជូនមកមានបទល្មើសមួយផ្សេងទៀត ដែលខុសពីក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា នោះចៅក្រមស៊ើបសួរត្រូវស្នើសុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញាសិន ទើបអាចស៊ើបសួរទៅលើបទល្មើសថ្មីនោះបាន។ ប៉ុន្តែប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងដំបូង នោះចៅក្រមស៊ើបសួរ មិនចាំបាច់សុំដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ[87]។

### ២.១.៥ ការបិទបញ្ចប់កិច្ចស៊ើបសួរ

កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការស៊ើបសួរចំពោះសំណុំរឿងមូលសព្វគ្រប់អស់ហើយ នោះចៅក្រមស៊ើបសួរនឹងធ្វើការបិទបញ្ចប់កិច្ចស៊ើបសួរ ដោយត្រូវជូនព័ត៌មាននេះដល់ ព្រះរាជអាជ្ញា ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណីនិង មេធាវី។ ២ថ្ងៃបន្ទាប់ពីបិទកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ។ បន្ទាប់ពីពិនិត្យសំណុំរឿង ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរថ្មីទៀតនោះ ព្រះរាជអាជ្ញាត្រូវធ្វើតាមមាត្រា១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ត្រង់ចំណុចនេះមានន័យថា ព្រះរាជអាជ្ញាអាចស្នើសុំឱ្យចៅក្រមស៊ើបសួរ ធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ថាមានប្រយោជន៍។ ហើយបើចៅក្រមស៊ើបសួរមិនព្រមតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ថ្ងៃ ដោយត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាឆាប់បំផុត។ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[88]។ តែបើព្រះរាជអាជ្ញាយល់ដូចចៅក្រមស៊ើបសួរដែរ ថាការស៊ើបសួរត្រូវបានបញ្ចប់ នោះព្រះរាជអាជ្ញាត្រូវ ធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ដីកាសន្និដ្ឋានស្ថាពរជាយោបល់ និងការយល់ឃើញរបស់ព្រះរាជអាជ្ញាចំពោះការបិទបញ្ចប់កិច្ចស៊ើបសួរ។ ដីកានេះអាចស្តែងចេញតាមស្ថានភាពពីរយ៉ាង៖

- ស្ថានភាពទី១គឺព្រះរាជអាជ្ញាអាចប្តឹងសុំ ឱ្យចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទ ទៅជំនុំជំម្រះ

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១២៥

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១៣២

- ស្ថានភាពទី២គឺព្រះរាជអាជ្ញាអាចប្តឹងសុំ ឱ្យចៅក្រមស៊ើបសួរសម្រេចលើកលែងការចោទប្រកាន់ចំពោះជនត្រូវចោទ។

ដីកាសន្និដ្ឋានស្ថាពរ ត្រូវតែបង្វិលទៅចៅក្រមស៊ើបសួរវិញជាមួយនឹងសំណុំរឿងដែលចៅក្រមបញ្ជូនមកក្នុងរយៈពេល១៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង១ខែបើជនត្រូវចោទនៅក្រៅឃុំ ដោយចិរវេលានេះត្រូវគិតពីថ្ងៃដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿង [89] ។ ការបិទបញ្ចប់កិច្ចស៊ើបសួរនឹងត្រូវធ្វើឡើងដោយដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ដែលដីកាអាចស្តែងចេញតាមរូបភាពពីរយ៉ាងៈ

- **ដីកាបញ្ជូនទៅជំនុំជម្រះ៖** កាលណាចៅក្រមស៊ើបសួរយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរ នឹងសម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដោយដីកានេះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់[90]។
- **ដីកាលើកលែងចោទប្រកាន់៖** ចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងការចោទប្រកាន់នៅក្នុងករណីដូចតទៅៈ
  - ក្នុងករណីអំពើប្រព្រឹត្តិមិនមែនជាបទល្មើសព្រហ្មទណ្ឌ។
  - ជនដែលប្រព្រឹត្តិអំពើនោះនៅតែគេមិនស្គាល់ (គ្មានអត្តសញ្ញាណ)។
  - គ្មានភស្តុតាងដាក់បន្ទុកគ្រាប់គ្រាន់លើជនត្រូវចោទ។

ជាគោលការណ៍ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុជានិច្ច។ មួយវិញទៀតចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច ធ្វើតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។ ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុត ដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី[91]។

## ២.២ ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

### ២.២.១ លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

ការបង្ហាញខ្លួនភ្លាមគឺជានីតិវិធីមួយក្នុងចំណោមនីតិវិធីទាំងបី នៃការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅៈ

- **បទល្មើសជាបទល្មើសជាក់ស្តែង៖** បទល្មើសជាក់ស្តែងត្រង់នេះគឺចង់សំដៅដល់បទល្មើសមជ្ឈិមជាក់ស្តែងតាមមាត្រា ៨៦នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបានឱ្យនិយមន័យថា បទល្មើសជាក់ស្តែងគឺជាបទ

---
[89] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៤៦

[90] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៤៧

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២៤៧

ល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ហើយក៏ត្រូវចាត់ទុកថាជាបទល្មើសជាក់ស្តែងផងដែរកាលណានៅក្រោយពេលមានបទល្មើសបន្តិចរួចមក ជនសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រជាប់ចាប់ប្រភីង និងបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។ ទន្ទឹមនឹងនេះមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការចាត់ទុកដូចជា បទមជ្ឈិមជាក់ស្តែងក៏ត្រូវយកមកអនុវត្តផងដែរ។

- **ការផ្តន្ទាទោសបទល្មើស៖** ជាលក្ខខណ្ឌ បទល្មើសត្រូវមានការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច១ឆ្នាំ និងច្រើនបំផុត៥ ឆ្នាំ ដែលនេះបញ្ជាក់ថាបទល្មើសដែលមានការផ្តន្ទាទោសតិចជាង១ ឆ្នាំមិនអាចចូលជាលក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាមទេ។
- **លក្ខខណ្ឌអាយុរបស់ជនល្មើស៖** ជនល្មើសត្រូវតែជានីតិជន ពោលគឺបុគ្គលដែលដល់នីតិភាព ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ចំណុចនេះបង្ហាញថានីតិវិធីបង្ហាញខ្លួនភ្លាម មិនអាចធ្វើឡើងចំពោះអនីតិជនបានទេ។
- **រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមនឹងជំនុំជម្រះបាន៖** មានន័យថាសំណុំរឿងដែលត្រូវចោទប្រកាន់តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម គឺត្រូវតែជាសំណុំរឿងដែលមានភស្តុតាងគ្រប់គ្រាន់ ទើបអាចបង្ហាញអំពីពិរុទ្ធភាពរបស់ជនល្មើសបាន ព្រោះបើមានវិមតិសង្ស័យលើជនល្មើសនោះនីតិវិធីនេះមិនអាចអនុវត្តបានទេ[92]។

កាលណាមិនមានលក្ខខណ្ឌគ្រប់គ្រាន់ទេ ព្រះរាជអាជ្ញាមិនអាចអនុវត្តបណ្តឹងអាជ្ញាដោយប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបានទេ ជាពិសេសបើរឿងក្តីមានលក្ខណៈស្មុគស្មាញព្រះរាជអាជ្ញាគួរជ្រើសរើសនីតិវិធីស៊ើបសួរជំនួសវិញ។

### ២.២.២ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

#### ២.២.២.១ នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា

នីតិវិធីនៃការបង្ហាញខ្លួនភ្លាមនឹងត្រូវ ធ្វើឡើងតាមកិច្ចនីតិវិធីមួយរបស់ព្រះរាជអាជ្ញាគឺ កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម។ កាលណាព្រះរាជអាជ្ញាសម្រេចថា ត្រូវប្រើនីតិវិធីបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវអនុវត្តនីតិវិធីដូចតទៅ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន
- ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៧

- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម[93]។

បន្ថែមពីនេះព្រះរាជអាជ្ញាក៏ត្រូវប្រាប់ជនជាប់ចោទផងដែរថា ខ្លួនមានសិទ្ធសុំពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ និទ្ទេសនៃទម្រង់ការដូចបានរៀបរាប់ខាងលើ ត្រូវចុះក្នុងកំណត់ហេតុ បើមិនដូច្នេះទេ នឹងនាំឱ្យមានមោឃៈភាពនៃនីតិវិធី។

**២.២.២.២ នីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ**

បន្ទាប់ពីតុលាការបានទទួលបណ្តឹងតាមរយៈ កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមរបស់ព្រះរាជអាជ្ញា ពេលនោះសមត្ថកិច្ចនៃយុត្តាធិកាជំនុំជម្រះត្រូវបានចាប់ផ្តើម។ ជនជាប់ចោទនឹងត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។ នៅពេលបង្ហាញខ្លួននេះ តុលាការនឹងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទ ព្រមទាំងធ្វើរបាយការណ៍សង្ខេបរឿងក្តីដែលបានចោទប្រកាន់ផងដែរ។ បន្ទាប់មកតុលាការត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួន។ ក្នុងករណីដែលជនជាប់ចោទសុំរយៈពេល ឬបើតុលាការយល់ឃើញថា រឿងក្តីមិនអាចជំនុំជម្រះភ្លាមៗបានទេ នោះសំណុំរឿងត្រូវលើកទៅសវនាការក្រោយ[94]។

**ក. ការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា**

កាលណាតុលាការ បានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមពីព្រះរាជអាជ្ញា ហើយតុលាការយល់ឃើញថាសំណុំរឿងដែលព្រះរាជអាជ្ញាបញ្ជូនមក មានភាពស្មុគស្មាញ ឬមិនអាចបំពេញលក្ខខណ្ឌនៃការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមទេ ដោយតម្រូវជាចាំបាច់នូវការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែម នោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរវិញ។ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើមិនដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាព[95]។

**ខ. ការឃុំខ្លួនជនជាប់ចោទ**

តុលាការអាចសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នបាន ដោយសាលក្រមដែលមានបញ្ជាក់ពីសំអាងហេតុ។ ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណី ការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៨ កថាខណ្ឌទី១

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៨ កថាខណ្ឌទី៧

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៨ កថាខណ្ឌទី១១

ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើស១ឆ្នាំប៉ុណ្ណោះ[96]។ ម៉្យាងវិញទៀតការឃុំខ្លួននេះអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី
- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ នឹងអ្នកសមគំនិត។
- ដើម្បីធានារក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានភាពច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស[97]។

តុលាការនឹងចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ក្នុងករណីដែលជនជាប់ចោទជាកម្មវត្ថុនៃការឃុំខ្លួនដូចដែលបាន រៀបរាប់ខាងលើ។

**គ. ការប្រកាសសាលក្រមលើអង្គសេចក្តី**

ចំពោះនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម តុលាការត្រូវតែប្រកាសសាលក្រមលើអង្គសេចក្តីក្នុងរយៈពេលមិនអាចលើពី ២សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ក្នុងករណីតុលាការមិនប្រកាសសាលក្រមឱ្យបានមុន ២សប្តាហ៍ទេ នោះការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ មានន័យថាជនជាប់នឹងត្រូវដោះលែងឱ្យមានសេរីភាពវិញ[98]។ ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធសេរីភាពរបស់ជនជាប់ចោទដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ដូចនេះក្នុងនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមការឃុំខ្លួនមិនអាចធ្វើបានយូរឡើយ។

**២.២.៣ អានុភាពនៃការចូលបង្ហាញខ្លួនភ្លាម**

នៅពេលដែលព្រះរាជអាជ្ញា សម្រេចជ្រើសរើសវិធីចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម តាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម នោះនឹងនាំឱ្យមានអានុភាពដូចជា ការផ្តាច់អាជ្ញាយុកាល ការផ្ទេរសមត្ថកិច្ចទៅយុត្តាធិការជំនុំជម្រះ និងការកំណត់ដែនសមត្ថកិច្ចនៃការជំនុំជម្រះ។

[96] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២០៤

[97] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា២០៥

[98] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៨ កថាខណ្ឌទី១០

- **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ព្រោះនៅពេលដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម នោះនឹងនាំឱ្យមានការចាប់គិតថេរវេលាថ្មីនៃអាជ្ញាយុកាល។
- **ការផ្ទេរសមត្ថកិច្ចទៅយុត្តាធិការជំនុំជម្រះ៖** យើងឃើញថានៅពេលដែលតុលាការទទួលបានកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ដែលធ្វើឡើងដោយព្រះរាជអាជ្ញា នោះសមត្ថកិច្ចនឹងផ្ទេរមកយុត្តាធិការជំនុំជម្រះផ្ទាល់តែម្តង។
- **ការកំណត់ដែនសមត្ថកិច្ចនៃការជំនុំជម្រះ៖** ក្នុងនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមតុលាការអាចជំនុំជម្រះតែបុគ្គលដែលបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទប៉ុណ្ណោះ។ ត្រង់ចំណុចនេះមានន័យថា តុលាការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្តីពីការបង្ហាញខ្លួន ដែលធ្វើដោយព្រះរាជអាជ្ញាប៉ុណ្ណោះ[99]។ តុលាការមិនអាចជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលផ្សេងដែលមិនមានកំណត់ក្នុងកំណត់ហេតុនេះឡើយ។

## ២.៣ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

### ២.៣.១ លក្ខខណ្ឌនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ចំពោះលក្ខខណ្ឌក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់នូវបទល្មើសមួយចំនួន ដែលអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចអនុវត្តនីតិវិធីនេះបាន។ តួយ៉ាងដូច ជាក្នុងករណីបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការដើម្បីជំនុំជម្រះដោយផ្ទាល់[100]។ ចំណែកឯបទមជ្ឈិមវិញនីតិវិធីនេះក៏អាចអនុវត្តបានដែរ ប៉ុន្តែច្បាប់មិនបានចែងជាក់លាក់អំពីលក្ខខណ្ឌទេ[101]។ ត្រង់ចំណុចនេះយើងអាចបកស្រាយបានថាបើគ្មានលក្ខខណ្ឌនៃការបើកការស៊ើបសួរ ឬការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមទេ នោះព្រះរាជអាជ្ញាអាចប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់។ លក្ខខណ្ឌទាំងនេះយើងអាចបកស្រាយដូចតទៅ៖

- បទល្មើសដែលចោទប្រកាន់ជាបទមជ្ឈិមមិនជាក់ស្តែង និងមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ពីពិរុទ្ធភាពនៃជនជាប់ចោទបាន។
- បទល្មើសនោះជាបទល្មើសមជ្ឈិមជាក់ស្តែង ឬចាត់ទុកដូចជាបទល្មើសមជ្ឈិមជាក់ស្តែង តែត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពី៦ថ្ងៃ និងតិចជាង១ឆ្នាំ។

---

[99] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៣៤៩

[100] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៩

[101] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៥ កថាខណ្ឌទី២

- បទល្មើសនោះជាបទល្មើសមជ្ឈិមជាក់ស្តែង ឬចាត់ទុកដូចជាបទល្មើសមជ្ឈិមជាក់ស្តែង ដែលត្រូវផ្តន្ទាទោសយ៉ាងតិច១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ និងមានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់ពីពិរុទ្ធភាពនៃជនជាប់ចោទបាន ប៉ុន្តែជនជាប់ចោទជាអនីតិជន។

បន្ថែមពីលក្ខខណ្ឌខាងលើក៏អាចមាន មូលហេតុមួយចំនួនទៀតដែលព្រះរាជអាជ្ញាអាចពិចារណាទៅលើស្ថានភាពផ្សេងទៀតដូចជា មានសំណុំរឿងកកស្ទះច្រើន ស្ថានភាពភាពនៃសំណុំរឿងមានភស្តុតាងជាក់បន្ទុកគ្រប់គ្រាន់ជាដើម ដែលនេះអាស្រ័យទៅលើភាពបត់បែនរបស់ព្រះរាជអាជ្ញា ប៉ុន្តែទោះជាយ៉ាងណាមិនត្រូវឃ្លាតចាកពីលក្ខខណ្ឌច្បាប់ឡើយ។

### ២.៣.២ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

#### ២.៣.២.១ លក្ខខណ្ឌទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ជាការចាប់ផ្តើមនៃនីតិវិធី ព្រះរាជអាជ្ញាត្រូវធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដែលត្រូវមានទម្រង់ដូចតទៅ៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ដីកានេះត្រូវប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ។ ដីកានេះក៏ត្រូវបញ្ជាក់ដែរថា ជនជាប់ចោទអាចពឹងពាក់មេធាវីឲ្យអមខ្លួនបាន។

#### ២.៣.២.២ ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ចំពោះរយៈពេល ដែលត្រូវគោរព រវាងការប្រគល់ដីកាឲ្យដល់ជនជាប់ចោទ និងកំណត់ថ្ងៃឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖

- ១៥ថ្ងៃ៖ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់សាលាដំបូង
- ២០ថ្ងៃ៖ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយផ្សេងទៀតក្នុងដែនដីជាតិ
- ២ខែ៖ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ខែ៖ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត[102]។

ក្នុងករណីដែលជនជាប់ចោទមិនចូលបង្ហាញខ្លួនទេ តុលាការនឹងពិនិត្យមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ តុលាការបង្គាប់ឲ្យចេញដីកាកោះបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឲ្យជនជាប់ចោទចូលខ្លួន

[102] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៥៧

ជាថ្មីម្តងទៀត លើកលែងតែបណ្តឹងអាជ្ញារលត់។ ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅសវនាការ តុលាការអាចពិនិត្យមើលរឿង ប្រសិនបើជនជាប់ចោទយល់ព្រមជាក់លាក់ឱ្យជំនុំជម្រះភ្លាម។ ប្រសិនបើជនជាប់ចោទមិនព្រមឲ្យជំនុំជម្រះទេតុលាការបង្គាប់រឿងនេះទៅជំនុំជម្រះនៅពេលសវនាការក្រោយទៀត[103]។

### ២.៣.៣ អានុភាពនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចេញដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ នឹងនាំឲ្យបង្កើតនូវអានុភាពមួយចំនួនដូចជា ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចទៅយុត្តាធិកាជំនុំជម្រះ និងការកំណត់ដែនសមត្ថកិច្ច។

- **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** តាមរយៈការចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ នឹងនាំឲ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល[104]។ ចំណុចនេះបានបញ្ជាក់ថាការអនុវត្តននីតិវិធីនេះគឺ នាំឲ្យមានការរាប់ឡើងវិញនូវចិរវេលាថ្មីនៃអាជ្ញាយុកាល ដែលនេះជាហេតុនាំឲ្យបណ្តឹងអាជ្ញាមិនងាយរលត់ដោយផុតអាជ្ញាយុកាលទេ។
- **ការផ្ទេរសមត្ថកិច្ចទៅយុត្តាធិកាជំនុំជម្រះ៖** ខុសពីការស៊ើបសួរ នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់នឹងផ្ទេរសមត្ថកិច្ចដោយផ្ទាល់តែម្តងទៅកាន់ យុត្តាធិកាជំនុំជម្រះនៅពេលកិច្ចនៃនីតិវិធីនេះត្រូវបានធ្វើដោយព្រះរាជអាជ្ញា។
- **ការកំណត់ដែនសមត្ថកិច្ច៖** តុលាការធ្វើការជំនុំជម្រះតែអង្គហេតុ និងបុគ្គលណាដែលមានកំណត់នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ប៉ុណ្ណោះ[105]។ ចំពោះអង្គហេតុដែលលេចឡើងផ្សេង ត្រូវស្នើឲ្យព្រះរាជអាជ្ញាធ្វើការបើកការស៊ើបសួរ។

[103] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៤៩១

[104] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា១១

[105] ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា៣៤៩

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងការបកស្រាយនូវប្រធានបទ ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរួចមក យើងអាចសន្និដ្ឋានបានថា ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ឬគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺជាការផ្តល់នូវវិធានកណ្តាលមួយសម្រាប់ព្រះរាជអាជ្ញា ក្នុងការថ្លឹងថ្លែងនូវចំណាត់ការរបស់ខ្លួន ដើម្បីសម្រេចអំពីបណ្តឹងអាជ្ញា។ តាមរយៈគោលការណ៍នេះព្រះរាជអាជ្ញាអាចមាន ជម្រើសក្នុងការវាយតម្លៃ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ថាគួរតែចោទប្រកាន់ ឬតម្កល់រឿងទុក ដោយផ្អែក ទៅលើទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្តិ ភាពរីករាលដល់សង្គម និងលទ្ធផលដែលប្រមូលបានពីការស៊ើបអង្កេត។

តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ក៏បានផ្តល់នូវវិធីនៃការចោទប្រកាន់ ៣យ៉ាងដល់ព្រះរាជអាជ្ញាផងដែរគឺ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ វិធីទាំង៣នេះអនុញ្ញាតឱ្យព្រះរាជអាជ្ញាអាចជ្រើសរើសនូវ មធ្យោបាយធ្វើបណ្តឹងទៅតាមស្ថានភាពនៃសំណុំរឿង។ បន្ទាប់ពីបានធ្វើការសិក្សាលម្អិតទៅលើ ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា យើងបានរកឃើញ និងអាចកំណត់បាននូវ ហេតុផលមួយចំនួនដែល នាំឲ្យមានការបង្កើតនូវគោលការណ៍ និងវិធីនៃការចោទប្រកាន់នេះឡើង ដោយយើងបានកំណត់នូវហេតុផល២សំខាន់ៗដូចជា ទី១ គឺដើម្បីផ្តល់នូវយុត្តិធម៌មួយដ៏ឆាប់រហ័ស និងទី២ គឺដើម្បីធ្វើឱ្យនីតិវិធីប្រកបដោយភាពច្បាស់លាស់។

**យុត្តិធម៌ឆាប់រហ័ស៖** យុត្តិធម៌ឆាប់រហ័សមិនមែនសំដៅដល់ ការជម្រះក្តីដែលលឿនហួសហេតុ និងមិនសមហេតុផលនោះទេ។ ប៉ុន្តែសំដៅដល់ការអនុវត្តនីតិវិធីព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធភាព ដើម្បីស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ឱ្យបានក្នុងរយៈពេលមួយដ៏សមស្រប។ យើងទទួលស្គាល់ថានីតិវិធីនីមួយៗ ត្រូវតម្រូវឱ្យមានភាពច្បាស់លាស់ ប៉ុន្តែបើនីតិវិធីធ្វើឡើងដោយអូសបន្លាយពេលវេលាយូរពេក នោះនឹងនាំឱ្យប៉ះពាល់ដល់ភាគីនៃសំណុំរឿង។ យុត្តិធម៌ដែលបានមកក្នុងរយៈពេលយូរខ្លាំងពេក អាចនឹងក្លាយទៅជាភាពអយុត្តិធម៌ទៅវិញ។ ដូចនេះហើយបាន ជាក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឱ្យព្រះរាជអាជ្ញា អាចជ្រើសរើសវិធីនៃការចោទប្រកាន់ដើម្បីជាប្រយោជន៍ ដល់ភាពឆាប់រហ័សក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។ តួយ៉ាង ព្រះរាជអាជ្ញាអាចពិនិត្យស្ថានភាពនៃសំណុំរឿង ហើយបើលក្ខខណ្ឌតម្រូវ ព្រះរាជអាជ្ញាអាចជ្រើសរើសវិធីចោទប្រកាន់ណាមួយដែលមានភាពឆាប់រហ័ស ឧទាហរណ៍ នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ទន្ទឹមនឹងនេះ ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលមានព្យសនកម្មតិចតួច និងមានលក្ខខណ្ឌអាចតម្កល់រឿងទុកបាន ព្រះរាជអាជ្ញាអាចតម្កល់រឿងទុក និងចូលអន្តរាគមន៍ ដោយបង្វែរទៅជាការអប់រំណែនាំ ឬសម្របសម្រួលវិញ។ ការអនុវត្តនីតិវិធី

ទាំងនេះនឹង អាចចូលរួមចំណែកកាត់បន្ថយការកកស្ទះសំណុំរឿង ព្រមទាំងពន្លឿនការស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះផងដែរ។

**ភាពច្បាស់លាស់នៃនីតិវិធី៖** យុត្តិធម៌ឆាប់រហ័សមួយមុខគឺពុំទាន់គ្រាប់គ្រាន់ទេ ទន្ទឹមនឹងនេះដំណើរការនៃនីតិវិធីក៏ត្រូវមានភាពច្បាស់លាស់ផងដែរ។ តួយ៉ាងនៅក្នុងដំណាក់កាលព្រះរាជអាជ្ញា វិធីនៃការចោទប្រកាន់នីមួយៗគឺ សុទ្ធសឹងតែមានកំណត់នូវ ទម្រង់ និងលក្ខខណ្ឌនៃនីតិវិធីច្បាស់លាស់។ ឧទាហរណ៍ ចំពោះបទឧក្រិដ្ឋព្រះរាជអាជ្ញាត្រូវតែ បើកការស៊ើបសួរ ដែលនេះសបញ្ជាក់ឱ្យឃើញថា ច្បាប់បានគិតគូរយ៉ាងម៉ត់ចត់អំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ជាពិសេសជៀសវាងនូវការផ្តន្ទាទោសដោយការភ័ន្តច្រឡំដែលធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពរបស់បុគ្គល។ ដោយឡែកចំពោះវិធីចោទប្រកាន់ពីរផ្សេងទៀត ក៏មានលក្ខខណ្ឌតម្រូវសម្រាប់ព្រះរាជអាជ្ញាផងដែរ ដូចជានីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមជាដើម គឺតម្រូវឱ្យសំណុំរឿងត្រូវមានភស្តុតាងមូលសព្វគ្រប់ ទើបអាចជំនុំជម្រះបាន។

ប៉ុន្តែទន្ទឹមនឹងផលវិជ្ជមាន ជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានេះ ក៏ផ្តល់នូវផលអវិជ្ជមានមួយចំនួនផងដែរ។ យើងទទួលស្គាល់ថា បទប្បញ្ញត្តិទាំងអស់មិនអាចមានតែផលវិជ្ជមាននោះទេ ពោលគឺតែងតែមាននូវផលអវិជ្ជមានភ្ជាប់ជាមួយជានិច្ច តែបើបញ្ញត្តិនោះមានផលវិជ្ជមានច្រើនដែលផ្តល់ជាប្រយោជន៍ដល់សង្គម ហើយមានផលអវិជ្ជមានតិចតួចនោះ យើងគួរគប្បីតែទទួលយក ព្រោះគ្មានបទប្បញ្ញត្តិណាដែលល្អឥតខ្ចោះនោះទេ។ ចំពោះជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាវិញ យើងអាចពិចារណាឃើញថា គោលការណ៍នេះបានផ្តល់នូវផលវិជ្ជមានជាច្រើនដល់ ការអនុវត្តនយោបាយព្រហ្មទណ្ឌរបស់អយ្យការ ដោយគោលការណ៍នេះបានផ្តល់នូវភាពបត់បែនដល់ព្រះរាជអាជ្ញា ក្នុងការអនុវត្តបណ្តឹង ដោយធ្វើការថ្លឹងថ្លែងពីប្រយោជន៍សាធារណៈ។ តែទោះជាយ៉ាងណាគោលការណ៍នេះក៏នាំមកនូវផលអវិជ្ជមានផងដែរ កាលណាមានភាពអសកម្មរបស់ព្រះរាជអាជ្ញា ក្នុងការអនុវត្តគោលការណ៍នេះ។ ប៉ុន្តែភាពអសកម្មដែលអាចកើតមានឡើង នឹងត្រូវបានបង្ការដោយ ដោយការអនុញ្ញាតឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ជាជាលាយលក្ខណ៍អក្សរ មកអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងបាន។

សរុបសេចក្តីមក ការអនុវត្តគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ឬជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានេះ គឺជាគោលការណ៍ដែលមិនអាចខ្វះបានសម្រាប់ដំណើរការ នីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ។ ប៉ុន្តែដើម្បីឲ្យការអនុវត្តប្រកបទៅដោយនិរន្តរភាព ព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវ ក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន និងត្រូវគតិគូរពីប្រយោជន៍សង្គមជាតិជាធំ ដោយត្រូវជៀសវាងដាច់ខាតនូវការប្រព្រឹត្តិអំពើពុករលួយ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងតាមការសិក្សាប្រធានបទខាងលើ យើងឃើញថាគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺជាគោលការណ៍ដ៏សំខាន់ សម្រាប់ការដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ប៉ុន្តែដើម្បីឲ្យគោលការណ៍នេះ អាចអនុវត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននូវភាពត្រឹមត្រូវ យើងខ្ញុំមាននូវអនុសាសន៍មួយចំនួនដូចតទៅ៖

**ការស្រាវជ្រាវ និងការសិក្សាបន្ថែម៖** ព្រះរាជអាជ្ញាគួរធ្វើការសិក្សាស្រាវជ្រាវជាប្រចាំដើម្បី ពង្រឹងនូវសមត្ថភាពរបស់ខ្លួន ព្រោះបទពិសោធន៍តែមួយមុខគឺពុំគ្រប់គ្រាន់ទេ។ ចំណេះដឹង និងបទពិសោធន៍ត្រូវដើរទន្ទឹមគ្នា ប្រសិនបើព្រះរាជអាជ្ញាពេញដោយបទពិសោធន៍ ហើយថែមទាំងមានការសិក្សាបន្ថែមជាប្រចាំទៀតនោះ រាល់ការសម្រេចរបស់ព្រះរាជអាជ្ញានឹងប្រកបដោយភាពច្បាស់លាស់ ត្រឹមត្រូវ នឹងមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ស្ថាប័នពាក់ព័ន្ធ ជាពិសេសឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌គួរលើកទឹកចិត្តដល់ព្រះរាជអាជ្ញាក្នុងការសិក្សាស្រាវជ្រាវបន្ថែមជាប្រចាំ ដោយរៀបចំជាវគ្គបណ្តុះបណ្តាលជាប្រចាំតាមដែលអាចធ្វើទៅបាន ដើម្បីធានាប្រសិទ្ធភាពការងាររបស់ព្រះរាជអាជ្ញា។

**ការបែងចែកជាជំនាញ៖** ក្នុងពេលបច្ចុប្បន្នយើងឃើញថា ព្រះរាជអាជ្ញាចាត់ការនូវរាល់គ្រប់បទល្មើសព្រហ្មទណ្ឌគ្រប់វិស័យទាំងអស់ ដែលនេះក៏ផ្តល់ការលំបាកដល់ព្រះរាជអាជ្ញាផងដែរ ព្រោះបន្ថែមពីលើបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ក៏នៅមានបទល្មើសព្រហ្មទណ្ឌតាមវិស័យផ្សេងទៀត ដែលចែងដោយច្បាប់ដោយឡែក។ ប្រសិនជាបទល្មើសដែលចែងដោយច្បាប់ដោយឡែកនោះ កើតមានញឹកញាប់ នោះវាមិនមែនជាបញ្ហាទេ ព្រោះព្រះរាជអាជ្ញាមានបទពិសោធន៍ទៅលើរឿងនេះច្រើន។ ប៉ុន្តែបើជាបទល្មើសដែលពុំសូវកើតមាន ហើយជាបទល្មើសតាមវិស័យ ឧទាហរណ៍ វិស័យនគរូបនីយកម្មជាដើម បើព្រះរាជអាជ្ញាមិនធ្លាប់បានសិក្សាស្រាវជ្រាវបន្ថែម ឬទទួលការបណ្តុះបណ្តាលអំពីបទល្មើសទាំងនោះទេ បញ្ហានេះអាចជាការលំបាកក្នុងការសម្រេចអំពីបណ្តឹងអាជ្ញា។ ត្រង់ចំណុចនេះ ក្រៅពីបទល្មើសព្រហ្មទណ្ឌទូទៅ គួរគប្បីឲ្យព្រះរាជអាជ្ញាម្នាក់ៗអាចមានជំនាញទាក់ទងនឹងបទល្មើសតាមវិស័យនីមួយៗ ផងដែរ។ ការធ្វើបែបនេះនឹងអាចជួយពន្លឿនដំណើរការនៃនីតិវិធី និងធានាបាននូវភាពច្បាស់លាស់នៃការធ្វើបណ្តឹង។

**ការគោរពនូវក្រមសីលធម៌វិជ្ជាជីវៈ៖** ដើម្បីធានាថា ការសម្រេចអំពីបណ្តឹងអាជ្ញាមានភាពត្រឹមត្រូវ នឹងធានាបាននូវផលប្រយោជន៍សាធារណៈ។ បុគ្គលដែលទទួលបាននីតិសម្បទាជាព្រះរាជអាជ្ញា ត្រូវប្រកាន់ភ្ជាប់ជានិច្ច នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ដោយត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ឱ្យបានត្រឹមត្រូវ។ ក្នុងការបំពេញតួនាទី ព្រះរាជអាជ្ញាត្រូវ ជៀសវាងពីការប្រព្រឹត្តអំពើពុករលួយជាដាច់ខាត។

# ឯកសារយោង

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្តៈ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើកាលពីថ្ងៃទី២១ កញ្ញា ឆ្នាំ១៩៩៣។

២. ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១0 សីហា ឆ្នាំ២00៧។

៣. ក្រមព្រហ្មទណ្ឌ ប្រកាសឱ្យប្រើកាលពីថ្ងៃទី៣0 ខែវិច្ឆិកា ឆ្នាំ២00៧។

៤. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២0១៤។

៥. ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២0១៤។

៦. ច្បាប់ស្តីពីឯកពន្ធភាព ប្រការឱ្យប្រើថ្ងៃទី២១ ខែតុលា ឆ្នាំ ២00៦។

៧. ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២00៨

៨. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៤ កក្កដា ឆ្នាំ២0១៦

៩. គោលការណ៍ណែនាំ តួនាទីរបស់ព្រះរាជអាជ្ញាអនុម័តដោយអង្គការសហប្រជាជាតិ ឆ្នាំ១៩៩0 ប្រទេសគុយបា ទីក្រុងហាវ៉ាណា

## ខ. ឯកសារជំនួយស្មារតីះ

១. សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ២0១៣-២0១៤

២. មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បកស្រាយដោយ ៖ ឯកឧត្តម ហ៊ី សោភា ឯកឧត្តម ប៊ុន ហ៊ុន ឯកឧត្តម តើត រិទ្ធ ឯកឧត្តម ផូវសំភី និងលោកស្រី ចាំង ស៊ីណាត

៣. មេរៀននីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយ ៖ សាស្ត្រាចារ្យ ហ៊ាង ឡេង

៤. សៀវភៅសិក្សា នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២0២២ រៀបរៀងដោយ ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

៥. មេរៀននីតិព្រហ្មទណ្ឌ រៀបរៀងដោយ ៖ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

៦. សៀវភៅនីតិព្រហ្មទណ្ឌ រៀបរៀងដោយ ៖ ឯកឧត្តម ហ៊ី សោភា

៧. មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ៖ លោកស្រី ឌី លីឡា និងលោកខាន់ សុខា

៨. លំហូនីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ ៖ លោក សេង រិទ្ធី ព្រះរាជអាជ្ញារង អយ្យការអមសាលាដំបូងខេត្តកណ្តាល

៩. ទ្រឹស្តីកំណត់បទល្មើសព្រហ្មទណ្ឌ រៀបរៀងដោយ ៖ លោកមេធាវី មួនសៀងលី

១០. សេចក្តីព្រាងច្បាប់ស្តីពីលក្ខនិកៈនៃក្រឡាបញ្ជី

១១. មូលដ្ឋានចោទប្រកាន់ សម្រាប់ព្រះរាជអាជ្ញាក្នុងរឿងព្រហ្មទណ្ឌ រៀបរៀងដោយ ៖ មេធាវី ទៀងវុទ្ធា

១២. អត្ថបទស្រាវជ្រាវធាតុផ្សំបទល្មើស រៀបរៀងដោយ ៖ លោក ផេង វិជ្ជ័យ

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ១ | ដីកាបង្គាប់ឱ្យនាំជនជាប់ចោទមកកាន់សវនាការ |
| ២ | ដីកាសម្រេចយកជនជាប់ចោទមកកាន់សវនាការ |
| ៣ | ដីកាកោះសាក្សីឱ្យចូលសវនាការ |
| ៤ | ដីកាបញ្ជូន |
| ៥ | ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ |
| ៦ | ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរ |
| ៧ | ដីកាសន្និដ្ឋានស្ថាពរ |
| ៨ | ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន |
| ៩ | ដីកាកោះដើមបណ្ដឹងរដ្ឋប្បវេណីឱ្យចូលសវនាការ |
| ១០ | ដីការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ (គំរូទី២) |
| ១១ | កំណត់ហេតុស្ដីពីការបង្គប់ឱ្យចូលបង្ហាញខ្លួនភ្លាម |
| ១២ | ដីកាបញ្ជាឱ្យចូលខ្លួន |
| ១៣ | ដីកាបង្គាប់ឱ្យស៊ើបសួរបឋម |
| ១៤ | កំណត់ហេតុទទួលវត្ថុតាង |
| ១៥ | កំណត់ហេតុស្ដាប់ចម្លើយ |
| ១៦ | កំណត់ហេតុស្រុះស្រួល |
| ១៧ | ដីកាកោះ |
| ១៨ | ដីកាផ្ទេរសមត្ថកិច្ច |
| ១៩ | ដីកាបញ្ជាស្វែងរកចាប់ខ្លួន |
| ២០ | លិខិតអញ្ជើញ |
| ២១ | លិខិតជូនដំណឹង |
| ២២ | ដីកាតម្កល់រឿងទុកឥតចាត់ការ |
| ២៣ | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបទល្មើសថ្មីបន្ថែម |

| | |
|---|---|
| ២៤ | ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម |
| ២៥ | ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ |
| ២៦ | ដីកាឱ្យដំណឹងពីសេចក្ដីសម្រេចរបស់តុលាការ |
| ២៧ | ដីកាដោះលែងទណ្ឌិត |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ____
ចុះថ្ងៃទី__ ខែ___ ឆ្នាំ________
លេខ ________/____

# ដីកាបង្គាប់ឱ្យ
# នាំជនជាប់ចោទមកកាន់សវនាការ

**យើង ____________ តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី**

ជម្រាបមក **លោកប្រធានពន្ធនាគារខេត្តរតនគិរី** ឱ្យនាំជនជាប់ចោទដែលមានឈ្មោះដូចខាងក្រោមមកកាន់សាលាដំបូងខេត្តរតនគិរី **នៅថ្ងៃទី**______ **ខែ**______ **ឆ្នាំ** ________ **នៅវេលាម៉ោង** ______________ **នាទី** ។

| ល.រ | នាមត្រកូល-នាមខ្លួន | លេខ.ថ្ងៃ.ខែ.ឆ្នាំឃុំខ្លួន | អាយុ | បទល្មើស |
|---|---|---|---|---|
| | ឈ្មោះ ________<br>ភេទ____ | ______________<br>______________ | ________ឆ្នាំ | ______________ ប្រព្រឹត្តនៅចំណុច__________ ស្ថិតក្នុងភូមិ__ ______ឃុំ____ ស្រុក________ ខេត្តរតនគិរី កាលពីថ្ងៃ __ ខែ ________ឆ្នាំ ______។ |

ថ្ងៃ__________ ខែ__________ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ខេត្តរតនគិរី, ថ្ងៃទី____________ ខែ ____ឆ្នាំ ២០២១

**តំណាងអយ្យការ**

យើង ________________ ប្រធានពន្ធនាគារខេត្តរតនគិរី សូមបញ្ជាក់ថា ជនដែលមានឈ្មោះខាងលើ ពិតជាជាប់ឃុំឃាំងនៅក្នុងពន្ធនាគាររបស់យើងពិតប្រាកដមែន ហើយយើងនឹងបញ្ជូនជនទាំងនេះឲ្យបានទាន់ពេលវេលាតាមការកំណត់របស់តុលាការ។

រតនគិរី, ថ្ងៃទី ________ ខែ ________ ឆ្នាំ ២០២១

**ប្រធានពន្ធនាគារ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ____
ចុះថ្ងៃទី___ ខែ_____ ឆ្នាំ______
លេខ ........../.....

# ដីកាសម្រេច
# យកជនជាប់ចោទមកកាន់សវនាការ

**យើង__________តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី**

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ________ចុះថ្ងៃទី______ ខែ___ ឆ្នាំ______ដែលមានជនជាប់ចោទ៖ ឈ្មោះ_______ភេទ__ អាយុ __ឆ្នាំ "**ឃុំខ្លួន**"

ជាប់ចោទពីបទ៖ ________________ប្រព្រឹត្តនៅចំណុច___________ស្ថិតក្នុងភូមិ___ ________ឃុំ____ស្រុក________ខេត្តរតនគិរី កាលពីថ្ងៃ __ ខែ ___ឆ្នាំ__________បទល្មើសព្រហ្មទណ្ឌ ដែលមានចែងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា_____កថាខណ្ឌ____នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច៖**

**ក**-ឱ្យនាំជនជាប់ចោទឈ្មោះ _________ ភេទ__ អាយុ____ឆ្នាំ ទៅសាលាដំបូងខេត្តរតនគិរី **នៅថ្ងៃទី____ ខែ____ ឆ្នាំ_______ វេលាម៉ោង______ នាទីព្រឹក** ដើម្បីជំនុំជម្រះពីបទចោទដូចដែលមានចែងខាងលើ។

**សមាសភាពអង្គសវនាការ៖**

-លោក____________________________ជាចៅក្រមជំនុំជម្រះ
-លោក____________________________ជាតំណាងអយ្យការ
-លោក____________________________ជាក្រឡាបញ្ជីសវនាការ

ថ្ងៃ________________________ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រតនគិរី, ថ្ងៃទី____ខែកក្កដា ឆ្នាំ២០២១

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ___
ចុះថ្ងៃទី___ ខែ___ឆ្នាំ_____

## ដីកាកោះសាក្សីឱ្យចូលសវនាការ

**យើង___________តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី**

-**បានឃើញ** មាត្រា_______នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ **នស/រកម/០៨០៧/០២៤** ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ_____ចុះថ្ងៃទី_____ខែ_____ឆ្នាំ_____របស់អយ្យការអមសាលាដំបូងខេត្តរតនគិរី ដែលមានជនជាប់ចោទ៖ ឈ្មោះ_____ហៅ_____ភេទ_____អាយុ_______ឆ្នាំ

"**ឃុំខ្លួន**"

ជាប់ចោទពីបទ៖ ____________________ប្រព្រឹត្តនៅចំណុច______ស្ថិតក្នុងភូមិ______ឃុំ ______ស្រុក_____ខេត្តរតនគិរី កាលពីថ្ងៃ______ខែ _____ឆ្នាំ_____បទល្មើសព្រហ្មទណ្ឌដែលមានចែងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ______កថាខណ្ឌ______នៃក្រមព្រហ្មទណ្ឌ។

**<u>អញ្ជើញ</u>** ឈ្មោះ ______ភេទ____ អាយុ ______ឆ្នាំ ទីលំនៅបច្ចុប្បន្ននៅភូមិ_____ឃុំ_____ ស្រុក_____ខេត្តរតនគិរី ឱ្យចូលមកបង្ហាញខ្លួនក្នុងឋានៈជា **សាក្សី** នៅសាលាដំបូងខេត្តរតនគិរី ( សាលសវនាការជាន់ក្រោម ) **នាវេលាម៉ោង______នាទីព្រឹក នៅថ្ងៃទី_____ខែ ______ឆ្នាំ_____** ដើម្បីឲ្យអង្គសវនាការបានស្តាប់ចម្លើយរបស់សាមីខ្លួនក្នុងកិច្ចពិភាក្សាដេញដោលនាពេលសវនាការខាងលើ។

**សមាសភាពអង្គសវនាការ៖**

-លោក_____________________________ជាចៅក្រមជំនុំជម្រះ
-លោក_____________________________ជាតំណាងអយ្យការ
-លោក_____________________________ជាក្រឡាបញ្ជីសវនាការ

ថ្ងៃ_________________________ខែ__________ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រតនគិរី, ថ្ងៃទី_____ខែកក្កដា ឆ្នាំ២០២១

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**អយ្យការអម**
**សាលាដំបូងខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ____
ចុះថ្ងៃទី__ខែ___ឆ្នាំ________
លេខ ............/......

# <u>ដីកាបញ្ជូន</u>

**ផ្ញើជូន៖ លោកអធិការ នៃអធិការដ្ឋាននគរបាលស្រុកលំផាត់**

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| | -ដីកាកោះហៅដើមបណ្តឹងឈ្មោះ ........ភេទ.....<br>-ដីកាកោះហៅសាក្សីឈ្មោះ ........ភេទ.<br>-ដីកាកោះហៅសាក្សីឈ្មោះ ........ភេទ.<br>-ដីកាកោះហៅសាក្សីឈ្មោះ ....ភេទប្រុស<br>ឱ្យចូលសវនាការនៅថ្ងៃទី ........ **ខែ** ..... **ឆ្នាំ** .....**វេលា** **ម៉ោង** ...**និង** .....**នាទី** នៅសាលាដំបូងខេត្តរតនគិរី សាលសវនាការជាន់ក្រោម។ | ..........ច្បាប់ | ..................<br>..................<br>..................<br>..................<br>..................<br>..................<br>.........។ |
| | | | |
| | សរុប | ..........ច្បាប់ | |

ថ្ងៃ ................................ ខែ..................... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រតនគិរី,ថ្ងៃទី ............ ខែ កក្កដា ឆ្នាំ ២០២១

**តំណាងអយ្យការ**

**បានទទួល**

ថ្ងៃទី .......... ខែ ............. ឆ្នាំ ២០២...

យើង.......................................ឈ្មោះ:.............................................................បានប្រគល់ដីកាកោះនេះឱ្យដល់ឈ្មោះ:.........................................មានទីលំនៅភូមិ....................ឃុំ-សង្កាត់ .........................................ស្រុក-ក្រុង.......................................ខេត្តរតនគិរី នៅថ្ងៃទី ......... ខែ ............ ឆ្នាំ........... ផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះមួយច្បាប់អោយសាមីខ្លួន ហើយប្រាប់សាមីខ្លួនថា ប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជី ពេលចូលទៅដល់តុលាការ។

| **អ្នកទទួល** | **អ្នកប្រគល់** |
|---|---|
| **ហត្ថលេខា ឬស្នាមមេដៃ** | **ហត្ថលេខា ឬស្នាមមេដៃ** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តរតនគិរី**

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់[១]

លេខ: .................អ.យ/

**យើង ..............តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី**

**-បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ.........ចុះថ្ងៃទី.....ខែ.........ឆ្នាំ..........របស់ អយ្យការអមសាលាដំបូងខេត្តរតនគិរី ។

**-បានឃើញ** មាត្រា..............នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ **នស/រកម/០៨០៧/០២៤** ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់**

**ឃើញថា[២]:**

កាលពីថ្ងៃទី.....ខែ.........ឆ្នាំ.......វេលាម៉ោង.......និង.....នាទី នៅចំណុចភូមិ....... .........ឃុំ..........ស្រុក............ខេត្តរតនគិរី .........................។

**ច្បានឃើញ[៣]**

**-បានឃើញ** កំណត់ហេតុនៃបទល្មើស............ ចុះថ្ងៃទី...... ខែ..... ឆ្នាំ......... ។

---

[១] ដីកានេះប្រើសម្រាប់ ព្រះរាជអាជ្ញា ធ្វើការសន្និដ្ឋានចោទប្រកាន់ផ្ញើរឿងទៅជម្រះផ្ទាល់ ចំពោះបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែងដែលមាន
ទណ្ឌកម្មកំណត់ក្នុងច្បាប់មិនលើសពី១០ឆ្នាំ ហើយដែលមានភស្តុតាង និងធាតុផ្សំបទល្មើសគ្រប់គ្រាន់។

[២] រៀបរាប់អំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត។

**សម្គាល់:** ត្រូវធ្វើដីកាកោះហៅភាគីឲ្យចូល ទៅបង្ហាញខ្លួននៅមុខតុលាការ នាពេលសវនាការ (មាត្រា៤៥៧)

[៣] លើកយកលិខិត និងភស្តុតាងសំអាងផ្សេងៗ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការយល់ឃើញរបស់ខ្លួន ដើម្បីសម្រេចឲ្យបានត្រឹមត្រូវតាមច្បាប់។

**-បានឃើញ** ចម្លើយរបស់សាក្សីឈ្មោះ ______ភេ_____ បានឆ្លើយនៅជំណាក់កាលអយ្យការថា៖ កាលពីថ្ងៃទី ___ ខែ ___ ឆ្នាំ _____ វេលាម៉ោង______និង _____នាទី នៅចំណុចភូមិ___ ឃុំ____ស្រុក______ខេត្ត___________។

**-បានឃើញ** ដីកាសម្រេចប្រគល់វត្ថុតាងលេខ___ចុះថ្ងៃទី____ ខែ_____ ឆ្នាំ_____ របស់អយ្យការអមសាលាដំបូងខេត្តរតនគិរី ។

**-បានឃើញ** ឯកសារមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងសំណុំរឿង ។

<u>**យល់ឃើញថា**</u>[៤]

-កាលពីថ្ងៃទី____ ខែ_____ ឆ្នាំ_____ វេលាម៉ោង___និង___នាទី ស្ថិតភូមិ____ ឃុំ___ ស្រុក ខេត្ត______ពិតជាមានអង្គ______________ប្រព្រឹត្តដោយ____________ប្រាកដមែន ។

-ក្រោយពេលកើតហេតុ_________________________________________។

-នៅពេលដែលសមត្ថកិច្ច_______________________________________។

-សំណុំរឿងព្រហ្មទណ្ឌនេះ មានលក្ខខណ្ឌគ្រប់គ្រាន់អាចបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់បាន ។

**ហេតុដូច្នេះសម្រេច**[៥]

**បញ្ជូនវត្ថុតាងរួមមាន ៖**

-_______________________និងសំណុំរឿងព្រហ្មទណ្ឌលេខ____ចុះថ្ងៃទី______ ខែ ________ ឆ្នាំ______ ទៅសាលាដំបូងខេត្តរតនគិរី **ដើម្បីជំនុំជម្រះតាមច្បាប់** ។

ថ្ងៃ_______________________ខែ____ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រតនគិរី, ថ្ងៃទី____ខែ_____ឆ្នាំ_______

**តំណាងអយ្យការ**

---

[៤] សន្និដ្ឋាន វាយតម្លៃពីអំពើរបស់ជនត្រូវចោទទៅលើធាតុផ្សំនៃបទល្មើស សម្រាប់បញ្ជាក់ថា មាន ឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់, ស្លាប់ ឬគេចខ្លួនបាត់ មាន ឬគ្មានសារតាជាតិគ្រប់គ្រាន់។

[៥] ផ្អែកតាមសំអាងហេតុ និងការយល់ឃើញរបស់ខ្លួន តំណាងអយ្យការ ត្រូវសម្រេចឲ្យបានច្បាស់លាស់ អំពីការចោទប្រកាន់ ការបង្គង់បណ្តឹងអាជ្ញា និងការលែងបណ្តឹងអាជ្ញា ដោយលើកយកមាត្រាច្បាប់មកសំអាងឲ្យបានត្រឹមត្រូវ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ: ________
ចុះថ្ងៃទី____ ខែ____ ឆ្នាំ_____
លេខ: ....................**អ.យ/ដ១**

## <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

**យើង________ តំណាងអយ្យការអមសាលាដំបូងខេត្តរតនគិរី**

- **បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ__ចុះថ្ងៃទី______ខែ_____ឆ្នាំ______របស់អយ្យការអមសាលាដំបូងខេត្តរតនគិរី។
- **បានឃើញ** របាយការណ៍សរុបលេខ__________ ចុះថ្ងៃទី_____ខែ_____ ឆ្នាំ_______ របស់អធិការដ្ឋាននគរបាលស្រុក______។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**យល់ឃើញថា មានតម្រុយសន្មតថា៖**

| | | |
|---|---|---|
| - នាមត្រកូល-នាមខ្លួន៖ | | ភេទ____អាយុ_____ ឆ្នាំ_____ ជនជាតិ_________ |
| មុខរបរ | ៖ | **កសិករ** |
| សាសនា | ៖ | ព្រះពុទ្ធ ប្រពន្ធឈ្មោះ______មានកូនចំនួន______នាក់ |
| ទីកន្លែងកំណើត | ៖ | ភូមិ_____ ឃុំ_____ ស្រុក/ខណ្ឌ_______ រាជធានី/ខេត្ត ________________។ |
| ទីលំនៅបច្ចុប្បន្ន | ៖ | ភូមិ____ឃុំ_____ ស្រុក________ខេត្ត______ |
| ឪពុកឈ្មោះ | ៖ | ____________ ម្ដាយឈ្មោះ_________ |
| ទោសពីមុន | ៖ | _______ជានីតិជន/អនីតិជន "<u>**ឃាត់ខ្លួន**</u>" |

**បានប្រព្រឹត្តដូចតទៅ[២]៖**

កាលពីថ្ងៃទី_______________ ខែ_____ ឆ្នាំ___ មានករណី_____មួយបានកើតឡើង នៅស្ថិតនៅក្នុងភូមិ_____ ឃុំ_____ ស្រុក_____ ខេត្ត_____ បង្កឡើងដោយជនសង្ស័យឈ្មោះ ភេទ___អាយុ___ ឆ្នាំ______________

អំពើរបស់ជនសង្ស័យខាងលើជាបទល្មើស ៖ ______________________ ប្រព្រឹត្តនៅ ចំណុច_____ ស្ថិតនៅក្នុងភូមិ____ ឃុំ_____ ស្រុក_____ ខេត្ត_____ កាលពីថ្ងៃទី___ ខែ___ឆ្នាំ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមតាមមាត្រា____ នៃច្បាប់____និងមាត្រា___ និង មាត្រា_____ នៃក្រមព្រហ្មទណ្ឌ________។

**បានឃើញ** មាត្រា____ និងមាត្រា_____នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

- បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

☑ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើជនត្រូវចោទ[៣]៖

-ឈ្មោះ______ភេទ_____ អាយុ____ឆ្នាំ

ពីបទ៖ _________________ប្រព្រឹត្តនៅចំណុច_______ស្ថិតនៅក្នុងភូមិ______ ឃុំ_______ ស្រុក _______ ខេត្ត_____កាលពីថ្ងៃទី____ ខែ____ឆ្នាំ____ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោស តាមតាមមាត្រា___នៃ___និងមាត្រា___និងមាត្រា___នៃច្បាប់______។

ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ៖

-ឈ្មោះ______ភេទ___ អាយុ____ឆ្នាំ_____

ពីបទ៖ ____________ប្រព្រឹត្តនៅចំណុច______ ស្ថិតនៅក្នុងភូមិ___ ឃុំ____ស្រុក __________ខេត្ត______កាលពីថ្ងៃទី_____ ខែ_____ឆ្នាំ_____ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទា ទោសតាមតាមមាត្រា_____នៃ_____និងមាត្រា_____និងមាត្រា_____នៃច្បាប់_______។

ថ្ងៃ __________ខែ_______ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រតនគិរី, ថ្ងៃទី____ខែ____ឆ្នាំ ២០២១

**តំណាងអយ្យការ**

---

២ សេចក្ដីសង្ខេបអង្គហេតុ

៣ ឈ្មោះជនសង្ស័យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តរតនគិរី**
សំណុំរឿងព្រហ្មទណ្ឌលេខ:......
ចុះថ្ងៃទី.... ខែ.... ឆ្នាំ......
លេខ: ..........................**អ.យ/២០**

## <u>ដីកាសន្និដ្ឋានស្ថាពរ</u>

**យើង** ................. **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តរតនគិរី**

**-បានឃើញ** មាត្រា____ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ **នសរកម ០៨០៧-០២៤** ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ_____ចុះថ្ងៃទី_____ ខែ____ ឆ្នាំ___ របស់អយ្យការអមសាលាដំបូងខេត្តរតនគិរី។

**-បានឃើញ** សំណុំរឿងស៊ើបសួរលេខ_____ចុះថ្ងៃទី_____ ខែ____ឆ្នាំ_____ របស់សាលាដំបូងខេត្តរតនគិរី។

**-បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ______ចុះថ្ងៃទី______ ខែ____ ឆ្នាំ___ ______ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តរតនគិរី។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា**

| |
|---|
| - **អញ្ញត្រជន** "គ្មានសាវតារជាតិគ្រប់គ្រាន់" |

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ ____________________ប្រព្រឹត្តនៅចំណុច______ស្ថិតនៅភូមិ_____ឃុំ_____ស្រុក_____ខេត្តរតនគិរី កាលពីថ្ងៃទី_____ខែសីហា ឆ្នាំ_____បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា_____កថាខណ្ឌទី______ចំណុចទី______និងមាត្រា_____ នៃច្បាប់ស្តីពីព្រៃឈើ ។

**ឃើញថា១**

កាលពីថ្ងៃទី____ ខែ____ ឆ្នាំ____ វេលាម៉ោង____និង____នាទី នៅចំណុច____ ភូមិ ______ឃុំ_____ស្រុក_______ខេត្តរតនគិរី ។

-**បានឃើញ** កំណត់ហេតុបទល្មើសលេខ____ចុះថ្ងៃទី______ខែ_____ឆ្នាំ______របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរដ្ឋបាលព្រៃឈើ។ "**ង.០១**"

-**បានឃើញ** ចម្លើយរបស់សាក្សីឈ្មោះ________ភេទ_______ អាយុ___ឆ្នាំ_______បានឆ្លើយនៅដំណាក់ចៅក្រមស៊ើបសួរថា៖ ______________________________________________ ។

-**បានឃើញ** ដីកាសម្រេចប្រគល់វត្ថុតាងលេខ______ឱ្យទៅខណ្ឌរដ្ឋបាលព្រៃឈើខេត្តរតនគិរី ចុះថ្ងៃទី___ខែ___ឆ្នាំ______របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តរតនគិរី។

-**បានឃើញ** ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ________ចុះថ្ងៃទី______ខែ_____ឆ្នាំ_______ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តរតនគិរី។

-**បានឃើញ** របាយការណ៍ស្តីពីលទ្ធផលតបលេខ ________ចុះថ្ងៃទី________ខែ_________ ឆ្នាំ_______របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តរតនគិរី។

-**បានឃើញ** ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងសំណុំរឿង ។

**<u>យល់ឃើញថា២</u>**

- កាលពីថ្ងៃទី____ ខែ_____ ឆ្នាំ________ វេលាម៉ោង_____និង___នាទី ពិតជាមានអង្គហេតុ_________________________________ ប្រាកដមែន។

-អំពើរបស់ជនត្រូវចោទបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ និងសង្គម រួមនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងជម្រកសត្វព្រៃ ដែលច្បាប់ត្រូវការពារ។

---

១ រៀបរាប់សង្ខេបអង្គហេតុ និងកាលកំណត់ការនៃនីតិវិធីតាមលំដាប់
(ឧទាហរណ៍អង្គហេតុដែលបានកើតឡើងចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌អយ្យការចៅក្រមស៊ើបសួរ)
២ សំអាងហេតុសំអាងច្បាប់

-មានធាតុផ្សំ និងភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើ **អញ្ញាតជន** ពីបទ៖ ........ ........ប្រព្រឹត្តនៅចំណុច........ស្ថិតនៅភូមិ........ឃុំ........ស្រុក........ខេត្តរតនគិរី កាលពីថ្ងៃទី........ខែ........ឆ្នាំ........បទល្មើសដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា........ កថាខណ្ឌទី........ចំណុចទី........និងមាត្រា........កថាខណ្ឌ........ចំណុចទី........នៃច្បាប់ស្តីពីព្រៃឈើ ។

-ជនត្រូវចោទជា ........................គប្បីចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទតាមមាត្រា ........កថាខណ្ឌទី........ចំណុចទី........នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ........មាត្រា ........មាត្រា........និងមាត្រា........នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច៖**

ប្តឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច៖

☑ លើកលែងចោទប្រកាន់លើជនត្រូវចោទ៖

-**អញ្ញាតជន** "គ្មានសាវតារជាតិគ្រប់គ្រាន់"

